១

# តើខ្ញុំអាចដឹងថា ខ្ញុំជាគ្រិស្តបរិស័ទដោយរបៀបណា?

បង្កើនទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះជាម្ចាស់

**សៀវភៅសំរាប់សិស្ស**

**សិក្សាជាក្រុម**

សំរាប់**គ្រិស្តបរិស័ទថ្មី**

# មាតិកា

សេចក្តីផ្តើម

ជំពូកទី១ តើមនុស្សម្នាក់អាចក្លាយជាគ្រិស្តបរិស័ទដោយរបៀបណា?

ក. ការប្តេជ្ញាដែលចេញពីគំនិត

ខ. ការប្តេជ្ញាដែលចេញពីឆន្ទះ

គ. ការប្តេជ្ញាដែលចេញពីអារម្មណ៍

ជំពូកទី២ តើកន្លែងណាដែលខ្ញុំអាចមើលឃើញភស្តុតាងដែលបញ្ជាក់ថា ខ្ញុំជាគ្រិស្តបរិស័ទ?

ក. ព្រះគម្ពីរ

ខ. ព្រះវិញ្ញាណបរិសុទ្ធ

គ. ការផ្លាស់ប្រែនៅក្នុងជីវិតរបស់យើង

ជំពូកទី៣ ទំនាក់ទំនងផ្ទាល់ខ្លួនរបស់ខ្ញុំជាមួយនឹងព្រះយេស៊ូគ្រិស្ត

ក. ហេតុអ្វីបានជាចាំបាច់ត្រូវកសាងទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះយេស៊ូ?

ខ. តើទំនាក់ទំនងប្រភេទណាដែលយើងអាចបង្កើតជាមួយនឹងព្រះយេស៊ូ?

គ. ការសិក្សាអំពីព្រះជាម្ចាស់

ឃ. ជំហានជាមូលដ្ឋានដើម្បីបង្កើតទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះយេស៊ូ

ង. តើអ្វីទៅជាលទ្ធផលនៃការស្គាល់ព្រះជាម្ចាស់ដោយផ្ទាល់នោះ?

ជំពូកទី៤ តើខ្ញុំអាចធ្វើអ្វីបាន នៅពេលខ្ញុំមានមន្ទិលសង្ស័យចំពោះជំនឿខ្លួនឯង?

ក. តើនរណាជាអ្នកនាំមន្ទិលសង្ស័យទាំងនេះចូលមកក្នុងគំនិតរបស់យើង?

ខ. តើអ្វីខ្លះជាដើមហេតុនៃមន្ទិលសង្ស័យ?

គ. តើយើងអាចរកឃើញដើមហេតុនៃមន្ទិលសង្ស័យដោយរបៀបណា?

ឃ. តើត្រូវបណ្តេញមន្ទិលសង្ស័យរបស់យើងចេញដោយរបៀបណា?

ឯកសារសំរាប់អាន និងសិក្សាបន្ថែម

# សេចក្ដីផ្ដើម

តើធ្លាប់មានគេសួរយើងថា "ឯងជាគ្រិស្តបរិស័ទមែនទេ?" ។ តើមានចាំទេថា នៅពេលមានគេសួរបែបនេះ តើយើងឆ្លើយបែបណា? តើយើងភ័យ ឬក៏សើច? អ្នកខ្លះឆ្លើយទៅវិញថា "ពិតមែនហើយ! តើអ្នកឯងគិតថាខ្ញុំជាស្អី? អ្នកមិនជឿហ្អេះ?"

តើមនុស្សម្នាក់ពិតជាអាចដឹងថា សព្វថ្ងៃនេះខ្លួនគាត់ជាគ្រិស្តបរិស័ទ ឬមិនមែនគ្រិស្តបរិស័ទមែនឬ? តើទាល់តែចាំដល់ពេលគាត់ស្លាប់ ទើបដឹងថាគាត់ទៅស្ថានសួគ៌ ឬទៅស្ថាននរក?

នៅពេលអ្នកបានសិក្សាវគ្គនេះ យើងខ្ញុំសង្ឃឹមថា នឹងអាចជួយឆ្លើយសំនួរទាំងប៉ុន្មានរបស់អ្នកបាន ។ គោលបំណង នៃវគ្គនេះ គឺចង់ពន្យល់ឱ្យបានច្បាស់អំពីចំនុចចំនួន៤:

១. របៀបដែលយើងអាចក្លាយជាគ្រិស្តបរិស័ទ ។

២. កន្លែងដែលយើងអាចមើលឃើញពីភស្តុតាងដែលបញ្ជាក់ថា យើងជាគ្រិស្តបរិស័ទ ។

៣. អត្ថន័យនៃការមានទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះយេស៊ូ ។

៤. របៀបដែលយើងអាចធ្វើ នៅពេលមានមន្ទិលសង្ស័យចំពោះជំនឿខ្លួនឯង ។

# ជំពូកទី១

## តើមនុស្សម្នាក់អាចក្លាយជាគ្រិស្តបរិស័ទដោយរបៀបណា?

មុនពេលមនុស្សម្នាក់អាចដឹងច្បាស់ថា ខ្លួនគាត់ជាគ្រិស្តបរិស័ទ គាត់ត្រូវតែដឹងពីរបៀបក្លាយជាគ្រិស្តបរិស័ទជាមុនសិន ។ គ្មាននរណាម្នាក់អាចក្លាយជាគ្រិស្តបរិស័ទដោយភាពចៃដន្យនោះឡើយ ។ ព្រះជាម្ចាស់មិនដែលប្រើល្បិច ដើម្បីឱ្យមនុស្សម្នាក់ក្លាយជាយើងដើរតាមព្រះអង្គនោះឡើយ ។ ប្រសិនបើយើងចង់ក្លាយជាគ្រិស្តបរិស័ទ យើងត្រូវតែប្តេជ្ញាចិត្តដើរតាមព្រះគ្រិស្ត ។ ចំនុចទាំង៣ខាងក្រោម មានជាប់ទាក់ទងជាមួយនឹងការប្តេជ្ញាដែលយើងបានលើកមកនៅក្នុងមេរៀននេះ:

ការប្តេជ្ញាដែលចេញពីគំនិតរបស់យើង

ការប្តេជ្ញាដែលចេញពីឆន្ទះរបស់យើង

ការប្តេជ្ញាដែលចេញពីអារម្មណ៍របស់យើង

យើងនឹងចូលទៅសិក្សាស៊ីជំរៅចំពោះចំនុចទាំង៣នេះ ។

### ក. ការប្តេជ្ញាដែលចេញពីគំនិត

**១. យើងត្រូវតែយល់ និងជឿលើចំនុចមួយចំនួននៅក្នុងព្រះគម្ពីរ ដែលប្រាប់យើងអំពីរបៀបក្លាយជាគ្រិស្តបរិស័ទ**

នៅពេលយើងក្លាយជាគ្រិស្តបរិស័ទ យើងមិនមែនលោតទៅទាំងភាពងងឹតងងុលខាងផ្នែកជំនឿនោះឡើយ ។ ការសំរេចចិត្តធ្វើជាគ្រិស្តបរិស័ទ ត្រូវតែមានមូលដ្ឋាននៅលើសេចក្តីពិតដែលមាននៅក្នុងព្រះគម្ពីរ ភាពពិតនៃប្រវត្តិសាស្រ្តដែលបានមកពីការស្រាវជ្រាវ និងការសិក្សារបស់អ្នកប្រាជ្ញជាច្រើន ។

ប្រសិនបើយើងចង់ក្លាយជាគ្រិស្តបរិស័ទ យើងមិនចាំបាច់ត្រូវយល់អ្វីៗទាំងអស់នៅក្នុងព្រះគម្ពីរឡើយ ។ ប៉ុន្តែយើងត្រូវយល់អំពីសេចក្តីពិតជាមូលដ្ឋានមួយចំនួន ដែលប្រាប់យើងអំពីរបៀបក្លាយជាគ្រិស្តបរិស័ទ ។ ទាំងនេះមិនមែនជាការបង្រៀនទ្រឹស្តីសាសនា ដែលមានភាពស្មុកស្មាញនោះឡើយ ។ សេចក្តីពិតជាមូលដ្ឋាននៅក្នុងព្រះគម្ពីរមានភាពសាមញ្ញជាទីបំផុត សូម្បីតែកុមារក៏អាចយល់បានដែរ ។

**២. ទាំងនេះជាសេចក្តីពិត ដែលយើងចាំបាច់ត្រូវដឹង និងជឿដើម្បីក្លាយជាគ្រិស្តបរិស័ទ**

១. ពិតជាមានព្រះ ។ ហេប្រឺ ១១:៦

២. ព្រះគម្ពីរជាសេចក្តីពិត ។ ២ធីម៉ូថេ ៣:១៦

៣. ខ្ញុំមានអំពើបាប ដោយមិនគោរពតាមវិន័យរបស់ព្រះជាម្ចាស់ ។ រ៉ូម ៣:២៣

៤. ព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ ហើយព្រះអង្គបានប្រទានព្រះបុត្រាតែមួយរបស់ទ្រង់មក គឺព្រះយេស៊ូ ដើម្បីមានព្រះជន្ម និង សុគតដើម្បីខ្ញុំ ។ យ៉ូហាន ៣:១៦

៥. មានតែព្រះយេស៊ូមួយអង្គគត់ ដែលអាចអត់ទោសចំពោះអំពើបាបរបស់ខ្ញុំ។ កិច្ចការ ៤:១២

៦. ការកាត់ទោសចំពោះអំពើបាប គឺសេចក្តីស្លាប់ ( អស់កល្បជានិច្ច) ។ រ៉ូម ៦:២៣

៧. ខ្ញុំអាចទទួលការសង្គ្រោះពីការកាត់ទោសចំពោះអំពីបាប ដោយសារភាពអំពើបាបរបស់ខ្ញុំទៅកាន់ព្រះយេស៊ូ ហើយសុំព្រះអង្គអោយអត់ទោសអោយខ្ញុំ។ ១យ៉ូហាន ១:៩

៨. ឥឡូវនេះខ្ញុំអាចក្លាយជាគ្រិស្តបរិស័ទ ដោយយាងព្រះយេស៊ូមកដឹកនាំជីវិតរបស់ខ្ញុំ។ រ៉ូម ១០:៩-១០

ប្រសិនបើអ្នកបានធ្វើការសំរេចចិត្តធ្វើជាគ្រិស្តបរិស័ទរួចហើយ សូមចំណាយពេលគិតឡើងវិញមួយសន្ទុះសិន។ សូមពិនិត្យមើលសេចក្តីពិតទាំង៨ចំនុចខាងលើឡើងវិញ។ តើចំនុចមួយណាដែលអ្នកយល់ច្បាស់មុនពេលក្លាយជាគ្រិស្តបរិស័ទ? តើចំនុចមួយណាក្នុងចំណោមសេចក្តីពិតទាំង៨ ដែលអ្នកយល់មិនទាន់ច្បាស់រហូតមកដល់ពេលដែលអ្នកក្លាយជាគ្រិស្តបរិស័ទ? តើចំនុចមួយនោះធ្វើអោយអ្នកយល់ច្រឡំ អំពីអត្ថន័យនៃភាពជាគ្រិស្តបរិស័ទមែនទេ?

យើងចាំបាច់ត្រូវតែប្រយ័ត្នអំពីចំនុចនេះ យើងមិនអាចគិតថា ទាល់តែព្រះជាម្ចាស់ធ្វើតាមយើងជាមុនសិន ទើបទ្រង់អាចអត់ទោសអោយអំពើបាបយើងបាន។ ព្រះអាចទតឃើញចិត្តមនុស្សយ៉ាងច្បាស់។ ប្រសិនបើមនុស្សចូលមកដោយចិត្តស្មោះត្រង់ ពិតជាចង់ស្គាល់ព្រះអង្គ ហើយចង់រួចផុតពីអំពើបាបមែននោះ ព្រះនឹងទទួលពួកគេ។ ព្រះយេស៊ូមានបន្ទូលនៅក្នុងគម្ពីរយ៉ូហាន ៦:៣៧ថា "ខ្ញុំមិនបោះបង់ចោលអ្នកដែលមករកខ្ញុំជាដាច់ខាត" ។

ប៉ុន្តែមានចំនុចមួយទៀតក៏ពាក់ព័ន្ធនឹងបញ្ហានេះដែរ។ មនុស្សខ្លះមានអារម្មណ៍មិនល្អ ហើយអធិស្ឋានទៅកាន់ព្រះជាម្ចាស់។ ពួកគាត់គិតថា អ្វីៗអាចផ្លាស់ប្រែយ៉ាងងាយ ដោយសារតែពួកគាត់បានអធិស្ឋានរួចហើយ។ ពីរបីថ្ងៃ ឬពីរបីអាទិត្យក្រោយមក ពួកគាត់នៅតែមិនឃើញមានអ្វីផ្លាស់ប្រែទាល់តែសោះ ហើយពួកគាត់ក៏សន្និដ្ឋថា "គ្មានព្រះឯណាទេ។ ឬក៏ ការជឿលើព្រះយេស៊ូជារឿងកុហក" ។ ដូច្នេះបញ្ហាជាមួយពួកគាត់គឺ ពួកគាត់មិនដែលមានបទពិសោធន៍ជាមួយនឹងការសង្គ្រោះដ៏ពិត។ អ្នកខ្លះបានបង្ខំពួកគាត់ឱ្យសំរេចចិត្តលឿនពេក ទាំងពួកគាត់មិនទាន់យល់ផងថា អ្វីទៅហៅថាគ្រិស្តបរិស័ទផង។

## ខ. ការប្តេជ្ញាដែលចេញពីឆន្ទះ

នៅពេលដែលទារកបានកើតមកនៅក្នុងលោកនេះ ឪពុកម្តាយមិនដែលសួរកូនអំពី កិច្ចការដែលកូនចង់ធ្វើជារៀងរាល់ថ្ងៃនោះឡើយ។ ទារកមិនទាន់ធំល្មមនឹងអាចធ្វើការជ្រើសរើស ឬក៏ការសំរេចចិត្តណាមួយបានឡើយ។ បែបនេះខុសទាំងស្រុងពីមនុស្សដែលចង់ក្លាយជាគ្រិស្តបរិស័ទ។ ទារកពុំអាចមានជំរើសសំរាប់កំណើតរបស់ខ្លួនឯង។ ប៉ុន្តែមនុស្សធំអាចមានជំរើសចំពោះការកើតជាថ្មី។ អ្នកត្រូវតែជ្រើសរើសធ្វើជាគ្រិស្តបរិស័ទ និងធ្វើជាកូនរបស់ព្រះជាម្ចាស់។

យើងមិនមែនសំរេចចិត្តចង់មានបទពិសោធន៏ខាងផ្នែកសាសនា ដោយយោលទៅតាមអារម្មណ៏របស់ខ្លួនឯងនោះឡើយ ។ តែយើងកំពុងតែសំរេចចិត្ត ជ្រើសរើសអ្នកដឹកនាំសំរាប់ជីវិតរបស់យើង ។ ជំរើសរបស់យើងមានជាប់ពាក់ព័ន្ធជាមួយនឹងម្នាក់ទៀត គឺព្រះជាម្ចាស់ ។ យើងអាចទទួល ឬក៏បដិសេធទ្រង់ ។

**១. យើងត្រូវតែយល់អំពីអត្ថន័យនៃភាពជាគ្រិស្តបរិស័ទ**

ព្រះជាម្ចាស់មិនទទួលយកនូវការសំរេចចិត្តណា ដែលខ្វះនូវការពិចារណា ។ អ្នកត្រូវច្បាស់លាស់ ប្រសិនបើចង់ក្លាយជាគ្រិស្តបរិស័ទ ។ ព្រះនឹងជួយពន្យល់អ្នក អំពីកិច្ចការមួយចំនួនដែលពាក់ព័ន្ធនឹងការថ្វាយជីវិតរបស់អ្នកទៅព្រះអង្គ ។ អ្នកត្រូវយល់ពីការទទួលខុសត្រូវរបស់អ្នកចំពោះការសំរេចចិត្តនេះ ។ អ្នកត្រូវសារភាពអំពើបាបរបស់អ្នកទាំងអស់ ដោយយល់ព្រមជាមួយព្រះជាម្ចាស់ថា យើងបានធ្វើខុសចំពោះវិន័យរបស់ទ្រង់ ។ យើងត្រូវសំរេចចិត្តថា មិនត្រឡប់ទៅរកអំពើបាប ហើយដើរតាមព្រះយេស៊ូ និងការបង្រៀនរបស់ព្រះអង្គ ។

**យ៉ាកុប ១:២១**

**ហេតុនេះ បងប្អូនត្រូវលះបង់ចិត្តសៅហ្មងគ្រប់យ៉ាង និងចិត្តកម្រោលឃោរឃៅទាំងប៉ុន្មាននោះចោលទៅ ហើយកាន់ចិត្តស្លូតបូត ទទួលព្រះបន្ទូលដែលព្រះជាម្ចាស់បានបណ្ដុះក្នុងបងប្អូន ព្រោះបន្ទូលនោះអាចនឹងសង្គ្រោះព្រលឹងរបស់បងប្អូន។**

អ្នកត្រូវតែយល់អំពីអ្វីៗដែលជាប់ពាក់ព័ន្ធនឹងគ្រិស្តបរិស័ទ មុនពេលធ្វើការប្តេជ្ញាដែលចេញពីឆន្ទះរបស់អ្នក ។ ប្រសិនបើយើងមិនយល់អោយច្បាស់អំពី ការប្តេជ្ញានៅក្នុងយើងទេ ភាពសង្ស័យនឹងចូលមកក្នុងយើងនៅថ្ងៃក្រោយ ។ យល់អោយច្បាស់អំពីសេចក្តីពិត ហើយដឹងច្បាស់អំពីគោលដៅដែលយើងនឹងទៅដល់ ។ ប៉ុន្តែអ្នកត្រូវដឹងថា យើងនឹងមិនទាន់អាចមានលទ្ធភាព យល់គ្រប់ជ្រុងជ្រោយអំពីជីវិតរបស់គ្រិស្តបរិស័ទឡើយ មុនពេលយើងសំរេចចិត្តដើរតាមព្រះគ្រិស្ត ។ យើងគ្រាន់តែអាចយល់ផ្នែកខ្លះនៃជីវិតគ្រិស្តបរិស័ទប៉ុណ្ណោះ បន្ទាប់ពីយើងសំរេចចិត្តរស់ជីវិតជាគ្រិស្តបរិស័ទបានមួយរយៈ ។ ប្រសិនបើអ្នកមានចំងល់ច្រើន សូមអធិស្ឋាន និងទូលចំងល់ទាំងនោះទៅព្រះជាម្ចាស់ ។ សូមទូលសុំជំនួយពីព្រះអង្គ ។

**២. អ្នកត្រូវធ្វើការសំរេចចិត្តធ្វើជាគ្រិស្តបរិស័ទ**

នៅពេលដែលអ្នកយល់ច្បាស់អំពីសេចក្តីពិតដែលបានរៀបរាប់ខាងលើ អ្នកត្រូវតែធ្វើការជ្រើសរើស ។ ចំណាយពេលគិតពិចារណាអំពីការសំរេចចិត្តរបស់អ្នក ។ អ្នកត្រូវតែយល់ព្រមជាមួយនឹងព្រះជាម្ចាស់ថា អ្នកបានប្រព្រឹត្តអំពើបាប ។ អ្នកត្រូវយាងព្រះជាម្ចាស់មកធ្វើជាអ្នកដឹកនាំសំរេចជីវិតរបស់អ្នក ។ សូមកុំគ្រាន់គិត ប៉ុន្តែត្រូវធ្វើការសំរេចចិត្ត ដែលជាការប្តេជ្ញាចិត្ត ។ លោកយ៉ូស្វេនៅក្នុងសម្ពន្ធមេត្រីចាស់ ក៏ប្រាប់អ្នកដែលដើរតាមគាត់អោយធ្វើដូច្នេះដែរ ។ គាត់ប្រាប់ពួកគេអោយធ្វើការសំរេចចិត្ត ដើម្បីបំរើព្រះដ៏ពិតនៃស្ថានសួគ៌ ឬក៏បំរើព្រះក្លែងក្លាយ ។ សូមអាន យ៉ូស្វេ ២៤:១៤-១៥ ។

យើងត្រូវតែមានជំនឿថា ព្រះជាម្ចាស់នឹងធ្វើតាមអ្វីៗដែលបានចែងនៅក្នុងព្រះគម្ពីរ ។ ព្រះជាម្ចាស់មិនអាចអត់ទោសអោយយើង ដោយយើងគ្រាន់តែសារភាពអំពើបាបតែប៉ុណ្ណោះទេ ។ ព្រះមិនបានទាមទារអោយយើងលះបង់ទំលាប់ចាស់របស់យើងចោល មុនពេលយើងក្លាយជាគ្រិស្តបរិស័ទនោះឡើយ ។ ព្រះអង្គចង់បានតែការសំរេចចិត្តរបស់យើងប៉ុណ្ណោះ ។ យើងត្រូវជ្រើសរើសថា យើងនឹងបំរើអ្នកណា ។ ប្រសិនបើអ្នករើសយកព្រះយេស៊ូមកធ្វើជាអ្នកដឹកនាំជីវិតរបស់អ្នក ព្រះអង្គនឹងប្រទានអោយអ្នកនូវអំណាច ដែលអាចផ្លាស់ប្រែការរស់នៅរបស់អ្នកបាន ។ នេះគឺជាដំណើរការនៃការផ្លាស់ប្រែ ដែលត្រូវចំណាយពេលក្នុងមួយជីវិតនេះ ។ ប៉ុន្តែចំពោះការសំរេចចិត្តធ្វើជាគ្រិស្តបរិស័ទវិញ ចំណាយពេលតែពីរបីនាទីតែប៉ុណ្ណោះ ដែលស្រដៀងទៅនឹងការចាប់កំណើតរបស់ទារកដែលប្រើរយៈខ្លីប៉ុណ្ណោះ ។

យើងត្រូវយល់ថា នេះជាការប្តេជ្ញាមួយដ៏ធំសំរាប់មួយជីវិតរបស់យើង ។ ព្រះជាម្ចាស់មិនបានស្វែងរកគ្រិស្តបរិស័ទសំរាប់១សប្តាហ៍ ឬ២សប្តាហ៍នោះឡើយ ។ ព្រះអង្គនឹងផ្តល់អំណាចអោយយើង (បើយើងមានជំនឿ) ដើម្បីធ្វើការសំរេចចិត្តមួយដ៏ត្រឹមត្រូវ ។ យើងជាអ្នកជ្រើសរើស ព្រះអង្គមិនបានបង្ខំយើងឱ្យធ្វើជាកូនរបស់ទ្រង់ឡើយ ។

## ៣. ដោយមានជំនួយពីព្រះជាម្ចាស់ យើងត្រូវតែអនុវត្ត និងដើរតាមការសំរេចចិត្តរបស់យើង

នៅពេលយើងបានធ្វើសេចក្តីសំរេចមួយនៅក្នុងគំនិតរបស់យើង យើងត្រូវតែសំដែងវាចេញមកក្រៅ ។ យើងត្រូវប្រកាន់ភ្ជាប់នូវការទទួលខុសត្រូវរបស់យើង ។ តើព្រះរំពឹងថាយើងនឹងធ្វើអ្វី? ព្រះអង្គចង់អោយយើងសារភាពរាល់អំពើបាបរបស់យើង (សូមអាន ១យ៉ូហាន ១:៩) ចុះចូលជាមួយព្រះជាម្ចាស់ (យ៉ាកុប ១:២១) ហើយស្តាប់តាមព្រះវិញ្ញាណបរិសុទ្ធ នៅពេលព្រះអង្គបង្ហាញអោយយើងឃើញពីអំពើបាបរបស់យើង (យ៉ូហាន ១៦:៨) ។ នៅពេលអ្នកសំរេចចិត្តធ្វើជាគ្រិស្តបរិស័ទ គឺប្រៀបដូចជា "ការកើតជាថ្មី" អញ្ចឹង ។ ឥឡូវនេះ យើងមានជីវិតជាកូនរបស់ព្រះ ហើយវិញ្ញាណរបស់យើងត្រូវតែរីកធំដឹងក្តីឡើង ។ មានសេចក្តីបង្រៀនជាច្រើននៅក្នុងព្រះគម្ពីរដែលពន្យល់អំពី ជីវិតបែបនេះ ។ ព្រះដឹកនាំ និងជួយយើង ។ ព្រះអង្គមិនដែលបោះបង់យើងចោលឡើយ ។

យ៉ាកុប ២:២៤

**ដូច្នេះបងប្អូនឃើញថា ព្រះជាម្ចាស់ប្រោសមនុស្សអោយបានសុចរិត ដោយសារអំពើល្អដែលគេប្រព្រឹត្ត គឺមិនត្រឹមតែដោយសារជំនឿប៉ុណ្ណោះទេ។**

យើងត្រូវតែសំដែងការសំរេចចិត្តនោះចេញមកក្រៅ ។ (សូមអាន ហេព្រើ ១២:១-២) ជាមួយគ្នានេះដែរ ព្រះជាម្ចាស់ក៏ឆ្លើយតបតាមរយៈសមម្ថភាពដែរ គឺនៅពេលយើងសំរេចចិត្តធ្វើជាគ្រិស្តបរិស័ទ ។ ព្រះអង្គឆ្លើយតបដោយលើកលែងទោសអោយយើង និងជួយយើងអោយមានសេរីភាពរួចផុតពីអំណាចនៃអំពើបាប ។

**១យ៉ូហាន ១:៩**

**ប៉ុន្តែបើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិត ទ្រង់នឹងអត់ទោសយើងអោយរួចពីបាប ព្រមទាំងជម្រះយើងអោយបានបរិសុទ្ធ រួចគ្រប់**

ពីអំពើទុច្ចរិតទាំងអស់ផង។

ដោយមានជំនួយពីព្រះ យើងអាចមានជោគជ័យនៅក្នុងដំណើរនៃការសំរេចចិត្តរបស់យើងនៅក្នុងជីវិតនេះ។ ជាដំបូង យើងត្រូវធ្វើការប្តេជ្ញាដែលចេញពីគំនិត ដើម្បីអោយយល់គ្រប់ទាំងសេចក្តីពិត។ បន្ទាប់មក យើងត្រូវធ្វើការប្តេជ្ញាដែលចេញពីឆន្ទះ ដើម្បីសំរេចដើរតាមព្រះយេស៊ូ។ ឥឡូវនេះ ដល់ពេលដែលត្រូវធ្វើការពិចារណាចំពោះអារម្មណ៍របស់យើងវិញម្តង។

## គ. ការប្តេជ្ញាដែលចេញពីអារម្មណ៍

អារម្មណ៍មានសារៈសំខាន់ណាស់សំរាប់យើងម្នាក់ៗ ហើយវាក៏មានសារៈសំខាន់ដែរ នៅក្នុងជីវិតជាគ្រិស្តបរិស័ទ។ ពិតជាសំខាន់ក្នុងការយល់អោយបានច្បាស់អំពី របៀបដែលអារម្មណ៍របស់យើងពាក់ព័ន្ធជាមួយនឹងជីវិតដែលជាគ្រិស្តបរិស័ទ។

### ១. តើអារម្មណ៍របស់យើងពាក់ព័ន្ធជាមួយនឹងជីវិតជាគ្រិស្តបរិស័ទដោយរបៀបណា?

#### ១.១ យើងនឹងបញ្ចេញប្រតិកម្មខុសពីមុន

ចូរគិតដល់មិត្តរបស់អ្នក។ តើអ្នកស្គាល់ម្នាក់ណាដែលឆាប់រំភើប និងឆាប់រំជួយចិត្តដែរឬទេ? តើអ្នកធ្លាប់ជួបមនុស្សដែលគ្មានប្រតិកម្មខាងផ្លូវអារម្មណ៍ដែរឬទេ? ប្រហែលជាអ្នកធ្លាប់ជួប ប្រសិនបើម្នាក់នោះមានចិត្តរឹងដូចជាដំថ្ម។ យើងម្នាក់ៗមានប្រតិកម្មផ្សេងៗពីគ្នា ចំពោះស្ថានការណ៍ដែលកើតឡើងចំពោះមុខជារៀងរាល់ថ្ងៃ។

ធ្លាប់មាននរណាសន្យាថា អ្នកនឹងមានអារម្មណ៍ខុសពីមុន នៅពេលអ្នកក្លាយជាគ្រិស្តបរិស័ទដែរឬទេ? តើពួកគេបានប្រាប់អ្នកអំពី សេចក្តីស្រឡាញ់ អំណរ និងភាពសុខសាន្ត ដែលមាននៅក្នុងជីវិតរបស់គេ នៅលើកដំបូងដែលពួកគេអធិស្ឋានសុំព្រះធ្វើជាគ្រិស្តបរិស័ទដែរឬទេ? សូមប្រយ័ត្នចំពោះសំដីរបស់ពួកគេ។ បើអ្នកធ្វើដូចពួកគេ ហើយអារម្មណ៍បែបនោះ វាជាការប្រសើរបំផុត! សូមអរព្រះគុណព្រះជាម្ចាស់ចំពោះអារម្មណ៍ទាំងអស់នោះ។

មានមនុស្សខ្លះទៀតបានអធិស្ឋានអញ្ចឹងដែរ ប៉ុន្តែគ្មានអ្វីកើតឡើងទាល់តែសោះ។ អ្នកនាង ស៊ូ បានគិតពិចារណាយ៉ាងល្អិតល្អន់អំពី ការក្លាយជាគ្រិស្តបរិស័ទដែលបានចែងនៅក្នុងព្រះគម្ពីរ។ នាងដឹងថា បើនាងសំរេចចិត្តធ្វើជាគ្រិស្តបរិស័ទ ជីវិតរបស់នាងនឹងផ្លាស់ប្រែអស់មួយជីវិត។ ដើម្បីបញ្ជាក់ថា ការសំរេចចិត្តនេះជាការសំរេចចិត្តមួយដ៏ត្រឹមត្រូវ នាងក៏អធិស្ឋានទៅកាន់ព្រះជាម្ចាស់ ដោយសារភាពរាល់ទាំងអំពើបាបរបស់នាង ហើយសុំយាងព្រះយេស៊ូមកគង់ធ្វើជាអ្នកដឹកនាំជីវិតរបស់នាង។ បន្ទាប់មក នាងរង់ចាំ តែគ្មានអ្វីកើតឡើងទាល់តែសោះ។ នាងពុំបានទទួលអារម្មណ៍អំពីអ្វីទាំងអស់។ ដូច្នេះ នាងក៏អធិស្ឋានម្តងទៀត នៅតែគ្មានអ្វីកើតឡើងទៀត។ នាងអធិស្ឋានជាលើកទី៣ តែនៅតែទទួលលទ្ធផលដូចមុន។ ទីបំផុត នាងក៏ហៅមិត្តរបស់នាងដែលជាគ្រិស្តបរិស័ទមកជួប ហើយពន្យល់ប្រាប់រឿងរ៉ាវដែលកើតមានឡើង។ មិត្តរបស់នាងបានប្រាប់នាងថា "កុំព្រួយអី ស៊ូ! បន្តិចទៀតនេះ ឯងប្រាកដជាមានអារម្មណ៍ប្លែកជាមិនខាន"។

ស៊ូជាជនរងគ្រោះដោយសារដំបូន្មានមិនល្អ ចំនួន២លើករួចមកហើយ ។ នាងបានសន្យាថា នៅពេលនាងក្លាយជាគ្រិស្តបរិស័ទ នាងនឹងពោរពេញទៅដោយអារម្មណ៍រីករាយ និងភាពសុខសាន្តក្នុងចិត្ត ។ នៅពេលនាងអធិស្ឋាន ដូចជាគ្មានឃើញមានអ្វីកើតឡើងទាល់សោះ ។ យោបល់និងដំបូន្មានរបស់មិត្តនាងក៏មិនល្អដែរ ។ គ្មានខគម្ពីរមួយណានៅក្នុងព្រះគម្ពីរដែលសន្យាថា "អ្នកនឹងមានអារម្មណ៍រីករាយ ពេញដោយសេចក្តីស្រឡាញ់ និងភាពសុខសាន្តនៅក្នុងចិត្ត នៅពេលអ្នកក្លាយជាគ្រិស្តបរិស័ទ" នោះឡើយ ។

មានគ្រិស្តបរិស័ទខ្លះអាចមានអារម្មណ៍ល្អ និងប្រសើរបំផុត នៅពេលពួកគេចូលមករកព្រះគ្រិស្ត ។ គ្រិស្តបរិស័ទផ្សេងទៀតពុំមានអារម្មណ៍អ្វីទាំងអស់ ។ តាមពិតទៅ ស៊ូមានអារម្មណ៍កាន់តែតប់ប្រមល់ទៅៗ នៅប៉ុន្មានសប្តាហ៍ក្រោយ ។ រាល់ពេលនាងស្រែកជេរស្តីអោយកូនរបស់នាង នាងហាក់ដូចជាមានអារម្មណ៍ថា ធ្វើបែបនេះមិនត្រូវទេ ហើយនាងមិនដែលមានអារម្មណ៍បែបនេះពីមុនមកទេ ។ ក្រោយមកទើបនាងដឹងថា នេះជាព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបំភ្លឺនាងអោយកែប្រែឥរិយាបថទៅកាន់កូនរបស់នាង ។ មិនមែនមានតែនាងទេ ដែលទទួលរងនូវការខកចិត្តជាងមុន បន្ទាប់ពីបានក្លាយជាគ្រិស្តបរិស័ទ ។

## ១.២ អារម្មណ៍របស់យើងផ្លាស់ប្តូរខុសពីមុន

ស៊ូ ពិតជាបានទទួលអារម្មណ៍ល្អនៅសប្តាហ៍ ដែលនាងបានសំរេចចិត្តធ្វើជាគ្រិស្តបរិស័ទ ។ នាងគ្មានការសោកស្តាយចំពោះការសំរេចចិត្តនេះទាល់តែសោះ ។ ជីវិតរបស់នាងបានបញ្ជាក់ប្រាប់យើងយ៉ាងច្បាស់ថា អារម្មណ៍យើងនឹងផ្លាស់ប្តូរខុសពីមុន បន្ទាប់ពីបានក្លាយជាគ្រិស្តបរិស័ទ ។ ប៉ុន្តែយើងត្រូវប្រយ័ត្នអំពី ការរំពឹងទុករបស់យើងចំពោះព្រះជាម្ចាស់ ដោយរំពឹងថាព្រះអង្គនឹងបំពេញយើងដោយ ក្តីស្រឡាញ់ អំណរ និងភាពសុខសាន្តនៅក្នុងចិត្ត ជារៀងរាល់ថ្ងៃ ។ នេះមិនមែនជាការពិតទេ!

អារម្មណ៍របស់យើងជួនកាលមានការផ្លាស់ប្តូរលឿនជាទីបំផុត ។ យើងអាចមានអារម្មណ៍នៅជាប់ជាមួយព្រះនៅថ្ងៃនេះ ប៉ុន្តែថ្ងៃស្អែក យើងអាចនឹងគ្មានអារម្មណ៍បែបនេះ ហើយពេញទៅដោយកំហឹង ភាពធុនថប់ និងការបាក់ទឹកចិត្ត ។ តើនេះមានន័យថា យើងលែងទទួលការសង្គ្រោះហើយឬ? មិនពិតទេ! យើងត្រូវយល់ថា យើងជាមនុស្សលោក អារម្មណ៍របស់យើងតែងតែផ្លាស់ប្តូរជានិច្ច ។ នេះជារឿងធម្មតារបស់មនុស្ស ។ សូមកុំជិនះធ្វើអោយខ្លួនឯងមានអារម្មណ៍ដូចថ្ងៃមុន ឬថ្ងៃដំបូងដែលអ្នកក្លាយជាគ្រិស្តបរិស័ទ ។ សូមសំឡឹងទៅកាន់ព្រះជាម្ចាស់ ព្រោះព្រះអង្គជាអ្នកប្រទានថ្ងៃថ្មីដល់យើង ។ ថ្ងៃខ្លះយើងអាចទទួលភាពរីករាយ និងភាពសុខសាន្តនៅក្នុងចិត្តយ៉ាងស្រួល ។ ប៉ុន្តែថ្ងៃខ្លះ យើងនឹងជួបតែកំហឹង និងភាពសោកសៅ ។

## ១.៣ នៅពេលក្លាយជាគ្រិស្តបរិស័ទ គួរតែមានកន្លែងមួយសំរាប់អារម្មណ៍របស់យើង

នៅពេលក្លាយជាគ្រិស្តបរិស័ទ តើអារម្មណ៍របស់យើងមានសារៈសំខាន់យ៉ាងដូចម្តេចខ្លះ? តើព្រះជាម្ចាស់មិនចង់អោយយើងយកចិត្តទុកដាក់ ជាមួយអារម្មណ៍របស់យើងមែនឬ? ទេ! ប៉ុន្តែអារម្មណ៍ទាំងនោះ គួរតែមានកន្លែងសំរាប់ពួកវា ។ ទី១ហើយសំខាន់ជាងគេនោះគឺ សេចក្តីពិតនៅក្នុងព្រះគម្ពីរ ដែលប្រាប់យើងពីរបៀបក្លាយជា

គ្រិស្តបរិស័ទ ។ ទី២នោះគឺ ជំនឿ( អំណាច) ដែលព្រះប្រទានអោយយើង ដើម្បីបង្ហាញសេចក្តីពិតទាំងនោះចេញមកក្រៅ ដោយគោរពតាមសេចក្តីពិតទាំងនោះ និងធ្វើជាគ្រិស្តបរិស័ទ ។




សូមប្រៀបធៀបសេចក្តីពិត ជំនឿ និង អារម្មណ៍ ទៅនឹងផ្ទះមួយ ។ គ្រឹះរបស់ផ្ទះតំណាងអោយសេចក្តីពិតដែលមាននៅក្នុងព្រះគម្ពីរ ដែលប្រាប់យើងពីរបៀបក្លាយជាគ្រិស្តបរិស័ទ ។ ជញ្ជាំង ដំបូល បង្អួច... តំណាងអោយជំនឿ ដែលព្រះប្រទានមកអោយយើង ដើម្បីរស់ជាជីវិតគ្រិស្តបរិស័ទ ។ ព្រះអង្គប្រទានអំណាច ដែលអាចបំផ្លាស់បំប្រែជីវិតរបស់យើងទាំងស្រុងបាន ។ ចំនុចដែលខុសគេនោះគឺ អារម្មណ៍របស់យើងប្រៀបបាននឹងឡកំដៅនៅក្នុងផ្ទះ ។ អារម្មណ៍ជួយអោយយើងរីករាយ ដូចជាឡកំដៅដែលធ្វើអោយមនុស្សមានអារម្មណ៍ល្អនៅរដូវរងា ។

អារម្មណ៍របស់យើងមានសារៈសំខាន់ណាស់ ព្រោះព្រះបង្កើតយើងដោយភ្ជាប់អារម្មណ៍មកជាមួយ ។ ប៉ុន្តែរបៀបដែលយើងអាចមានអារម្មណ៍នៅពេលក្លាយជាគ្រិស្តបរិស័ទ មិនសំខាន់ដល់ការយល់ និងគោរពតាមសេចក្តីពិតនៅក្នុងព្រះគម្ពីរ ដែលប្រាប់យើងពីរបៀបក្លាយជាគ្រិស្តបរិស័ទនោះឡើយ ។

នៅពេលអ្នកក្លាយជាគ្រិស្តបរិស័ទ ព្រះជាម្ចាស់មានព្រះបន្ទូលសន្យាថា នឹងលើកលែងទោសរាល់អំពើបាបរបស់យើង សំអាតជីវិតរបស់យើង ហើយនាំជីវិតថ្មីមកអោយវិញ្ញាណរបស់យើង ។ ព្រះអង្គមានព្រះបន្ទូលសន្យាទៀតថា នឹងយាងមកគង់ក្នុងយើង ។ ធ្វើជាគ្រិស្តបរិស័ទមិនចាំបាច់ខិតខំប្រឹងកែប្រែអារម្មណ៍របស់ខ្លួនឯងឡើយ ។ ការកែប្រែអារម្មណ៍ដែលយើងបានទទួល ជាផលផ្លែនៃការបំផ្លាស់បំប្រែដែលព្រះបានធ្វើក្នុងជីវិតរបស់យើង ។ សូមមានជំនឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺព្រះគម្ពីរ មិនត្រូវជឿតាមអារម្មណ៍របស់ខ្លួនឯងឡើយ ។

## ២. តើអារម្មណ៍បែបណា ដែលជាប់ពាក់ព័ន្ធជាមួយនឹងជីវិតជាគ្រិស្តបរិស័ទ?

មានមនុស្សជាច្រើនពិតជាមានអារម្មណ៍ច្រើនដែលប្លែកខុសពីគ្នា ទាំងមុន និងបន្ទាប់ពីក្លាយជាគ្រិស្តបរិស័ទ។ អារម្មណ៍ដែលប្រាប់ពីកំហុស តែងតែមាននៅក្នុងគ្រិស្តបរិស័ទ។ នេះជាប្រតិកម្មមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបំភ្លឺរាល់អំពើបាបដែលយើងមិនទាន់បានសារភាពទៅព្រះអង្គ។

ការរំភើប ភាពសុខសាន្ត និងភាពរីករាយ ជាអារម្មណ៍ដែលតែងតែកើតមានចំពោះអស់អ្នកដែលបានក្លាយជាគ្រិស្តបរិស័ទ។ សូមពិនិត្យមើលសៀវភៅសរសេររបស់អ្នក ដែលបានកត់នៅក្នុងថ្នាក់ និង លំហាត់ទី២ស្តីអំពី "អារម្មណ៍" នៅក្នុងសៀវភៅលំហាត់ សំរាប់ចំណេះដឹងបន្ថែមនៅក្នុងមេរៀននេះ។

| | | |
|---|---|---|
| ទំនុកតម្កើង ៥១:១-២ | លូកា ១៩:៥ | យ៉ាកុប ៤:៨-១០ |
| ទំនុកតម្កើង ៣២:៥ | យ៉ូហាន ១៤:២៧ | |

## ៣. រៀនអំពីរបៀបដែលព្រះគ្រិស្តចង់អោយយើងបង្ហាញពីអារម្មណ៍របស់យើងរាល់ថ្ងៃ

ឥឡូវនេះ ប្រសិនបើព្រះយេស៊ូជាអ្នកដឹកនាំជីវិតរបស់អ្នក យើងចាំបាច់ត្រូវស្វែងយល់អំពីអារម្មណ៍ប្រភេទណា ដែលព្រះអង្គសព្វព្រះទ័យអោយយើងបញ្ចេញនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង។ ព្រះជាម្ចាស់គាប់ព្រះទ័យអោយយើងយកចិត្តទុកដាក់ជាមួយនឹងអារម្មណ៍របស់យើង។ ព្រះគម្ពីរមានចែងច្រើនណាស់អំពីការបញ្ចេញអារម្មណ៍នេះ។

### ៣.១ អនុញ្ញាតអោយព្រះយេស៊ូដឹកនាំអារម្មណ៍របស់យើង

សូមកុំអនុញ្ញាតអោយអារម្មណ៍របស់យើងគ្រប់គ្រងលើការសំរេចចិត្ត និងឥរិយាបថរបស់យើង។ មនុស្សយើងភាគច្រើនសុទ្ធតែធ្លាប់ធ្វើតាមតែអារម្មណ៍របស់ខ្លួន។ យើងព្យាយាមចៀសវាងពីអ្វីៗដែលយើងមិនចូលចិត្ត។ សំរាប់មនុស្សខ្លះវិញ កំហឹងបានគ្រប់គ្រងលើអារម្មណ៍របស់គេ។ ហើយការភ័យខ្លាចក៏ជាចៅហ្វាយដែលមានឥទ្ធិពលខ្លាំងនៅក្នុងជីវិតរបស់យើងផងដែរ។

យើងចាំបាច់ត្រូវតែមកជួបព្រះជាម្ចាស់ ហើយទូលសុំអោយព្រះអង្គដឹកនាំអារម្មណ៍របស់យើង។ យើងចង់រៀនអំពីរបៀបដែលធ្វើអោយព្រះអង្គគាប់ព្រះទ័យ តាមរយៈអារម្មណ៍របស់យើង។ យើងចាំបាច់ត្រូវមានភាពប្រាកដនិយមផងដែរ។ ប្រតិកម្មនៃអារម្មណ៍របស់យើង ជាបុគ្គលិកលក្ខណៈរបស់យើង។ ជាធម្មតា ការអធិស្ឋានទៅកាន់ព្រះ ហើយការប្តេជ្ញាខាងផ្នែកអារម្មណ៍របស់យើងចំពោះព្រះជាម្ចាស់ នឹងនាំទៅដល់ការផ្លាស់ប្រែជារៀងរហូត។

សូមស្មោះត្រង់ជាមួយនឹងការប្តេជ្ញាដែលយើងបានធ្វើជាមួយនឹងព្រះ ហើយសូមបន្តស្វែងយល់អំពីអារម្មណ៍ដែលមានចែងនៅក្នុងព្រះគម្ពីរសំរាប់យឹងអនុវត្ត។ សូមមើលតារាងខគម្ពីរដែលទាក់ទងជាមួយនឹងអារម្មណ៍ដូចជា កំហឹង ក្តីស្រឡាញ់ ការភ័យខ្លាច ភាពសុខសាន្ត ការមានអារម្មណ៍ថាមានកំហុស អំណរ ឬសុភមង្គល និងទុក្ខព្រួយជាដើម។ សូមមើលពីរបៀបដែលអ្នកអាចអនុវត្តនៅក្នុងជីវិតប្រចាំថ្ងៃ ចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់

ដែលមានបន្ទូលទៅកាន់អ្នក តើអារម្មណ៏បែបណាដែលព្រះអង្គចង់អោយយើងបញ្ចេញប្រតិកម្ម ចំពោះស្ថានការណ៏ផ្សេងៗដែលយើងជួប?

រ៉ូម ១២:១-២បានប្រាប់យើងអោយថ្វាយខ្លួនទៅព្រះជាម្ចាស់ ហើយត្រូវទុកអោយព្រះវិញ្ញាណដ៏វិសុទ្ធកែប្រែចិត្តគំនិតរបស់យើងអោយទៅជាថ្មីទាំងស្រុងវិញ។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងដឹកនាំយើងទៅតាមសេចក្តីពិត ប្រសិនបើយើងពិតជាបើកចំហរចិត្ត។

### ៣.២ រៀនសំគាល់អារម្មណ៏របស់ខ្លួនឯង

ប្រសិនបើយើងថ្វាយអារម្មណ៏របស់យើងទៅអោយព្រះយេស៊ូជាអ្នកដឹកនាំ យើងក៏ត្រូវតែព្រមទទួលស្គាល់ចំពោះអារម្មណ៏ផ្ទាល់ខ្លួនដែលយើងមាននាពេលបច្ចុប្បន្ននេះផងដែរ។ ការរៀនសំគាល់អារម្មណ៏របស់ខ្លួនឯង ជាជំហានមួយដែលមានសារៈសំខាន់ជាទីបំផុត។

ជួនកាលមានមនុស្សខ្លះភ័យខ្លាចក្នុងការចូលពិនិត្យមើលខ្លួនឯង និងអារម្មណ៏របស់ខ្លួនឯង។ គ្មានអ្វីត្រូវខ្លាចនោះទេ។ ព្រះជាម្ចាស់មានអំណាចជួយអ្នកអោយរស់ជាគ្រិស្តបរិស័ទម្នាក់ដែលមានលំនឹងក្នុងចិត្ត។ ព្រះអង្គក៏អាចបង្ហាញពីវិធី ដែលនាំអោយមានភាពចាស់ទុំខាងផ្នែកអារម្មណ៏ផងដែរ។

សូមចំណាយពេលមួយនាទី ហើយគិតដល់អារម្មណ៏ខ្លះៗ ដែលអ្នកមានក្នុងកំឡុងប៉ុន្មានថ្ងៃនេះ។ សូមគិតដល់ពេលដែលអ្នកនៅម្នាក់ឯង?

ពេលអ្នកសប្បាយរីករាយ?

ពេលទទួលភាពអាម៉ាស់?

ពេលក្រៀមក្រំ?

ពេលបាក់ទឹកចិត្ត?

ពេលខឹង?

សូមគិតដល់ ពេលដែលអ្នកមានអារម្មណ៏ភ័យខ្លាច?

មានអារម្មណ៏ថាមានកំហុស?

មានអារម្មណ៏ពេញដោយក្តីស្រឡាញ់?

មានអារម្មណ៏ថាមានភាពសុខសាន្ត?

ការស្គាល់ និងហៅអារម្មណ៏ទាំងអស់នេះអោយត្រូវតាមឈ្មោះរបស់វា ជាការសំខាន់ណាស់ក្នុងការបញ្ចេញអារម្មណ៏របស់យើង ទៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ សូមចំណាយពេលគិតដល់អារម្មណ៏របស់អ្នក ហើយព្យាយាមចាំថា តើអារម្មណ៏មួយណាដែលអ្នកមាននៅពេលនោះ។ អារម្មណ៏មិនមែនជាអំពើបាបទេ ដូច្នេះសូមកុំខ្លាច ក្នុងការមានភាពស្មោះត្រង់ចំពោះខ្លួនឯង។ ប្រសិនបើអ្នកបានខឹង សូមទទួលស្គាល់ថាបានខឹង។ អ្នកប្រហែលជាគិតថា "ខ្ញុំមិនគួរធ្វើបែបនោះទេ" ប៉ុន្តែសូមប្រឈមមុខនឹងការពិត។

សូមចាំថា ព្រះជាម្ចាស់បង្កើតយើងមកជាមួយនឹងអារម្មណ៍ ។ អារម្មណ៍មិនមែនជាអំពើបាបនោះទេ ។ យើងប្រព្រឹត្តអំពើបាប ប្រសិនបើយើងអនុញ្ញាតអោយអារម្មណ៍របស់យើង បំផ្លាញនិងធ្វើអោយអ្នកដទៃឈឺចាប់ ។ សូមអធិស្ឋានទៅព្រះជាម្ចាស់បែបនេះ "ព្រះអម្ចាស់អើយ! សូមជួយទូលបង្គំអោយចេះប្រយ័ត្នជាមួយនឹងអារម្មណ៍ខ្លួនឯង ។ ទូលបង្គំចង់បានព្រះអង្គ មិនមែនអារម្មណ៍របស់ទូលបង្គំឡើយ ដើម្បីគ្រប់គ្រងលើជីវិតនេះ" ។

## ៣.៣ រៀនបន្ធូរអារម្មណ៍តាមរយៈការអធិស្ឋាន

ជាញឹកញាប់វិធីដែលល្អបំផុតនោះគឺ ប្រាប់នរណាម្នាក់អំពីអារម្មណ៍របស់យើង ។ នៅពេលយើងបញ្ចេញវាអស់ យើងនឹងបានធូរទ្រូង ហើយមានអារម្មណ៍ប្រសើរទៀតផង ។ ជាអកុសល ពេលខ្លះយើងបញ្ចេញការបាក់ទឹកចិត្តរបស់យើងទៅអោយមិត្តភក្តិ ឬក៏អ្នកនៅក្នុងគ្រួសារ តែពួកគេបែរជាខឹងនឹងយើងទៅវិញ ។

វិធីដែលល្អជាងគេបំផុតសំរាប់បន្ធូរអារម្មណ៍នៅពេលយើងបាក់ទឹកចិត្តគឺ ទូលទៅព្រះជាម្ចាស់ ។ នេះជាវិធីល្អជាងគេបំផុត ប៉ុន្តែប្រហែលជាយើងពិបាកធ្វើ ។ មើលទៅហាក់ដូចជាមានតែម្នាក់ទេ ដែលអាចធ្វើបែបនេះបានគឺ ព្រះបាទដាវីឌនៅក្នុងសម្ពន្ធមេត្រីចាស់ ។

ប្រសិនបើយកពេលវេលាមកអានសៀវភៅទំនុកតម្កើងវិញ យើងឃើញថា ព្រះបាទដាវីឌបានប្រើពាក្យមិនល្អទៅកាន់ព្រះជាម្ចាស់ ។ ជាញឹកញាប់ព្រះបាទដាវីឌទូលសុំអោយព្រះជាម្ចាស់កំទេចសត្រូវរបស់ព្រះអង្គ ។ សូមកុំអានអំពីកំហឹងរបស់ព្រះបាទដាវីឌ ដែលព្រះអង្គបញ្ជាអោយមេទ័ពរបស់ព្រះអង្គកំទេចសត្រូវទាំងអស់នោះចោល ។

ព្រះបាទដាវីឌបានរៀនអំពី អាថ៌កំបាំងនៃការមានភាពស្មោះត្រង់ខាងផ្នែកអារម្មណ៍ជាមួយនឹងព្រះជាម្ចាស់ ។ យើងទាំងអស់គ្នាក៏អាចរៀនបានដែរ ។ ព្រះជាម្ចាស់នឹងមិនភ្ញាក់ផ្អើលជាមួយនឹងអារម្មណ៍របស់យើងឡើយ ។ ព្រះអង្គជាព្រះជាម្ចាស់ ព្រះអង្គឈ្វេងយល់គ្រប់អ្វីទាំងអស់ដែលមាននៅក្នុងយើង ។ សូមទូលព្រះអង្គអំពីអារម្មណ៍របស់អ្នក ។ បន្ទាប់មក ទូលសុំព្រះអង្គនូវក្តីស្រឡាញ់ និងភាពសុខសាន្តដែលមាននៅក្នុងព្រះអង្គ បែបនេះទើបអ្នកអាចចេញទៅ និងប្រព្រឹត្តចំពោះមនុស្សផ្សេងទៀតប្រកបដោយភាពស្រទន់ និងចិត្តសប្បុរស ។

## ៣.៤ រៀនពីរបៀបនិយាយអំពីអារម្មណ៍ខ្លួនឯងប្រាប់អ្នកដទៃ

យើងភាគច្រើនចេះនិយាយពីអារម្មណ៍របស់ខ្លួន ប្រាប់ទៅមនុស្សម្នាក់ទៀត ។ យើងតែងតែបង្ហាញពីអារម្មណ៍របស់ខ្លួនឯងតាមរយៈប្រតិកម្មរបស់យើង ។ យើងខឹង យើងស្រែក ឬក៏គ្រវែងរបស់ចោល ដូចជាសៀវភៅ ឬចាន ។ នៅពេលយើងកើតទុក្ខ យើងយំ ។ នៅពេលយើងបាក់ទឹកចិត្ត យើងបង្ហាញវាតាមរយៈឥរិយាបទរបស់យើង ។

យើងត្រូវតែរៀនប្រាប់នរណាម្នាក់អំពីអារម្មណ៍របស់យើង ។ សូមមានភាពស្មោះត្រង់ ហើយក្នុងពេលជាមួយគ្នានោះដែរ សូមបញ្ចេញអារម្មណ៍ទៅកាន់គាត់ប្រកបដោយភាពគោរព ។ ប្រសិនបើមានអារម្មណ៍ខឹងនរណាម្នាក់ សូមប្រាប់គាត់ថា: "ខ្ញុំមានអារម្មណ៍ខឹងឡើងវិញហើយ ។ តើយើងអាចបន្តការពិភាក្សា នៅពេលខ្ញុំរសាយបាត់កំ

ហឹងបានទេ?" ។ ខឹងនិងមិនខឹង សំលេងរបស់យើងមានភាពខុសគ្នា ប៉ុន្តែបើយើងហាត់និយាយអោយបានស្រួល នៅពេលដែលយើងខឹង យូរៗទៅ យើងនឹងអាចធ្វើបាន ។

ការប្រាប់មនុស្សម្នាក់ទៀតអំពីអារម្មណ៍របស់យើង យើងត្រូវតែច្បាស់ខ្លួនឯងថា យើងទទួលខុសត្រូវចំពោះអារម្មណ៍របស់យើង ។ កុំដោយសារតែអារម្មណ៍ យើងបែរជាបន្ទោសគាត់ទៅវិញ ។ គ្មាននរណាបង្ខំអោយយើងខឹងនោះឡើយ ។ ខ្លួនយើងទេតើ ដែលខឹងដោយសារមនុស្សនិយាយពីនេះពីនោះច្រើនពេក ។

សៀវភៅរបស់លោក **ចន ផូវេល** ដែលមានឈ្មោះថា <u>ហេតុអ្វីបានជាខ្ញុំភ័យក្នុងការប្រាប់អ្នកអំពីខ្លួនខ្ញុំ?</u> បានផ្តល់នូវយោបល់ល្អៗជាច្រើន ចំពោះការបញ្ចេញអារម្មណ៍ និងទំនាក់ទំនងជាមួយអ្នកដទៃ ។

## ៣.៥ រៀនបញ្ចេញអារម្មណ៍ថែមទៀត

គ្រិស្តបរិស័ទថ្មីជាច្រើនបានដឹងថា ខ្លួនឯងកំពុងស្ថិតនៅក្នុងការបំផ្លាស់បំប្រែនៃអារម្មណ៍ បន្ទាប់ពីបានក្លាយជាគ្រិស្តបរិស័ទ ។ អ្នកចាំបាច់ត្រូវមានការប្រុងប្រយ័ត្នចំពោះការរីកចំរើន និងការបញ្ចេញអារម្មណ៍ទាំងអស់នោះ បែបនេះទើបអ្នកអាចបំរើព្រះជាម្ចាស់បានល្អជាងមុន ។ អារម្មណ៍មួយដែលព្រះជាម្ចាស់មានបន្ទូលសន្យាជាមួយយើងគឺ សេចក្តីសុខសាន្ត ។

**យ៉ូហាន ១៤:២៧**

**ខ្ញុំទុកសេចក្តីសុខសាន្តអោយអ្នករាល់គ្នា ខ្ញុំផ្តល់សេចក្តីសុខសាន្តរបស់ខ្ញុំអោយអ្នករាល់គ្នា។ សេចក្តីសុខសាន្តដែលខ្ញុំផ្តល់អោយនេះ មិនសេចក្តីសុខសាន្តដែលមនុស្សលោកអោយទេ។ ចូរកុំរន្ធត់ចិត្ត កុំភ័យខ្លាចអោយសោះ។**

នេះជាបន្ទូលដែលព្រះយេស៊ូបានសន្យាជាមួយយើង ។ យើងអាចមានបទពិសោធន៍ជាមួយនឹងសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់នៅក្នុងចិត្ត ទោះជាមានបញ្ហាជាច្រើនកើតមាននៅជុំវិញយើងក៏ដោយ ។

ប៉ុន្តែអារម្មណ៍ខ្លះអាចធ្វើអោយយើងបែកចេញពីសេចក្តីសុខសាន្តនេះ ។ ប្រសិនបើអ្នកខឹង ឬអនុញ្ញាតអោយភាពភ័យខ្លាច និងភាពខ្វល់ខ្វាយចូលមកក្នុងគំនិត មិនយូរទេ អ្នកនឹងលែងមានសេចក្តីខុសសាន្តរបស់ព្រះជាម្ចាស់នៅក្នុងជីវិត ។ ហេតុនេះហើយបានជាអ្នកត្រូវតែរៀនបញ្ចេញអារម្មណ៍របស់ខ្លួនថែមទៀត ។ សូមរៀនបញ្ចេញនូវសេចក្តីសុខសាន្ត និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ។ វាចំណាយពេលមួយជីវិត ដើម្បីទទួលនូវការរីកចំរើនក្នុងការបញ្ចេញសេចក្តីសុខសាន្ត និងក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ប៉ុន្តែវាជាគោលដៅដ៏មានតំលៃជាទីបំផុតសំរាប់ជីវិតរបស់យើង ។

នៅពេលអ្នកកំពុងតែខឹងនរណាម្នាក់ សូមព្យាយាមបញ្ចេញមកវិញនូវ ភាពសោកសៅ ឬ សេចក្តីអាណិតអាសូរ ឬសេចក្តីស្រឡាញ់ទៅម្នាក់នោះវិញ ។ បែបនេះអ្នកនឹងអាចឃើញថា ប្រតិកម្មដែលយើងបញ្ចេញទៅគេអាចជាបច្ច័យល្អសំរាប់ជីវិតជាគ្រិស្តបរិស័ទរបស់យើង ។ ចំនុចដែលសំខាន់ជាងគេគឺ ត្រូវនឹកដល់ព្រះគ្រិស្តមុនគេបង្អស់ បែបនេះព្រះអង្គនឹងដឹកនាំយើងអោយយល់ពីសេចក្តីពិតរបស់ព្រះអង្គ ។

## ៣.៦ សូមប្រយ័ត្នជាមួយនឹងគ្រិស្តបរិស័ទដែលធ្វើតាមតែអារម្មណ៍

គ្រិស្តបរិស័ទខ្លះតែងយល់ច្រឡំអំពីជីវិតថ្មី ដែលពួកគេសង្កត់ធ្ងន់តែទៅលើ "អារម្មណ៍ល្អដែលព្រះជាម្ចាស់ប្រទានអោយគេ"។ ពួកគេបានបង្រៀនថា យើងអាចមាន "អារម្មណ៍ល្អជាមួយនឹងព្រះយេស៊ូ"។ ប្រសិនបើអ្នកក្លាយជាគ្រិស្តបរិស័ទហើយប្រតិបត្តិតាមសេចក្តីបង្រៀនរបស់ព្រះអង្គ អ្នកនឹងតែងតែមានអំណរ សេចក្តីសុខសាន្ត និងអារម្មណ៍ល្អៗជាច្រើនទៀតដែលមាននៅក្នុង "ជីវិតថ្មីហើយល្អនេះ"។

សូមកុំធ្លាក់ទៅក្នុងអន្ទាក់នៃអារម្មណ៍ល្អទាំងអស់នោះ។ ជាការពិតណាស់ ដែលព្រះជាម្ចាស់ចង់អោយយើងមានបទពិសោធន៍ជាមួយនឹងអំណរ និងសេចក្តីសុខសាន្តដែលមាននៅក្នុងការសង្គ្រោះរបស់ព្រះអង្គ។ ប៉ុន្តែ ទាំងនេះសុទ្ធតែជាផលដែលបានមកពីការសង្គ្រោះដ៏ពិត។ យើងចាំបាច់ត្រូវស្វែងយល់អោយច្បាស់អំពីព្រះជាម្ចាស់ មិនមែនស្វែងរកតែអារម្មណ៍ល្អនោះទេ។ ស្គាល់ព្រះអង្គកាន់តែច្បាស់ យើងក៏កាន់តែស្គាល់វិធីជាច្រើនថែមទៀត ដែលធ្វើអោយយើងកាន់តែមានភាពរីករាយជាមួយនឹងសេចក្តីស្រឡាញ់ សេចក្តីសុខសាន្ត និងអំណររបស់ព្រះអង្គ។

ទោះជាគ្រិស្តបរិស័ទដែលល្អជាងគេនៅក្នុងលោក ក៏មានពេលធ្លាក់ចុះ បាក់ទឹកចិត្ត និងមានអារម្មណ៍ឯកាដែរ។ គេបាក់ទឹកចិត្តម្តងហើយម្តងទៀត។ យើងត្រូវតែចងចាំថា ទោះជាមានអារម្មណ៍បែបណាក៏ដោយ ព្រះជាម្ចាស់គង់នៅជាមួយយើងជានិច្ច ហើយព្រះអង្គមានបន្ទូលសន្យាថា ទ្រង់នឹងមិនបោះបង់យើងចោលម្តងណាឡើយ។

ហេតុអ្វីបានជាអារម្មណ៍ល្អឆាប់ចាកចេញពីយើង ក្រោយពីពេលយើងក្លាយជាគ្រិស្តបរិស័ទ? ឬក៏ប្រហែលជាអារម្មណ៍ល្អទាំងនោះ មិនត្រឡប់មកក្នុងជីវិតរបស់យើងវិញជារៀងរហូត។ សូមកុំភ្ញាក់ផ្អើល ប្រសិនបើយើងជួបនូវហេតុការណ៍បែបនេះ។ ព្រះជាម្ចាស់មិនដែលមានបន្ទូលសន្យាថា បើអ្នកក្លាយជាគ្រិស្តបរិស័ទ អារម្មណ៍របស់អ្នកនឹងខុសពីមុនទាំងស្រុងនោះឡើយ។ ព្រះអង្គមានព្រះបន្ទូលថា អ្នកនឹងអាចផ្លាស់ប្រែខុសពីមុន នេះទើបជាអត្ថន័យពិត។ ២កូរិនថូស ៥:១៧បានចែងថា ប្រសិនបើអ្នកណានៅរួមជាមួយព្រះគ្រិស្ត អ្នកនោះបានកើតជាថ្មី (ជាមនុស្សថ្មី)។ ខគម្ពីរនេះមិនបានប្រាប់ថា យើងនឹងមាន "អារម្មណ៍"ដូចជាមនុស្សថ្មីនោះឡើយ។

ជួនកាលព្រះជាម្ចាស់ដាក់ការសាកល្បងមួយនៅក្នុងយើង ដើម្បីអោយយើងមានការរីកចំរើន។ ជួនកាល ព្រះអង្គដកអារម្មណ៍ល្អទាំងនោះចេញ ដើម្បីបង្រៀនយើងកុំអោយពឹងទៅលើអារម្មណ៍ទាំងអស់នោះ។ ព្រះអង្គចង់អោយយើងឈរយ៉ាងរឹងមាំចំពោះការថ្វាយខ្លួនរបស់យើងទៅកាន់ព្រះអង្គ ទោះជាយើងគ្មានអារម្មណ៍ពីព្រះវត្តមាន សេចក្តីស្រឡាញ់ និងសេចក្តីសុខសាន្តរបស់ទ្រង់ក៏ដោយ។ ប្រសិនបើយើងនឹងដល់ព្រះអង្គមុនអ្វីៗបង្អស់ យើងនឹងអាចដឹងថា សេចក្តីសុខសាន្ត អំណរ សេចក្តីស្រឡាញ់ និងអារម្មណ៍ផ្សេងៗទៀត ដែលព្រះអង្គបញ្ជូនមក គឺមានភាពប្រសើរជាងរាល់អារម្មណ៍ដែលបានមកពីមារសាតាំងឆ្ងាយណាស់។

# ជំពូកទី២

## តើកន្លែងណាដែលខ្ញុំអាចមើលឃើញភស្តុតាងដែលបញ្ជាក់ថា ខ្ញុំជាគ្រិស្តបរិស័ទ?

នៅពេលដែលមនុស្សម្នាក់បានសំរេចចិត្តធ្វើជាគ្រិស្តបរិស័ទ តើគាត់ដឹងដោយរបៀបណាថា គាត់ជាគ្រិស្តបរិស័ទ? តើមានភស្តុតាងអ្វីខ្លះ ដែលបង្ហាញថាអ្នកជាគ្រិស្តបរិស័ទ? តើយើងគួរមើលកន្លែងណា? នៅពេលដែលមារសាតាំងដាក់ភាពសង្ស័យមកក្នុងគំនិតយើង តើយើងអាចចង្អុលចំនុចណាខ្លះ ដែលជាភស្តុតាងបញ្ជាក់ថាយើងជាគ្រិស្តបរិស័ទ?

ការផ្លាស់ប្រែដែលគួរអោយកត់សំគាល់នឹងកើតមានឡើង នៅក្នុងមនុស្សដែលបានក្លាយជាគ្រិស្តបរិស័ទ។ ការផ្លាស់ប្រែខ្លះចំណាយរយៈពេលខ្លី ហើយចំណែកការផ្លាស់ប្រែខ្លះទៀតមានរយៈពេលយូរ។ ប៉ុន្តែគ្រិស្តបរិស័ទថ្មីម្នាក់ៗគួរតែអាចចង្អុលបង្ហាញនូវភស្តុតាងខ្លះៗ ដែលព្រះយេស៊ូបានបំផ្លាស់ប្រែជីវិតរបស់ពួកគេ។

គ្រិស្តបរិស័ទថ្មីក៏អាចមើលក្នុងព្រះគម្ពីរ និងព្រះវិញ្ញាណដ៏វិសុទ្ធដែលអាចផ្តល់នូវភស្តុតាងបញ្ជាក់ថា គាត់ជាគ្រិស្តបរិស័ទ។ យើងនឹងសិក្សាលំអិតអំពីចំនុចខ្លះៗដែលអាចប្រើសំរាប់បង្ហាញថា មនុស្សម្នាក់ជាគ្រិស្តបរិស័ទ ឬមិនមែនជាគ្រិស្តបរិស័ទ។

### ក.ព្រះគម្ពីរ

ព្រះគម្ពីរជាសៀវភៅពិសេសរបស់គ្រិស្តបរិស័ទ។ ព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់មកកាន់យើងតាមរយៈព្រះគម្ពីរ ហើយបានបង្រៀនយើងយ៉ាងច្បាស់អំពី របៀបរស់នៅរបស់យើងដែលគាប់ព្រះទ័យរបស់ព្រះអង្គ។ គំរោងការណ៍របស់ព្រះជាម្ចាស់សំរាប់យើង មានភាពសាមញ្ញ ហើយសូម្បីតែកុមារក៏អាចគោរពការបង្រៀនរបស់ទ្រង់ ហើយក្លាយជាគ្រិស្តបរិស័ទបានដែរ។

**១. ព្រះគម្ពីរមានសេចក្តីពិតដែលប្រាប់យើងអំពីរបៀបក្លាយជាគ្រិស្តបរិស័ទ**

សេចក្តីពិតទាំងនេះមានរៀបរាប់នៅក្នុងជំពូកទី១រួចហើយ។ សូមអាន ១យ៉ូហាន៥:៩-១៣ និង រ៉ូម១០:៩-១២។ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដែលគ្រិស្តបរិស័ទថ្មីគួរតែអានព្រះគម្ពីរ និងលឺព្រះបន្ទូលរបស់ព្រះអង្គចេញពីសៀវភៅរបស់ព្រះអង្គផ្ទាល់។ សូមកុំពឹងផ្អែកលើអ្នកដទៃផ្សេងទៀត ប្រាប់អ្នកអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ សូមអានដោយខ្លួនឯង ហើយសុំអោយព្រះវិញ្ញាណដ៏វិសុទ្ធជួយអ្នកអោយយល់ពីសេចក្តីពិតរបស់ព្រះជាម្ចាស់។

នៅពេលអានព្រះគម្ពីរ ជាការសំខាន់ណាស់ដែលអ្នកយល់ត្រូវ ចំពោះអត្ថន័យដែលមាននៅក្នុងព្រះគម្ពីរ។ បើអ្នកអានតែចំនុចដ៏តូចមួយ អ្នកអាចយល់ខុសអំពីអត្ថន័យដែលមាននៅក្នុងជំពូកទាំងមូលបាន។ ឧទាហរណ៍ដូចជានៅក្នុងព្រះគម្ពីរបានចែងថា "គ្មានព្រះជាម្ចាស់ទាល់តែសោះ"។ បែបនេះ វាផ្ទុយជាមួយនឹងខគម្ពីររាប់រយទៀត

នៅក្នុងព្រះគម្ពីរ ដែលចែងថា "ពិតជាមានព្រះជាម្ចាស់" ។ ទោះយ៉ាងណាក៏ដោយ នៅក្នុងសៀវភៅទំនុកតម្កើង ១៤:១ បានចែងថា "មនុស្សល្ងីល្ងើគិតក្នុងចិត្តថា គ្មានព្រះជាម្ចាស់ទាល់តែសោះ!" ។ សូមអានព្រះគម្ពីរ ហើយសូមប្រាកដថាអ្នកយល់ពីអត្ថន័យនៃខគម្ពីរទាំងមូល ។

សូមចំណាយពេលស្វែងរកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលព្រះអង្គមានបន្ទូលអំពីរបៀបដែលយើងអាចក្លាយជាកូនដ៏ពិសេសរបស់ព្រះអង្គ ។ សូមសរសេរខគម្ពីរទាំងនោះនៅលើក្រដាស់មួយ ហើយនៅពេលដែលយើងមានភាពសង្ស័យអំពីជំនឿរបស់យើងដែលជាគ្រិស្តបរិស័ទ យើងអាចអានខគម្ពីរទាំងនោះដែលជាភស្តុតាងបញ្ជាក់ថាយើងពិតជាគ្រិស្តបរិស័ទ ។

## ២. យើងត្រូវតែប្រតិបត្តិតាមសេចក្តីបង្រៀនដែលមាននៅក្នុងព្រះគម្ពីរ

ប្រសិនបើអ្នកចង់ក្លាយជាគ្រិស្តបរិស័ទ អ្នកត្រូវតែធ្វើអោយលើសពីសេចក្តីពន្យល់នៃសេចក្តីពិតទាំងប៉ុន្មានដែលប្រាប់អំពីរបៀបក្លាយជាគ្រិស្តបរិស័ទ ។ អ្នកត្រូវតែប្រតិបត្តិតាមសេចក្តីពិតទាំងនេះ ។ អ្នកនឹងមានសេចក្តីសុខសាន្តនៅក្នុងចិត្តគំនិត ចំពោះភាពជាគ្រិស្តបរិស័ទរបស់អ្នក ។

ចំណេះដឹងចេញពីព្រះគម្ពីរ ដែលប្រាប់អំពីរបៀបក្លាយជាគ្រិស្តបរិស័ទ មិនអាចផ្តល់នូវភស្តុតាងដែលបញ្ជាក់ថា អ្នកជាគ្រិស្តបរិស័ទនោះឡើយ ។ តែបើអ្នកនិយាយថា "ខ្ញុំប្រតិបត្តិតាមព្រះគម្ពីរ" នោះអ្នកនឹងមានទំនុកចិត្តថាអ្នកជាកូនរបស់ព្រះជាម្ចាស់ ។ សូមអាន យ៉ាកុប ១:១៩-២៧ ។

នៅពេលយើងគោរពនិងប្រតិបត្តិតាមសេចក្តីបង្រៀនរបស់ព្រះជាម្ចាស់ យើងបង្កើតនូវភស្តុតាងផ្ទាល់ខ្លួនដែលបញ្ជាក់ថាយើងជាគ្រិស្តបរិស័ទ ។ ប្រសិនបើមាននរណាម្នាក់ចង់អោយយើងបញ្ជាក់ថា យើងជាគ្រិស្តបរិស័ទ យើងអាចប្រើហេតុផលទាំងនោះ ដើម្បីបង្ហាញពីសេចក្តីពិតដែលមាននៅក្នុងព្រះគម្ពីរ ។ ប្រសិនបើយើងអាចចង្អុលបង្ហាញសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរ ដែលយើងប្រតិបត្តិតាម និងចេញជាផ្លែផ្កានោះ ការអះអាងរបស់យើងទៅកាន់អ្នកដទៃផ្សេងទៀត នឹងរឹតតែមានប្រសិទ្ធិភាពថែមទៀត ។

## ៣. សេចក្តីពិតនៅក្នុងព្រះគម្ពីរមិនប្រែប្រួលឡើយ

ព្រះគម្ពីរជាគម្ពីរបុរាណមួយក្បាល ។ សៀវភៅទីមួយនៅក្នុងព្រះគម្ពីរ បានសរសេរឡើងប្រហែលជាជាង៤០០០ឆ្នាំកន្លងមកហើយ ។ ហើយសៀវភៅចុងក្រោយរបស់ព្រះគម្ពីរបានសរសេរឡើងប្រហែលជាជាង២០០០ឆ្នាំមុន ។ តើគម្ពីរបុរាណមួយនេះអាចយកមកធ្វើជាភស្តុតាង ដើម្បីបញ្ជាក់ថាមនុស្សម្នាក់ជាគ្រិសបរិស័ទបានទេ? បាន! យើងអាចមានទំនុកចិត្តចំពោះព្រះគម្ពីរនាពេលបច្ចុប្បន្ន ជាគម្ពីរដែលមានភាពត្រឹមត្រូវតាមសំណៅដើមទាំងស្រុង ។ មានសំណៅចំលងចាស់៧រាប់ពាន់ នៃសៀវភៅទាំងឡាយនៅក្នុងព្រះគម្ពីរ ។ សំណៅខ្លះបានចំលងឡើងប្រហែលជា ២០០ឆ្នាំ ឬ៣០០ឆ្នាំបន្ទាប់ពីសំណៅដើម ។

ហេតុផលមួយទៀតដែលធ្វើអោយយើងមានទំនុកចិត្តចំពោះព្រះគម្ពីរនោះគឺ ព្រះបន្ទូលរបស់ព្រះយេស៊ូចំពោះព្រះគម្ពីរ។ សូមអាន ម៉ាថាយ៧:១៧-១៩ ម៉ាថាយ២៤:៣៥ និង លូកា១៦:១៧។ ព្រះយេស៊ូបានមានព្រះបន្ទូលយ៉ាងច្បាស់ថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់នឹងមិនផ្លាស់ប្តូរឡើយ។ សេចក្តីពិតសំរាប់មនុស្សកាលពី២០០០ឆ្នាំមុនក៏សំរាប់យើងនាពេលបច្ចុប្បន្ននេះដែរ។

**២ធីម៉ូថេ ២:១៩**

**ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ គ្រឹះដ៏រឹងមាំដែលព្រះជាម្ចាស់បានចាក់នោះនៅតែស្ថិតស្ថេររឹងប៉ឹងដដែល ហើយនៅលើគ្រឹះនោះមានចារឹកពាក្យជាសញ្ញាសំគាល់ថា: "ព្រះអម្ចាស់ស្គាល់កូនចៅរបស់ព្រះអង្គ" ហើយ "អ្នកណាប្រកាសខ្លួនគោរពព្រះនាមព្រះអម្ចាស់ អ្នកនោះត្រូវតែងាកចេញអោយផុតពីអំពើទុច្ចរិត"។**

ចំនុចមួយទៀតដែលធ្វើអោយយើងមានទំនុកចិត្តជាមួយនឹងព្រះគម្ពីរគឺ ព្រះបន្ទូលសន្យាដែលមាននៅក្នុងនោះ។ បើយើងអនុវត្តតាមព្រះបន្ទូលសន្យាទាំងនោះ ព្រះជាម្ចាស់នឹងបង្ហាញអង្គទ្រង់នៅក្នុងជីវិតយើងម្តងហើយម្តងទៀត។ យើងត្រូវតែរៀនអំពីវិធីមានជំនឿលើព្រះជាម្ចាស់ ទោះជាយើងមិនទាន់ឃើញលទ្ធផលលេចចេញភ្លាមៗក៏ដោយ។

មានភស្តុតាងជាច្រើន ដែលបញ្ជាក់ថា ព្រះគម្ពីរនាពេលបច្ចុប្បន្នជា ជាគម្ពីរដែលមានភាពត្រឹមត្រូវតាមសំណៅដើម ដែលបានសសេរឡើងកាលពីរាប់ពាន់ឆ្នាំមុន។ សូមអានសៀវភៅសំរាប់សិស្ស ដែលមានចំណងជើងថា គ្រិស្តបរិស័ទថ្មី និងអានព្រះគម្ពីរ ដើម្បីទទួលចំណេះដឹងបន្ថែមស្តីអំពីភស្តុតាង ដែលបញ្ជាក់ថាព្រះគម្ពីរនាពេលបច្ចុប្បន្នមានភាពត្រឹមត្រូវតាមសំណៅដើម។ បែបនេះទើបយើងមិនខ្លាចថា ព្រះគម្ពីរមានការកែប្រែ ឬក៏គន្លឹះសំខាន់នៃសេចក្តីបង្រៀននៅក្នុងនោះមានការបាត់បង់។ គម្ពីរគ្រិស្តបរិស័ទត្រូវបានគេស្គាល់ថា ជាគម្ពីរដែលត្រឹមត្រូវតាមសំណៅដើម ហើយព្រះបន្ទូលសន្យាដ៏ពិតរបស់ព្រះជាម្ចាស់ក៏មាននៅក្នុងនោះដែរ។

## ខ. ព្រះវិញ្ញាណដ៏វិសុទ្ធ

ព្រះជាម្ចាស់ប្រទានព្រះគម្ពីរមកអោយយើង ហើយព្រះគម្ពីរជាប្រភពនៃភស្តុតាងដែលបញ្ជាក់ថា យើងជាគ្រិស្តបរិស័ទ។ ព្រះអង្គក៏ប្រទានព្រះវិញ្ញាណបរិសុទ្ធមកអោយយើងផងដែរ ដើម្បីទុកជាភស្តុតាងមួយផ្សេងទៀតដែលបញ្ជាក់ថាយើងជាគ្រិស្តបរិស័ទ។ មនុស្សគ្រប់រូបអាចអានព្រះគម្ពីរបាន ហើយសេចក្តីពិតមានចែងច្បាស់នៅក្នុងនោះ។ ប៉ុន្តែព្រះវិញ្ញាណដ៏វិសុទ្ធគឺជាព្រះជាម្ចាស់។ យើងមិនអាចមើលឃើញព្រះអង្គទេ ប៉ុន្តែយើងអាចឃើញពីភស្តុតាង ដែលព្រះអង្គបញ្ជាក់ថាយើងជាគ្រិស្តបរិស័ទ។ ព្រះគម្ពីរប្រាប់យើងអំពី របៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញភស្តុតាង ដែលបញ្ជាក់ថាយើងជាគ្រិស្តបរិស័ទ។

### ១. ព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមក ហើយគង់នៅក្នុងយើង

ព្រះបន្ទូលសន្យាមួយដែលបានចែងនៅក្នុងព្រះគម្ពីរជាញឹកញាប់នោះគឺ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមក ហើយគង់នៅក្នុងមនុស្សណា ដែលបានក្លាយជាគ្រិស្តបរិស័ទ។ ប្រសិនបើអ្នកជឿថាព្រះគម្ពីរជាសេចក្តីពិត អ្នកត្រូវតែព្រមទទួលសេចក្តីពិតនេះ។ ប្រសិនបើអ្នកបានអធិស្ឋានសុំព្រះជាម្ចាស់ធ្វើជាគ្រិស្តបរិស័ទរួចហើយ ឥឡូវនេះ ព្រះវិញ្ញាណដ៏វិសុទ្ធកំពុងតែគង់នៅក្នុងវិញ្ញាណអ្នក។ ប្រហែលជាអារម្មណ៍របស់អ្នកនៅតែដដែល ប៉ុន្តែសេចក្តីពិតនៅតែជាការពិត។

**២ កូរិនថូស ១:២១-២២**

**គឺព្រះជាម្ចាស់ហើយ ដែលប្រទានអោយយើង និងបងប្អូនមានជំនឿខ្ជាប់ខ្ជួនលើព្រះគ្រិស្ត ព្រមទាំងបានចាក់ប្រេងលើយើងផង ហើយព្រះអង្គក៏បានដៅសញ្ញាសំគាល់របស់ព្រះអង្គលើយើង និងប្រទានព្រះវិញ្ញាណមកបញ្ចាំចិត្តយើងផងដែរ។**

អេភេសូ ១:១៣-១៤ បានបញ្ជាក់ច្បាស់ថា ព្រះជាម្ចាស់ដាក់សញ្ញាដៅសំគាល់នៅលើយើង ដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកបញ្ចាំចិត្តយើង។ "ព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណនេះ មកបញ្ចាំចិត្តយើងអោយដឹងថា យើងនឹងទទួលមត៌ក..."។ យើងអាចប្រឈមមុខនឹងអនាគតដោយមានទំនុកចិត្តថា ព្រះជាម្ចាស់នឹងតាមថែរក្សា និង ការពារយើងជានិច្ច ទោះជាមានអ្វីកើតឡើងនៅក្នុងជីវិតរបស់យើងក៏ដោយ។ សូមអាន កាឡាទី ៤:៦-៧ និង ១យ៉ូហាន ៣:២៤។

### ២. ព្រះវិញ្ញាណដ៏វិសុទ្ធនឹងធ្វើជាគ្រូរបស់យើង

ហេតុអ្វីបានជាព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ហើយគង់នៅក្នុងយើង បន្ទាប់ពីយើងបានក្លាយជាគ្រិស្តបរិស័ទ? ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកគង់នៅក្នុងជីវិតយើង គឺជាការទទួលខុសត្រូវរបស់ព្រះអង្គដែលទទួលមកពីព្រះបិតា។ ព្រះអង្គយាងមកជួយ ដឹកនាំ បង្រៀន និងកំសាន្តចិត្តយើង។ ព្រះវិញ្ញាណដ៏វិសុទ្ធមិនបានគង់នៅលើបល្ល័ង្កឆ្ងាយរាប់លានគីឡូម៉ែត្រ ហើយបន្លឺសំឡេងចុះមក ដើម្បីអោយយើងប្រតិបត្តិតាមវិន័យរបស់ទ្រង់នោះឡើយ។ ព្រះអង្គគង់នៅក្នុងយើង ហើយឈ្វេងយល់គ្រប់អ្វីៗដែលកើតមានឡើងជារៀងរាល់ថ្ងៃនៅក្នុងជីវិតយើង។

ប្រសិនបើយើងចង់ធ្វើជាគ្រិស្តបរិស័ទម្នាក់ដែលមានជោគជ័យ ហើយឈ្នះលើការល្បួង និងបញ្ហាទាំងឡាយដែលនឹងកើតមានឡើងនៅក្នុងជីវិត យើងចាំបាច់ត្រូវតែទទួលការជំនួយពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធបានត្រៀមព្រះទ័យជាស្រេចដើម្បីជួយកំសាន្តចិត្តយើង លើកទឹកចិត្តយើង ចាំប្រាប់យើងរាល់អំពើបាបដែលយើងប្រព្រឹត្ត បង្រៀនយើងនៅពេលយើងអានព្រះគម្ពីរ និងនៅមានកិច្ចការជាច្រើនទៀតដែលព្រះអង្គនឹងនៅចាំជួយយើង។ យើងចាំបាច់ត្រូវរៀននិយាយទៅកាន់ព្រះអង្គជារៀងរាល់ថ្ងៃ។ នៅក្នុងគំនិតរបស់យើង ចូរប្រាប់ខ្លួនឯងថា ព្រះអង្គគង់នៅក្នុងខ្ញុំ។ នៅពេលជួបនូវបញ្ហាផ្សេងៗ សូមទូលទៅព្រះអង្គ។

## ៣. ព្រះអង្គអាចមានបន្ទូលមកយើង និងប្រាប់ថា យើងជាគ្រិស្តបរិស័ទ

ព្រះជាម្ចាស់មិននៅស្ងាត់ស្ងៀមឡើយ។ រ៉ូម ៨:១៦ បានចែងថា ព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលមកកាន់អស់អ្នកដែលជាគ្រិស្តបរិស័ទ។

**រ៉ូម ៨:១៦**

**គឺព្រះវិញ្ញាណផ្ទាល់ដែលផ្ដល់សក្ខីភាពដោយវិញ្ញាណរបស់យើងដឹងថា យើងពិតជាបុត្ររបស់ព្រះជាម្ចាស់មែន។**

ព្រះបន្ទូលសន្យាដូចគ្នានេះមានចែងនៅក្នុង ១ថេស្សាឡូនិក ១:៥ និង យ៉ូហាន ១៤:១៧។ ប្រសិនបើអ្នកជាគ្រិស្តបរិស័ទ អ្នកនឹងអាចលឺព្រះវិញ្ញាណមានបន្ទូលមកអ្នកថា អ្នកជាកូនរបស់ព្រះអង្គ។ ប៉ុន្តែ តើព្រះវិញ្ញាណមានបន្ទូលមកកាន់យើងយ៉ាងម៉េចទៅ? តើយើងរំពឹងថាបានឮអ្វីពីព្រះអង្គ?

រ៉ូម ៨:១៦ បានចែងថា ព្រះវិញ្ញាណផ្ទាល់ដែលផ្ដល់សក្ខីភាពនៅក្នុងជំរៅចិត្តរបស់យើង។ សូមកុំស្ដាប់សំលេងខ្លាំងៗដែលនិយាយចេញពីមេឃថា "នេះជាព្រះវិញ្ញាណដ៏វិសុទ្ធ និយាយមកកាន់អ្នក សូមស្ដាប់ចុះ!"។ យើងនឹងមានទំនុកចិត្តថា បទពិសោធន៍ដែលយើងបានជួបប្រទះ ជាការពិត។ ជាញឹកញាប់ព្រះវិញ្ញាណមានបន្ទូលមកកាន់យើង តាមរយៈមនសិការរបស់យើង។ យើងគួរតែរៀនពីរបៀបស្ដាប់សំលេងរបស់ព្រះជាម្ចាស់ ទើបយើងអាចស្ដាប់ឮព្រះអង្គមានបន្ទូលមកកាន់យើង។

## ៤. តើមនុស្សម្នាក់អាចមានភាពងាយស្រួលក្នុងការស្ដាប់ឮសំលេងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដោយរបៀបណា?

នៅពេលយើងបើកទូរទស្សន៍ យើងនឹងឃើញរូបភាពនិងឮសំលេង ដែលស្ថានីយ៍ទូរទស្សន៍បានផ្សាយតាមរលកធាតុអាកាស។ រលកសញ្ញាទាំងនោះបានចូលមកក្នុងបន្ទប់ មុនពេលយើងបើកទូរទស្សន៍ទៅទៀត។ ប៉ុន្តែត្រចៀករបស់យើងមិនអាចស្ដាប់ឮរលកសញ្ញាទាំងនោះឡើយ។ ទូរទស្សន៍របស់យើងអាចមានលទ្ធភាពចាប់យករលកសញ្ញាដែលមើលមិនឃើញទាំងអស់នោះបាន ហើយបំលែងមកជារូបភាពនិងសំលេង ដែលភ្នែកយើងអាចមើលឃើញ និងត្រចៀកយើងអាចស្ដាប់ឮ។

មនុស្សខ្លះនិយាយថា "ខ្ញុំមិនដែលឮព្រះជាម្ចាស់មានបន្ទូលមកកាន់ខ្ញុំម្ដងណាឡើយ។ ខ្ញុំមិនជឿទេថា ព្រះជាម្ចាស់មានបន្ទូលមកកាន់មនុស្ស"។ យើងមិនអាចឮព្រះបន្ទូលរបស់ព្រះអង្គ គឺដូចគ្នានឹងរលកសញ្ញាទូរទស្សន៍ដែលនៅជុំវិញខ្លួនយើង ទាល់តែមានទូរទស្សន៍ទើបយើងអាចស្ដាប់ឮ។

តើព្រះវិញ្ញាណមានបន្ទូលទៅកាន់កូនរបស់ព្រះអង្គដោយរបៀបណា? តើយើងដឹងថាព្រះជាម្ចាស់មានបន្ទូលមកកាន់យើងដោយរបៀបណា? មានគ្រិស្តបរិស័ទម្នាក់ពិពណ៌នាថា "ព្រះវិញ្ញាណមានបន្ទូលមកកាន់ខ្ញុំ តាមរយៈមនសិការរបស់ខ្ញុំ។ ខ្ញុំដឹងថា នោះជាព្រះវិញ្ញាណ ដោយសារខ្ញុំមិនអាចដោះសារចំពោះកំហុសរបស់ខ្ញុំបាន។ មនសិការរបស់ខ្ញុំបានប្រាប់ខ្ញុំថា ទាល់តែសារភាពអំពើបាបទៅព្រះជាម្ចាស់ និងទទួលការលើកលែងទោស

ទើបជាវិធីល្អ ។ ខ្ញុំក៏មានអារម្មណ៍អំពីភាពសុខសាន្តរបស់ព្រះអង្គនៅក្នុងចិត្តផងដែរ ។ នៅពេលខ្ញុំគិតអំពី សេចក្តីស្លាប់ និងជីវិតបន្ទាប់ពីសេចក្តីស្លាប់ ខ្ញុំពិតជាមានភាពសុខសាន្តដ៏ពិត ព្រោះខ្ញុំនឹងបាននៅជាមួយនឹងព្រះជាម្ចាស់" ។

មានគ្រិស្តបរិស័ទម្នាក់ទៀតនិយាយថា "ខ្ញុំមិនបានឮសំឡេងអ្វីទាំងអស់ ប៉ុន្តែកាលណាព្រះវិញ្ញាណមានបន្ទូលមកកាន់ខ្ញុំ ខ្ញុំដឹង ។ មានគំនិតមួយចូលមកក្នុងខ្ញុំ ។ ខ្ញុំមិនអាចប្រឆាំងនឹងគំនិតនោះបាន ។ ខ្ញុំតែងតែធ្វើការសាកល្បង មុនពេលជឿថា គំនិតនេះមកពីព្រះវិញ្ញាណ ។ ប្រសិនបើវាដើរស្របជាមួយនឹងព្រះគម្ពីរ ទើបខ្ញុំអាចទទួលយកបាន ។ ប្រសិនបើវាផ្ទុយពីព្រះគម្ពីរ ខ្ញុំមិនអាចទទួលយកបានឡើយ ព្រោះនេះមិនមែនជាព្រះបន្ទូលរបស់ព្រះវិញ្ញាណនោះឡើយ" ។

បទពិសោធន៍របស់គ្រិស្តបរិស័ទទី២នេះ មានភាពស្មុគស្មាញណាស់ ។ យើងទាំងអស់គ្នាសុទ្ធតែមានគំនិតជាច្រើន បានចូលមកក្នុងគំនិតរបស់យើង ។ តើគំនិតមួយណាដែលមកពីព្រះជាម្ចាស់? តាមពិត យើងអាចដឹងដោយស្ម័យប្រវត្តិចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ ខាងក្រោមនេះជាគំនិតខ្លះៗដែលជាជំនួយដល់អ្នក ។

១. ពិនិត្យជាមួយនឹងព្រះគម្ពីរ ។ ប្រសិនបើវាផ្ទុយជាមួយនឹងសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរ នោះយើងអាចដឹងច្បាស់ថា គំនិតនោះមិនមែនមកពីព្រះជាម្ចាស់ទេ ។

២. និយាយទៅកាន់ព្រះជាម្ចាស់ ហើយព្យាយាមស្តាប់ព្រះសូរសៀងរបស់ព្រះអង្គ ។ ព្រះអង្គនឹងមិនពិរោធ នៅពេលដែលយើងមកស្វែងរកការពិតនោះឡើយ ។ ប្រសិនបើព្រះគម្ពីរបានចែងថា យើងគួរតែធ្វើកិច្ចការមួយចំនួន (ដូចជាចុះចូលជាមួយអ្នកដឹកនាំ) សូមធ្វើចុះ ។ យើងមិនចាំបាច់អធិស្ឋានសួរព្រះជាម្ចាស់នាំតែខាតពេលទេ ។ សូមប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មានដែលបានចែងក្នុងព្រះគម្ពីរចុះ ។

៣. សូមសួរខ្លួនឯងថា "តើខ្ញុំមានភាពសុខសាន្តនៅក្នុងចិត្តដែរឬទេ?" ។ ជាញឹកញាប់ ព្រះជាម្ចាស់តែងតែប្រទានអោយយើងនូវ ភាពប្រាកដក្នុងចិត្តចំពោះកិច្ចការដែលព្រះអង្គសព្វព្រះទ័យអោយយើងធ្វើ ។ ប្រសិនបើភាពសុខសាន្តនោះបានមកពីព្រះជាម្ចាស់ វានឹងមិនរលាយភ្លាមៗនោះឡើយ ។

៤. តើគំនិតដែលមកពីព្រះជាម្ចាស់ អាចចាក់ចេញពីខ្ញុំបានដែរឬទេ? ប្រសិនបើគំនិតនោះនៅតែត្រឡប់ចូលមកវិញ ហើយវាដើរស្របជាមួយនឹងព្រះគម្ពីរ ប្រហែលនោះមកពីព្រះជាម្ចាស់ហើយ ។

៥. យើងប្រហែលជាត្រូវការជំនួយពីគ្រិស្តបរិស័ទចាស់ៗ ។ សូមមានចិត្តរៀនពីអ្នកដទៃ ។ ប៉ុន្តែសូមកុំពឹងទាំងស្រុងទៅលើសំដីរបស់ពួកគេ ។ សូមរៀនយកសំដីរបស់ពួកគេធ្វើជាយោបល់ស្ថាបនា ។

មានពេលខ្លះ យើងអាចមានទំនុកចិត្តដល់ទៅ៩៩ភាគរយ ។ ប្រសិនបើយើងគិតថា ព្រះជាម្ចាស់មានបន្ទូលប្រាប់យើងអោយអធិស្ឋានអោយនរណាម្នាក់ សូមអធិស្ឋានចុះ ។ វាជាការល្អ ក្នុងការអធិស្ឋានអោយនរណាម្នាក់ ទោះជាព្រះវិញ្ញាណមិនបានមានបន្ទូលប្រាប់អោយយើងធ្វើក៏ដោយ ។

## គ. ការផ្លាស់ប្រែនៅក្នុងជីវិតរបស់យើង

នៅពេលមនុស្សម្នាក់ក្លាយជាគ្រិស្តបរិស័ទ ផ្នែកដែលផ្លាស់ប្រែមុនគេគឺ វិញ្ញាណរបស់គាត់។ ព្រះជាម្ចាស់នាំជីវិតថ្មីមកអោយវិញ្ញាណរបស់យើង នៅពេលយើងក្លាយជាគ្រិស្តបរិស័ទ។ ព្រះអង្គយាងមកគង់នៅក្នុងវិញ្ញាណរបស់យើង។ មានមនុស្សភាគតិចណាស់ ដែលនឹកឃើញពីបញ្ហារបស់ខ្លួន នៅថ្ងៃដែលពួកគេក្លាយជាគ្រិស្តបរិស័ទ។ តាមពិត ពួកគេឃើញបញ្ហាជាច្រើនលេចឡើង ក្រោយពេលពួកគេក្លាយជាគ្រិស្តបរិស័ទ។

ដូចគ្នាដែរ ចំពោះទារកដែលទើបនឹងប្រសូត ក្នុងរយៈពេល៩ខែ ទារកពិតជាមានភាពសុខសាន្ត ភាពកក់ក្តៅ និងពោរពេញដោយសុវត្ថិភាព។ ក្រោយមកទារកត្រូវប្រឈមមុខនឹងបញ្ហាថ្មីមួយចំនួន។ បញ្ហាទាំងនោះតែងធ្វើអោយទារកយំ ប៉ុន្តែទោះជាមានទុក្ខលំបាកទាំងអស់នោះក៏ដោយ ទារកនៅតែចំរើនវ័យឡើង។ ច្រើនសប្តាហ៍ និងច្រើនខែក្រោយមក យើងនឹងឃើញទារកផ្លាស់ប្តូរខុសពីមុន។ គ្រិស្តបរិស័ទថ្មីក៏ជួបនូវការឈឺចាប់ស្រដៀងគ្នានេះដែរ គឺក្រោយពីពេលថ្វាយជីវិតរបស់ពួកគេទៅព្រះគ្រិស្ត។

ធ្វើជាគ្រិស្តបរិស័ទគឺមានន័យថា ធ្វើខ្លួនអោយមានលក្ខណៈដូចជាព្រះយេស៊ូគ្រិស្ត បន្តិចម្តងៗ ពីមួយថ្ងៃទៅមួយថ្ងៃ។ តើការផ្លាស់ប្រែបែបណា ដែលព្រះជាម្ចាស់គាប់ព្រះទ័យអោយអ្នកធ្វើនៅសប្តាហ៍នេះ? សូមគិតអំពីចំនុចនេះ វាចាំបាច់ណាស់ ក្នុងការជួយយើងអោយមានលក្ខណៈដូចជាយេស៊ូ។ ក្នុងការកសាងជីវិតជីវិតរបស់យើងរាល់ចំនុចវិជ្ជមានទាំងនោះនឹងបង្ហាញពីព្រះជន្មរបស់ព្រះអង្គនៅក្នុងយើង។ សូមកុំចំណាយកំលាំងទៅលើការដោះស្រាយបញ្ហារបស់ខ្លួនច្រើនពេក តែសូមសម្លឹងទៅព្រះយេស៊ូ។ ការផ្លាស់ប្រែដែលយើងបានធ្វើ នឹងនាំសិរីរុងរឿងព្រមទាំងកិត្តិយសដល់ព្រះជាម្ចាស់។

យើងត្រូវតែផ្លាស់ប្រែ។ ការផ្លាស់ប្រែមិនអាចរីកទៅមុខដោយស្វ័យប្រវត្តិបានឡើយ។ ជួនកាលស្រួលជួនកាលត្រូវចំណាយពេលដល់ទៅរាប់ឆ្នាំឯណោះ។ គ្រិស្តបរិស័ទថ្មីគួរតែអាចស្គាល់នូវការផ្លាស់ប្រែមួយចំនួន ដែលជាភស្តុតាងបញ្ជាក់ថា ឥឡូវនេះព្រះយេស៊ូជាអ្នកដឹកនាំជីវិតរបស់យើង។ ការផ្លាស់ប្រែដែលជាភស្តុតាងទាំងអស់នេះ គឺជាប្រភពនៃការលើកទឹកចិត្តសំរាប់ខ្លួនយើងផ្ទាល់ និងសំរាប់អ្នកដទៃផ្សេងទៀត ចំពោះកិច្ចការដែលព្រះជាម្ចាស់បានធ្វើនៅក្នុងជីវិតរបស់យើង។

ការផ្លាស់ប្រែទាំងអស់នេះ នឹងមិនធ្វើអោយយើងក្លាយជាគ្រិស្តបរិស័ទឡើយ។ ទាំងនេះជាលទ្ធផល ដែលចេញមកពីគ្រិស្តបរិស័ទ។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងណែនាំយើងអោយស្គាល់ពីសេចក្តីពិត ហើយបង្ហាញយើងអំពីចំនុចដែលយើងត្រូវផ្លាស់ប្រែ ជាមួយនឹងវិធីដែលយើងអាចផ្លាស់ប្រែប្រកបដោយប្រសិទ្ធិភាព។ នៅពេលយើងអធិស្ឋាន សិក្សាព្រះគម្ពីរ និងអនុវត្តតាមព្រះបន្ទូលរបស់ទ្រង់ ព្រះអង្គនឹងបង្ហាញយើងពីវិធីរស់នៅដែលត្រឹមត្រូវស្របតាមព្រះទ័យរបស់ព្រះអង្គ។

**១. យើងនឹងយល់ច្បាស់ចំពោះសេចក្ដីសុចរិត និងអំពីបាប**

ព្រះយេស៊ូបានមានព្រះបន្ទូលសន្យានៅក្នុង យ៉ូហាន ១៥:១៦-១៧ និង យ៉ូហាន ១៦:៨-១៥ថា កាលណាព្រះវិញ្ញាណនៃសេចក្ដីពិតយាងមក ព្រះអង្គនឹងណែនាំអ្នករាល់គ្នាអោយស្គាល់សេចក្ដីពិតគ្រប់ជំពូក។ ព្រះវិញ្ញាណមានកិច្ចការជាច្រើនដែលត្រូវបំពេញ ហើយនៅក្នុងនោះមានកិច្ចការមួយគឺ បញ្ជាក់អោយមនុស្សលោកដឹងថា គេយល់ខុសអំពីបាប អំពីសេចក្ដីសុចរិត អំពីការកាត់ទោស។ យើងនឹងអាចយល់ចំនុចនេះបាន ប្រសិនបើយើងយល់ព្រះហឫទ័យនិងទស្សនៈរបស់ព្រះជាម្ចាស់។

ព្រះវិញ្ញាណនឹងមានបន្ទូលទៅកាន់មនសិការរបស់យើង ដើម្បីប្រាប់យើងអំពីសេចក្ដីសុចរិត និងអំពីបាប។ យើងត្រូវតែប្រយ័ត្នចំពោះការស្ដាប់តាមមនសិការរបស់យើង។ បន្ទាប់មក យើងត្រូវបង្កើតទំលាប់អានព្រះគម្ពីរ ដើម្បីរកខគម្ពីរខ្លះៗដែលបញ្ជាក់ថា ព្រះជាម្ចាស់មានបន្ទូលមកយើងតាមមនសិការរបស់យើង។

ការយល់ច្បាស់ចំពោះសេចក្ដីសុចរិត និងអំពើបាប នឹងមានឥទ្ធិពលទៅលើគំនិត និងឥរិយាបថរបស់យើង។ យើងត្រូវតែព្យាយាមធ្វើអ្វីដែលជាអំពើសុចរិត ហើយសូមកុំយល់ព្រមប្រព្រឹត្តអោយសោះ។ និយាយមានភាពងាយស្រួល ប៉ុន្ដែពេលខ្លះ យើងក៏មានបញ្ហាដូចលោកប៉ូលដែរ។ គាត់បានពិពិណនាបញ្ហាទាំងអស់នេះនៅក្នុង រ៉ូម ៧:១-២៥។ គាត់ស្គាល់កិច្ចការដែលត្រឹមត្រូវ ប៉ុន្ដែគាត់បែរជាធ្វើផ្ទុយទៅវិញ។ ជាញឹកញាប់ ទំលាប់មិនល្អដែលមានតាំងពីមុនមក នៅតែមានអំណាចនៅក្នុងជីវិតរបស់គ្រិស្ដបរិស័ទថ្មី។

ព្រះជាម្ចាស់មិនរំពឹងថា យើងអាចធ្វើបានល្អឥតខ្ចោះនោះឡើយ ប៉ុន្ដែព្រះអង្គទតមើលតែចិត្ត និងបំណងប្រាថ្នារបស់យើងប៉ុណ្ណោះ។ តើអ្នកចង់ប្រតិបត្តិតាមព្រះអង្គ ហើយធ្វើកិច្ចការដែលត្រឹមត្រូវដែរឬទេ? ប្រសិនបើចង់ ព្រះជាម្ចាស់នឹងជួយអ្នកឈ្នះលើទំលាប់មិនល្អទាំងឡាយ ដែលមានអំណាចក្នុងជីវិតរបស់អ្នក។ ចំនុចគន្លឹះនោះគឺ "តើព្រះជាម្ចាស់មានបន្ទូលបែបណាចំពោះសេចក្ដីសុចរិត និងអំពើបាប?"។ ព្រះវិញ្ញាណមិនគាប់ព្រះទ័យទេ ប្រសិនបើអ្នកមិនធ្វើតាមមនសិការដែលត្រឹមត្រូវ ឬក៏ឃើញអ្នកលាក់ទុកនូវឥរិយាបថមិនល្អរបស់ខ្លួន។

**សុភាសិត ២៨:១៣**

**អ្នកណាលាក់កំហុសរបស់ខ្លួន អ្នកនោះមិនអាចចំរើនឡើងបានឡើយ។ រីឯអ្នកដែលសារភាពកំហុសហើយឈប់ប្រព្រឹត្តអំពើអាក្រក់ទៀត នោះព្រះជាម្ចាស់នឹងអាណិតមេត្តា។**

ខាងក្រោមនេះជាខគម្ពីរច្រើនទៀត ដែលមានជាប់ទាក់ទងនឹងចំនុចនេះ

| | | |
|---|---|---|
| សុភាសិត ២:៩ | ទំនុកតម្កើង ៩៧:១០ | ១ធីម៉ូថេ ១:១៩ |
| សុភាសិត ៣:១៣-១៥ | ហេព្រើ ៥:១៤ | |

**២. យើងនឹងស្រឡាញ់ (មានចំណាប់អារម្មណ៍) ចំពោះព្រះគម្ពីរ**

ប្រសិនបើអ្នកចង់រៀនថែមទៀតអំពីព្រះជាម្ចាស់ សូមចំណាយពេលជារៀងរាល់ថ្ងៃដើម្បីអានព្រះគម្ពីរ។ អ្នកអាចរៀនអំពីវិធី ដែលព្រះអង្គទតមើលមកក្នុងជីវិតរបស់យើង។ អ្នកក៏នឹងអាចដឹងថា កិច្ចការបែបណាដែល

ព្រះអង្គគាប់ព្រះទ័យ ដើម្បីអោយយើងកាន់តែដូចព្រះអង្គ។ បទពិសោធន៍នៃជីវិតរបស់មនុស្សនៅក្នុងព្រះគម្ពីរ អាចជួយផ្តល់នូវដំបូន្មានល្អៗដល់យើង ដើម្បីចៀសផុតពីបញ្ហាគ្រប់ជំពូក និងដើម្បីធ្វើការសំរេចចិត្តដែលត្រឹមត្រូវ។

ជួនកាល ការអានព្រះគម្ពីរអាចធ្វើអោយយើងធុញទ្រាន់។ សូមកុំភ្ញាក់ផ្អើល បើវាមិនដែលកើតឡើងចំពោះអ្នក។ បញ្ហានេះអាចមានដំណោះស្រាយ។ តើព្រះគម្ពីរដែលអ្នកអាន មានការបកប្រែយ៉ាងម៉េចដែរ? តើនៅពេលអាន អ្នកស្រួលយល់ដែរឬទេ? បើមិនស្រួលយល់ទេ សូមរកព្រះគម្ពីរដែលមានការបកប្រែផ្សេងមួយទៀតមកអាន។ ឬក៏ព្យាយាមអានខគម្ពីរដូចគ្នានេះ នៅក្នុងព្រះគម្ពីរដែលមានការបកប្រែផ្សេងទៀត។

មូលហេតុមួយទៀតដែលជាប់ទាក់ទងនឹងការធុញទ្រាន់ក្នុងការអានព្រះគម្ពីរ គឺអត្ថបទនៅក្នុងព្រះគម្ពីរ។ ប្រសិនបើអត្ថបទដែលអ្នកអាននៅក្នុងព្រះគម្ពីរ មើលទៅហាក់ដូចជាមិនសូវចាប់អារម្មណ៍ អ្នកអាចបើកទៅអានអត្ថបទផ្សេងមួយទៀតបាន។ ឧទាហរណ៍ដូចជា ជួនកាលយើងចង់អានសម្ពន្ធមេត្រីចាស់ ហើយក៏ចង់អានសម្ពន្ធថ្មីដែរ។ ការអានចំរុះបែបនេះអាចជួយយើងបានច្រើន។ ប៉ុន្តែសូមចៀសវាងការអានរំលោងជារៀងរាល់ថ្ងៃ។ សូមរៀបចំកាលវិភាគផ្ទាល់ខ្លួនដើម្បីអានព្រះគម្ពីរ ហើយអនុវត្តតាមកាលវិភាគនោះអោយបានយ៉ាងតិចក៏១ ឬ២សប្តាហ៍ដែរ មុនពេលកែប្រែកាលវិភាគនោះ។

ជួនកាល មូលហេតុដែលនាំអោយមានភាពធុញទ្រាន់ក្នុងការអានព្រះគម្ពីរនោះគឺ តើយើងអានហើយយើងបានអនុវត្តតាមដែរឬទេ? ប្រសិនបើយើងគ្រាន់តែអានធម្មតា ភាពធុញទ្រាន់ប្រាកដជានឹងចូលមក។ យើងគួរតែរិះរកវិធីណាដែលយើងអាចយកសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរ មកអនុវត្តនៅក្នុងជីវភាពប្រចាំថ្ងៃរបស់យើង។ បែបនេះទើបយើងអាចបង្កើនចំណាប់អារម្មណ៍ជាមួយនឹងព្រះគម្ពីរបាន។ នៅពេលដែលយើងឃើញមានភាពផ្លាស់ប្រែនៅក្នុងជីវិតរបស់យើង យើងនឹងរឹតតែចង់ស្វែងយល់ថែមទៀតអំពី របៀបយកឈ្នះលើបញ្ហា ដែលមាននៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។

វិធីមួយទៀតដែលជួយដល់យើងក្នុងការអានព្រះគម្ពីរគឺ សួរខ្លួនឯងថា "តើខគម្ពីរនេះប្រាប់ខ្ញុំអ្វីខ្លះអំពីព្រះជាម្ចាស់ និងមាគ៌ារបស់ព្រះអង្គ?"។ បែបនេះ យើងនឹងរំភើបជាមួយនឹងកិច្ចការ ដែលព្រះជាម្ចាស់បានធ្វើចំពោះមនុស្សផ្សេងទៀតនៅអតីតកាល។

ការមកចូលរួមសិក្សាព្រះគម្ពីរជាមួយនឹងគ្រិស្តបរិស័ទផ្សេងទៀត ក៏អាចជួយយើងអោយកាន់តែមានចំណាប់អារម្មណ៍ថែមទៀត ជាមួយនឹងព្រះគម្ពីរ។ ប្រសិនបើគ្មានក្រុម ដែលមកជួបគ្នាដើម្បីសិក្សាព្រះគម្ពីរទេ អ្នកអាចរកគ្រិស្តបរិស័ទណាម្នាក់ ហើយណាត់ជួបគាត់មួយម្តងក្នុងមួយសប្តាហ៍ក៏បាន។ ចែកចាយទៅវិញទៅមកនូវមេរៀនដែលអ្នកបានសិក្សានៅក្នុងព្រះគម្ពីរ កាលពីសប្តាហ៍មុន។ ការពិភាក្សានេះជាជំនួយយ៉ាងពិសេសសំរាប់អ្នក ហើយវាអាចជួយលើកទឹកចិត្តអ្នករាល់ថ្ងៃក្នុងការអានព្រះគម្ពីរទៀតផង។ ប្រសិនបើអ្នកដឹងថា អ្នកត្រូវប្រាប់មិត្តរបស់អ្នកនូវខគម្ពីរដែលអ្នកបានអាន អ្នកនឹងមិនចាញ់ការល្បួងក្នុងការអានព្រះគម្ពីរឡើយ។

បញ្ហាដែលកើតឡើងនោះគឺ "ហេតុអ្វីបានជាខ្ញុំចង់អានព្រះគម្ពីរ?"។ "តើការអានព្រះគម្ពីរនឹងជួយខ្ញុំយ៉ាងម៉េចទៅ?"។ ចំណាប់អារម្មណ៍ជាមួយនឹងព្រះគម្ពីរ គឺចេញពីចិត្ត មិនមែនចេញមកពីការញញើតកោតខ្លាចនរណា

ម្នាក់នោះឡើយ ។ សូមអានខគម្ពីរទាំងនេះដែលមានជាប់ទាក់ទងជាមួយនឹងចំនុចនេះៈ ១ ពេត្រុស ២:២ និង ទំនុកតម្កើង ១១៩:៩,១១ ។

**៣. យើងនឹងមានបំណងចិត្តចង់ធ្វើខ្លួនអោយដូចជាព្រះយេស៊ូ**

ឧទាហរណ៍របស់ក្មេងៗ ទើបធ្វើអោយយើងងាយស្រួលយល់នៅក្នុងចំនុចនេះ ។តើកុមារតូចៗធ្លាប់និយាយប៉ុន្មានដងថា "ធំឡើងខ្ញុំចង់ធ្វើដូចម៉ាក់ ឬធ្វើដូចលោកប៉ា!" (ទោះជាកុមារនោះធំឡើងពេញវ័យក៏ដោយ) ។ ភាពដូចក្មេងដែលចង់ធ្វើដូចជាឪពុក និងចង់ធ្វើដូចម្តាយ ជាការគាប់ព្រះទ័យព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ចង់ឃើញភាពដូចគ្នានេះកើតមានឡើងចំពោះគ្រិស្តបរិស័ទថ្មី ។

ឪពុកម្តាយមិនបានបង្រៀនកូនអោយនិយាយបែបនេះទេ ។ តែកូននិយាយដូច្នេះ ដោយសារតែកូននោះពិតជាមានអារម្មណ៏បែបនេះនៅក្នុងចិត្តមែន ។ ព្រះជាម្ចាស់ក៏កំពុងតែទតរកមើលភាពស្រដៀងគ្នានេះដែរ ។ "ព្រះជាម្ចាស់អើយ ទូលបង្គំចង់នៅជិតព្រះអង្គ ។ ទូលបង្គំចង់ដូចព្រះអង្គ មិនមែនដោយសារនេះជាក្រិត្យវិន័យរបស់ព្រះអង្គតែប៉ុណ្ណោះទេ តែដោយសារតែទូលបង្គំស្រឡាញ់ព្រះអង្គ" ។

តើយើងអាចដូចជាមនុស្សម្នាក់ទៀត ដែលយើងមិនធ្លាប់ឃើញ និងមិនធ្លាប់និយាយជាមួយដោយរបៀបណា? យើងនឹងសិក្សាស៊ីជំរៅថែមទៀត អំពីការពង្រីកទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះយេស៊ូ នៅជំពូកទី៣ ។ ប៉ុន្តែឥឡូវនេះ យើងចង់សិក្សាទៅលើរបៀបដែលយើងអាចផ្លាស់ប្តូរឥរិបថ និងមាយាទ ដើម្បីអោយដូចជាព្រះគ្រិស្ត ។

សូមគិតឡើងវិញអំពីប្រតិកម្មរបស់យើង ចំពោះរាល់បញ្ហាដែលកើតមានឡើង ។ ប្រសិនបើព្រះគ្រិស្តជាយើងវិញ តើព្រះអង្គនឹងធ្វើដូចយើងដែរឬទេ? សូមអានសៀវភៅម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាននៅក្នុងសម្ពន្ធមេត្រីថ្មី ដើម្បីអោយកាន់តែស្គាល់ព្រះយេស៊ូថែមទៀត ។

ការធ្វើខ្លួនអោយដូចជាព្រះគ្រិស្ត មិនមែនមានន័យថា គ្រិស្តបរិស័ទទាល់តែបង្កើតតារាងមួយ ដែលរៀបរាប់អំពីកិច្ចការដែលត្រូវធ្វើ និងកិច្ចការដែលមិនត្រូវធ្វើ នោះឡើយ ។ ព្រះវិញ្ញាណនឹងជួយប្រាប់អ្នក ចំនុចត្រង់ណាដែលគួរតែកែប្រែ ។ សូមកុំអនុញ្ញាតអោយសំពាធរបស់អ្នកដទៃ ធ្វើអោយអ្នកផ្លាស់ប្រែតែផ្នែកខាងក្រៅ (ព្រោះអ្នកចង់អោយពួកគេសប្បាយចិត្ត) ។ អ្នកមិនអាចបដិសេធចំពោះការផ្លាស់ប្រែពីខាងក្នុងបានឡើយ ហើយការផ្លាស់ប្រែនោះនឹងធ្វើឡើងជាមួយនឹងឥរិយាបថ អារម្មណ៏ និងគំនិតរបស់អ្នក ។

ប្រសិនបើអ្នកនៅតែមានបញ្ហា ជំហានទី១ សូមរក្សានូវឥរិយាបថល្អរបស់ខ្លួន ។ "ខ្ញុំចង់ដូចព្រះយេស៊ូជារៀងរាល់ថ្ងៃ" ។ ទទួលស្គាល់ការពិត បែបនេះនឹងមានការរីកចំរើនទៅមុខ ។ ដូចជាក្មេងអាយុ៤ឆ្នាំដែរ វាតែងនិយាយថា វាចង់ធ្វើដូចប៉ារបស់វា ។ ក្មេងនោះមិនអាចធំពេញវ័យក្នុងរយៈពេល៣សប្តាហ៏នោះឡើយ ។ ប៉ុន្តែវាធំឡើងបន្តិចម្តងជារៀងរាល់ថ្ងៃ ។

សូមចាំថា ព្រះវិញ្ញាណរស់នៅក្នុងយើង ដើម្បីបង្រៀនយើង និងដឹកនាំយើងអោយស្គាល់សេចក្តីពិត ។ ព្រះអង្គជួយយើងស្វែងរកឫសគល់នៃបញ្ហាទាំងឡាយ ដែលបានរារាំងយើងមិនអោយរីកចំរើនទៅមុខ ។ ប្រហែលជាព្រះអង្គប្រើគ្រិស្តបរិស័ទម្នាក់ទៀតមកជួយយើង ក៏ថាបាន ។ ប៉ុន្តែសូមរក្សាក្តីសង្ឃឹមទុកជាមួយនឹងព្រះអង្គ

ហើយសូមកុំអនុញ្ញាតអោយការយល់ខុសរបស់នរណាម្នាក់ បង្អាក់យើងពីដំណើរឆ្ពោះទៅកាន់ភាពដូចជាព្រះយេស៊ូអោយសោះ។

ជួនកាលយើងបារម្ភពេកថា យើងហាក់ដូចជាមិនឃើញដំណោះស្រាយអ្វីសោះពីព្រះជាម្ចាស់ ចំពោះបញ្ហារបស់យើង។ "បញ្ហានៅតែមាននៅក្នុងខ្ញុំនៅឡើយ។ ប្រហែលនេះជាព្រះហឫទ័យរបស់ព្រះអង្គហើយមើលទៅ"។ សូមកុំដោះសារបែបនេះ។ ភីលីព ៤:១៣បានចែងថា ខ្ញុំអាចទ្រាំបានទាំងអស់ ដោយរួមជាមួយព្រះអង្គដែលប្រទានកម្លាំងអោយខ្ញុំ។ ជួនកាល ព្រះម្ចាស់អនុញ្ញាតអោយបញ្ហាចូលមកក្នុងជីវិតយើង ក្នុងករណីដែលព្រះអង្គមិនអាចមានបន្ទូលមកកាន់មនសិការរបស់យើងបាន។

នៅក្នុងព្រះគម្ពីរមានឧទាហរណ៍ជាច្រើន ដែលមានទាំងបុរស ទាំងស្ត្រី ហើយពួកគេសុខចិត្តដើរតាមមាគ៌ារបស់ព្រះជាម្ចាស់ដោយអស់ពីចិត្ត។ ពួកគេមិនមែនល្អឥតខ្ចោះនោះទេ ប៉ុន្តែពួកគេបានដាក់ព្រះជាម្ចាស់ជាអទិភាពទីមួយនៅក្នុងជីវិតរបស់ពួកគេ។ មានដូចជាៈ លោកណូអេ លោកអប្រាហាំ លោកយ៉ូសែប លោកម៉ូសេ លោកសាំយូអែល ព្រះបាទដាវីឌ ព្រះបាទហេសេគា ព្រះបាទយ៉ូសៀស នាងរស់ នាងអេសធើរ លោកដានីយ៉ែល ហើយនៅក្នុងសម្ពន្ធមេត្រីថ្មី មានសាវ័ករបស់ព្រះយេស៊ូ លោកប៉ូល លោកលូកា លោកស្ទេផាន លោកធីម៉ូថេ។ សូមអាន ១យ៉ូហាន ២:៦ និង ១ពេត្រុស ២:២១។

**៤. យើងនឹងជួបជាមួយនឹងការល្បងជំនឿ ការល្បួង និងបញ្ហាជាច្រើនទៀត**

មានគ្រិស្តបរិស័ទច្រើនអាចនឹងសប្បាយចិត្ត ប្រសិនបើឮគេនិយាយថា "យើងនឹងមានការល្បងជំនឿ ការ ល្បួង និងបញ្ហាតិចជាងមុន"។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើយើងចង់ដូចព្រះយេស៊ូ យើងត្រូវតែត្រៀមខ្លួន ដើម្បីប្រឈមមុខនឹងគ្រប់បញ្ហា។ ព្រះយេស៊ូមិនដែលប្រព្រឹត្តអំពើបាបម្តងណាឡើយ ប៉ុន្តែព្រះអង្គនៅតែប្រឈមមុខនឹងការល្បងជំនឿ ការល្បួង និងបញ្ហាជាច្រើន។ យើងក៏មានបញ្ហាច្រើនដែរ ប៉ុន្តែនៅក្នុងចំណោមយើង បែរជាមានមនុស្សមួយចំនួន ត្រឡប់ទៅធ្លាក់ក្នុងអំពើបាបដូចមុន ឬក៏មានការចុះខ្សោយកំលាំងខាងវិញ្ញាណទៅវិញ។ សូមទទួល និងប្រឈមមុខនឹងបញ្ហាទាំងអស់នោះ ទោះជាយើងចូលចិត្ត ឬមិនចូលចិត្តវាក៏ដោយ។

ទោះជាមានភាពរឹងមាំខាងផ្នែកព្រលឹងវិញ្ញាណ ដូចកាលដែលព្រះយេស៊ូគង់នៅលើផែនដីនេះក៏ដោយ ក៏យើងនៅតែប្រឈមមុខនឹងបញ្ហាជាច្រើនដែរ។ គ្រាន់តែបញ្ហាកាលពីជំនាន់នោះ មានភាពខុសប្លែកពីបញ្ហានៅសម័យនេះ។ យ៉ាកុប ១:២-៤ បានពន្យល់យ៉ាងច្បាស់អំពីបញ្ហា និងការល្បងជំនឿដែលចូលមកក្នុងជីវិតយើង ហើយប្រាប់យើងយ៉ាងច្បាស់អំពី ឥរិយាបថដែលយើងគួរសំដែងទៅអ្នកដទៃផ្សេងទៀត។

យ៉ាកុប ១:២_៤

**បងប្អូនអើយ ទុក្ខលំបាកគ្រប់យ៉ាង ដែលបងប្អូនត្រូវឆ្លងកាត់ សូមចាត់ទុកថាជាការធ្វើអោយបងប្អូនមានអំណរបរិបូរណ៍វិញ ដោយដឹងថា ការល្បងលមើលជំនឿរបស់បងប្អូន នឹងនាំអោយបងប្អូនចេះស៊ូទ្រាំ។ ក៏ប៉ុន្តែ ត្រូវអោយការស៊ូទ្រាំនេះបង្កើតចេញជាផលផ្លែដ៏ល្អគ្រប់លក្ខណៈ ដើម្បី**

អោយបងប្អូនបានគ្រប់លក្ខណៈ មានគុណសម្បត្តិល្អសព្វគ្រប់ ឥតខ្វះត្រង់ណាឡើយ។

មានការល្បួងជំនឿផ្សេងៗពីគ្នា ដែលនឹងចូលមកក្នុងជីវិតយើងជារៀងរាល់ថ្ងៃ។ ខាងក្រោមនេះ ជាការល្បួងជំនឿ ដែលយើងអាចរំពឹងថា វាអាចនឹងកើតឡើងបាន។

ក. ការល្បួងអោយប្រព្រឹត្តអំពើបាប ១កូរិនថូស ១០:១៣

ខ. ការបៀតបៀន ២ធីម៉ូថេ ៣:១២

គ. ការធ្លាក់ចុះរបស់គ្រិស្តបរិស័ទផ្សេងទៀត កាឡាទី ៦:១-២

ឃ. ប្រឈមនឹងការពិតនៅក្នុងជីវិត

ង. ការយកឈ្នះអតីតកាល

តើព្រះជាម្ចាស់នឹងជួយយើង ក្នុងការដោះស្រាយបញ្ហាដែរឬទេ? ព្រះអង្គនឹងជួយ។ មានខគម្ពីរជាច្រើនដែលបានចែងអំពី ព្រះបន្ទូលសន្យានេះ។ ប៉ុន្តែ ជាញឹកញាប់ ព្រះម្ចាស់តែងជួយយើងអោយឆ្លងកាត់គ្រប់ឧបសគ្គ ដែលជាវិធីប្រសើរជាងការដកឧបសគ្គចេញពីជីវិតរបស់យើងទៅទៀត។ ព្រះជាម្ចាស់ប្រើបញ្ហាទាំងអស់នោះ ដើម្បីជួយយើងអោយរីកចំរើនឡើង។

"តើការល្បួងអោយខ្ញុំប្រព្រឹត្តអំពើបាប នឹងដើរតាមខ្ញុំរហូតទេ?" ដោយមានជំនួយពីព្រះជាម្ចាស់ យើងនឹងអាចឆ្លងផុតការល្បួងបាន។ យើងត្រូវធ្វើកិច្ចការដែលជាការទទួលខុសត្រូវរបស់យើង ចំណែកឯព្រះជាម្ចាស់វិញ ព្រះអង្គនឹងបំពេញកិច្ចការរបស់ព្រះអង្គ។ នៅពេលយើងរីកចំរើនក្លាយជាគ្រិស្តបរិស័ទដែលរឹងមាំខាងព្រលឹងវិញ្ញាណ ការល្បួងអោយយើងប្រព្រឹត្តអំពើបាប មិនអាចមានឥទ្ធិពលលើយើងឡើយ។ ព្រះជាម្ចាស់ចង់អោយយើងមានសេរីភាពរួចផុតពីអំណាចនៃអំពើបាប។ ព្រះអង្គនឹងជួយយើងអោយឈ្នះលើគ្រប់បញ្ហាដែលមានអំណាចក្នុងជីវិតយើង។ ប៉ុន្តែសូមចាំថា ការកំចាត់បញ្ហាទាំងនោះចេញពីជីវិតរបស់យើង មិនមែនជាកិច្ចការមួយដែលសំខាន់ជាងគេនៅក្នុងជីវិតនេះឡើយ។ កិច្ចការដែលសំខាន់ជាងគេនោះគឺ ត្រូវស្រឡាញ់ព្រះជាម្ចាស់អោយអស់ពីចិត្ត អស់ពីអារម្មណ៍ អស់ពីគំនិត និងអស់ពីកំលាំងរបស់យើង។

### ៥. យើងនឹងមានសេចក្តីស្រឡាញ់ចំពោះអ្នកដទៃផ្សេងទៀត (ជាពិសេសចំពោះគ្រិស្តបរិស័ទផ្សេងទៀត)

អត្ថបទគម្ពីរ ១យ៉ូហាន ៤:៧-១៣ និង យ៉ូហាន ១៣:៣៤-៣៥ បានចែងអំពី ការផ្លាស់ប្រែដែលសំខាន់ជាងគេ ហើយកំពុងកើតឡើងនៅក្នុងជីវិតគ្រិស្តបរិស័ទ។ ការរៀនស្រឡាញ់អ្នកដទៃផ្សេងទៀតដូចព្រះយេស៊ូ ជាអទិភាពទីមួយនៅក្នុងជីវិតរបស់យើង។ ម៉ាកុស ១២:៣-៣១ បានចែងថា បទបញ្ញាដែលសំខាន់ជាងគេរបស់ព្រះជាម្ចាស់គឺ ត្រូវស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់អ្នកដទៃផ្សេងទៀត។

ព្រះជាម្ចាស់មិនបានមានបន្ទូលអំពី ក្តីស្រឡាញ់បែបមនោសញ្ចេតនានៅត្រង់ចំនុចនេះឡើយ។ ព្រះអង្គមានបន្ទូលអំពី ការចេះជួយទុកធុរៈគ្នា និងក្តីស្រឡាញ់ដែលមិនគិតតែពីខ្លួនឯង ដែលយើងគួរយកមកអនុវត្ត។ សេចក្តីស្រឡាញ់ប្រភេទនេះ មានចែងនៅក្នុង ១កូរិនថូស ១៣:១-៨។ លក្ខណៈទីមួយរបស់ក្តីស្រឡាញ់នោះគឺ

ភាពអត់ធ្មត់ ។ ជាទូទៅ ការអត់ធ្មត់មានភាពពិបាកក្នុងការអនុវត្តន៏ ។ ក្តីស្រឡាញ់ប្រភេទនេះទាមទារនូវការប្តេជ្ញាចិត្តដែលចេញពីខ្លួនយើងផ្ទាល់ ។ ព្រះជាម្ចាស់កំពុងតែទតរកភាពជាក់ស្តែង នៃសេចក្តីស្រឡាញ់ដែលរាប់អានគ្នាដូចជាបងប្អូន ។

ឥឡូវនេះ អ្នកប្រហែលជាគិតឃើញហើយថា មានមនុស្សជាច្រើនដែលអ្នកពិបាកនឹងស្រឡាញ់ ។ ព្រះជាម្ចាស់អាចប្រទានអោយយើងនូវក្តីស្រឡាញ់ ដែលចេះគិតគូរដល់អ្នកដទៃ ទោះជាពួកគេមិនតបជាមួយនឹងយើងដោយក្តីស្រឡាញ់វិញក៏ដោយ ។ ពិតជាពិបាក តែយើងអាចធ្វើបាន ។ ព្រះជាម្ចាស់មានបន្ទូលសន្យាថា នឹងជួយយើង ដូច្នេះនៅពេលជួបមនុស្សបែបនេះ សូមទូលសុំព្រះអង្គជួយអ្នក អោយចេះស្រឡាញ់គាត់ ។ ទូលសុំព្រះអង្គជួយយើង អោយចេះអត់ធ្មត់ និងមានចិត្តសប្បុរសទៅកាន់គាត់ ។ ចូរចាំថា យើងជ្រើសរើសស្រឡាញ់មនុស្សគ្រប់គ្នា ។

**៦. យើងនឹងចង់ប្រាប់អ្នកដទៃផ្សេងទៀតអំពីព្រះយេស៊ូគ្រិស្ត**

ការផ្លាស់ប្រែបែបនេះ គួរតែមាននៅថ្ងៃដំបូងដែលយើងក្លាយជាគ្រិស្តបរិស័ទ ។ សូមប្រាប់ពួកគេអំពី អ្វីៗដែលព្រះយេស៊ូគ្រិស្តបានធ្វើនៅក្នុងជីវិតអ្នក ។ ទោះជាពួកគេជាគ្រិស្តបរិស័ទ ឬមិនមែនជាគ្រិស្តបរិស័ទក៏ដោយ ។ នេះមិនមែនជាការអួតបំប៉ោងនោះឡើយ ។

នៅពេលយើងអុជទៀន យើងអុជភ្លាម វានឹងចេញពន្លឺមកភ្លាម ។ ព្រះជាម្ចាស់គាប់ព្រះទ័យ អោយយើងធ្វើជាពន្លឺរបស់ព្រះអង្គនៅក្នុងជីវិតនេះ ។ នៅពេលយើងប្រាប់អ្នកដទៃផ្សេងទៀត នៅពេលញ៉ាំបាយ នៅពេលធ្វើការ ឬក៏នៅពេលទំនេរ សូមកុំនិយាយតែអំពីអាកាសធាតុ ឬក៏និយាយដើមអ្នកដទៃ ។ ប្រាប់ពួកគេថា យើងមានអារម្មណ៏រំភើបចំពោះហេតុការណ៏ល្អៗ ដែលបានកើតឡើងនៅក្នុងជីវិតរបស់យើង ។

ប្រសិនបើអ្នកពិបាកក្នុងការនិយាយជាមួយនឹងអ្នកដែលមិនមែនជាគ្រិស្តបរិស័ទ អ្នកអាចចាប់ផ្តើមដំបូងជាមួយនឹងគ្រិស្តបរិស័ទ ឬក៏ជាមួយនឹងសមាជិកនៅក្នុងក្រុមគ្រួសាររបស់អ្នកក៏បាន ។ សូមកុំប្រដៅ ឬក៏បង្រៀនពួកគេចំពោះបញ្ហាដែលពួកគេកំពុងជួបប្រទះ ។ យើងគ្រាន់តែចង់ដាក់កំណត់ខ្លួនឯងថា ក្នុងរយៈពេល៤សប្តាហ៏ទៀត ត្រូវចែកចាយជាមួយនឹងមនុស្សយ៉ាងតិចអោយបានពីរនាក់ អំពីកិច្ចការដែលព្រះជាម្ចាស់កំពុងធ្វើនៅក្នុងជីវិតរបស់យើង ។

ប្រសិនបើអ្នកជាអ្នកញៀនថ្នាំ ឬជាអ្នកញៀនស្រា ហើយព្រះជាម្ចាស់បានជួយអ្នកអោយរួចផុតពីជីវិតបែបនេះ សូមអរសប្បាយ និងថ្វាយសិរីរុងរឿងទៅព្រះជាម្ចាស់ ។ តែសូមកុំយកកិត្តិយសមកដាក់លើខ្លួនឯង ឬក៏និយាយលើកតំលៃអំពើអាក្រក់ទាំងឡាយ ដែលអ្នកបានធ្វើនៅអតីតកាល ។ សេចក្តីពិតដែលយើងគួរចែកចាយនោះគឺ "កិច្ចការដែលព្រះគ្រិស្តបានធ្វើនៅក្នុងជីវិតយើងនៅថ្ងៃនេះ" ។ ចែកចាយជាមួយពួកគេនូវការអស្ចារ្យដែលព្រះជាម្ចាស់បានធ្វើនៅក្នុងជីវិតយើង ចាប់តាំងពីពេលយើងបានក្លាយជាគ្រិស្តបរិស័ទ ។

សមាជិកខ្លះនៅក្នុងក្រុមគ្រួសាររបស់យើង ឬអ្នកដែលមិនទាន់ជឿព្រះជាម្ចាស់ អាចមានសំនួរ និងការសង្ស័យច្រើនចំពោះកិច្ចការដែលព្រះបានធ្វើនៅក្នុងជីវិតយើង ។ ពួកគេអាចហៅយើងថា មនុស្សងុបនឹងសាសនា ឬមនុស្សឡប់ៗ ។ យើងមិនចាំបាច់និយាយយកឈ្នះពួកគេ ក្នុងន័យដើម្បីការពារព្រះជាម្ចាស់នោះឡើយ ។ គ្មានជំនួយ

របស់យើង ក៏ព្រះជាម្ចាស់អាចការពារអង្គទ្រង់បាន ។ សូមព្យាយាម និងប្រើកំលាំងរបស់អ្នកខិតខំអនុវត្តតាមព្រះគម្ពីរវិញ ទើបជាការល្អ ។ សូមបង្ហាញពួកគេអោយបានឃើញចំនុច ដែលព្រះគ្រិស្តបានបំផ្លាស់បំប្រែនៅក្នុងជីវិតរស់នៅរបស់អ្នក ។

**១ ពេត្រុស ៣:១៥**

**តែត្រូវទុកអោយព្រះគ្រិស្តជាព្រះអម្ចាស់សំដែងព្រះបារមីក្នុងចិត្តគំនិតរបស់បងប្អូនវិញ។ ត្រូវប្រុងប្រៀបខ្លួនឆ្លើយតទល់នឹងអស់អ្នកដែលសាកសួរអំពីសេចក្តីសង្ឃឹមរបស់បងប្អូននោះជានិច្ច។**

សូមអោយសកម្មភាពរបស់យើងដើរស្របនឹងពាក្យសំដីរបស់អ្នក ។ ព្រះជាម្ចាស់ទ្រង់ឈ្វេងយល់ដឹងថា យើងមិនអាចធ្វើបានល្អឥតខ្ចោះនោះឡើយ ប៉ុន្តែព្រះអង្គរំពឹងថា យើងនឹងប្រឹងអោយអស់ពីលទ្ធភាពរបស់ខ្លួន ។ ប្រសិនបើយើងខ្ជិល ហើយខ្ជះខ្ជាយពេលវេលានៅកន្លែងការងាររបស់យើង ឬក៏យើងខ្ជិលធ្វើការ សកម្មភាពទាំងនេះនឹងស្រែកប្រាប់ទៅមនុស្សផ្សេងទៀត ខ្លាំងជាងសំដីរបស់យើងទៅទៀត ។ សូមកុំនិយាយ ប្រសិនបើឥរិយាបថរបស់យើងមិនទាន់បង្ហាញពីការផ្លាស់ប្រែនៅក្នុងខ្លួនយើងនៅឡើយ ។

ចំនុចមួយទៀតដែលមនុស្សជាច្រើនអាចឃើញពីឥរិយាបថរបស់យើងគឺ ការចំណាយលុយ ។ លូកា ១៩ បានថែងអំពីវិធីដែលលោកសាខេស្គាល់ព្រះគ្រិស្ត និងរបៀបដែលគាត់កែប្រែចិត្តគំនិត ។ គាត់បានប្រាប់ពួកបណ្តាជនថា គាត់នឹងសងប្រាក់ដល់អស់អ្នកដែលគាត់បានទារពន្ធហួសកំរិត ។ ការសងប្រាក់ដែលយើងបានយកកាលពីអតីតកាល ជាការពិបាកជាទីបំផុត ។ ប៉ុន្តែព្រះវិញ្ញាណអាចជួយដឹកនាំយើង ដើម្បីអោយយើងបានទទួលនូវការលើកលែងទោស ពីសំណាក់មនុស្សយើងធ្លាប់ជិះជាន់ និងវិធីដ៏ស្រួលក្នុងការសងប្រាក់ទៅគេវិញ ។

ប្រហែលជាយើងមិនបានប្រព្រឹត្តអំពើបាបអ្វីធ្ងន់ធ្ងរទេ កាលពីអតីតកាល ។ តើយើងមានអ្វីដើម្បីប្រាប់អ្នកដទៃផ្សេងទៀត? សូមសំឡឹងមើលបច្ចុប្បន្នកាលរបស់យើង ហើយរីករាយជាមួយនឹងព្រះជាម្ចាស់ ព្រោះព្រះអង្គបានជួយយើងអោយរួចផុតពីជីវិតដែលពេញដោយបាប ។ ចូរសង្កេតមើលជីវិតប្រចាំថ្ងៃរបស់យើង ព្រោះមានចំនុចខ្លះអាចជាភស្តុតាងបញ្ជាក់ថា ព្រះអង្គកំពុងធ្វើការនៅក្នុងជីវិតយើង ។ ប្រហែលជាគ្រិស្តបរិស័ទថ្មីគិតថា អ្វីៗដែលកើតឡើងនៅក្នុងជីវិតគេ ជាការចៃដន្យ ។ ប៉ុន្តែសូមអរព្រះគុណព្រះជាម្ចាស់ ព្រោះព្រះអង្គគង់នៅជាមួយអ្នក និងចាំជួយអ្នកក្នុងគ្រប់កាលៈទេសៈទាំងអស់ ។ សូមសរសើរព្រះអង្គ ព្រោះនេះមិនមែនជាការចៃដន្យទេ ។

**៧.ការផ្លាស់ប្រែផ្សេងទៀត**

ចំនុចទាំង៦ដែលរៀបរាប់ពីខាងលើ គ្រាន់តែជាការផ្លាស់ប្រែមួយចំនួនដែលយើងអាចកត់សំគាល់ឃើញនៅពេលយើងក្លាយជាគ្រិស្តបរិស័ទ ។ នៅមានការផ្លាស់ប្រែជាច្រើនទៀត ។ ការផ្លាស់ប្រែច្រើនទៀតនៅក្នុងអេភេសូ ៤:១៧-៣២ និង កូឡុស ៣:៥-១៥ បានពិពណ៌នាអំពី ការបោះបង់អ្វីៗខាងលោកិយ៍ចោល ហើយងាកមកពាក់ជីវិតថ្មីដែលកាន់តែចំរើនថ្មីឡើងៗវិញ ។ តើអ្នកគួរតែផ្តោតទៅលើការផ្លាស់ប្តូរឥរិយាបថ ឬក៏គួរតែចាប់

ផ្តើមផ្លាស់ប្តូរអាកប្បកិរិយា? សូមប្រឹងអោយអស់ពីលទ្ធភាពរបស់ខ្លួនក្នុងការផ្លាស់ប្តូរទាំងឥរិយាបថ និង អាកប្បកិរិយា។ ការដែលសំខាន់នោះគឺ ត្រូវចាប់ផ្តើមផ្លាស់ប្រែឥឡូវនេះ។

ព្រះវិញ្ញាណនឹងជួយអ្នកអោយផ្លាស់ប្រែ ក្រោយពីអ្នកបានក្លាយជាគ្រិស្តបរិស័ទ។ កាឡាទី ៥:២២-២៦ បានថែងអំពី ផលផ្លែដែលកើតមកពីព្រះវិញ្ញាណ។ អ្នកត្រូវតែអនុញ្ញាតអោយព្រះវិញ្ញាណគ្រប់គ្រងជីវិតរបស់អ្នករាល់ថ្ងៃ។ នៅពេលឃើញមានការផ្លាស់ប្រែជាច្រើនកើតមាននៅក្នុងជីវិតរបស់អ្នក នោះអ្នកនឹងអាចដឹងថា ខ្លួនឯងជាគ្រិស្តបរិស័ទ។

# ជំពូកទី៣

## ទំនាក់ទំនងផ្ទាល់ខ្លួនរបស់ខ្ញុំជាមួយនឹងព្រះយេស៊ូគ្រិស្ត

ការក្លាយជាគ្រិស្តបរិស័ទជារឿងផ្ទាល់ខ្លួនរវាងអ្នកជាមួយនឹងព្រះជាម្ចាស់ ។ ព្រះជាម្ចាស់មិនបានចាត់ទុកយើងជាម៉ាស៊ីនកុំព្យូទ័រនោះឡើយ ។ ព្រះអង្គស្គាល់ឈ្មោះយើងម្នាក់ៗ ហើយស្រឡាញ់យើងខ្លាំងជាទីបំផុត ។ ប្រសិនបើអ្នកសំរេចចិត្តធ្វើជាគ្រិស្តបរិស័ទ នោះមានន័យថា អ្នកពិតជាចង់មានទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះយេស៊ូគ្រិស្ត ។ ការរស់ជីវិតជាគ្រិស្តបរិស័ទគឺមានន័យថា យើងក្លាយជាមិត្តសំឡាញ់របស់ព្រះយេស៊ូគ្រិស្ត ។

កថាខណ្ឌខាងលើស្តាប់ទៅដូចជាត្រឹមត្រូវ ។ តើការពិតយ៉ាងម៉េចដែរ? តើមានភាពងាយស្រួលបែបណាទៅក្នុងការក្លាយជាមិត្តសំឡាញ់របស់ព្រះយេស៊ូ? តើមនុស្សម្នាក់អាចស្គាល់ព្រះជាម្ចាស់ដោយរបៀបណា? ហេតុអ្វីបានជាយើងត្រូវជឿសំដីរបស់អ្នកដទៃដែលប្រាប់យើងអំពីព្រះជាម្ចាស់? ប្រសិនបើព្រះសព្វព្រះហប្ញទ័យចង់អោយយើងក្លាយជាមិត្តរបស់ទ្រង់ តើយើងនឹងភ្ជាប់ទំនាក់ទំនងជាមួយនឹងព្រះអង្គដែលយើងមើលពុំឃើញ មិនឮសំលេង មិនដឹងពីអារម្មណ៍របស់ទ្រង់ដូចមនុស្សទូទៅដែលជាមិត្តរបស់យើង ដោយរបៀបណា? តើយើងចាប់ផ្តើមពីចំនុចត្រង់ណាទៅ ដើម្បីអោយកាន់តែស្គាល់ព្រះជាម្ចាស់ដែលយើងមើលពុំឃើញ? សំនួរទាំងនេះនឹងទទួលនូវការបកស្រាយនៅក្នុងជំពូកនេះ ។

### ក. ហេតុអ្វីបានជាចាំបាច់ត្រូវកសាងទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះយេស៊ូ?

ប្រសិនបើចង់ឆ្លើយសំនួរនេះ យើងចាំបាច់ត្រូវតែឆ្លើយសំនួរជាមូលដ្ឋានខ្លះទៀតសិន ។ តើអ្នកជឿថាមានព្រះជាម្ចាស់ដែរឬទេ? តើអ្នកជឿថាព្រះយេស៊ូគ្រិស្តជាព្រះជាម្ចាស់ដែរឬទេ? តើអ្នកជឿថា ព្រះយេស៊ូគ្រិស្តបង់ថ្លៃលោះចំពោះអំពើបាបរបស់អ្នក នៅពេលទ្រង់សុគតនៅលើឈើឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញ៣ថ្ងៃក្រោយដែរឬទេ? ប្រសិនបើអ្នកអាចឆ្លើយនឹងសំនួរទាំងនេះបាន អ្នកអាចសិក្សាស៊ីជំរៅនៅក្នុងមេរៀននេះបានហើយ ។

១. ហេតុអ្វីបានជាព្រះជាម្ចាស់បង្កើតអ្នកមក

តើព្រះជាម្ចាស់គ្រាន់តែបង្កើតអ្នកមក ដើម្បីអោយធំដឹងក្តី រៀបការ មានកូន បង់ថ្លៃទឹកឬភ្លើង ចាស់ចូលនិវត្តន៍ ហើយស្លាប់ឬ? នៅជំពូកទី១នៃព្រះគម្ពីរបានចែងច្បាស់ថា ក្នុងចំណោមអ្វីៗដែលព្រះជាម្ចាស់បានបង្កើត មនុស្សមានសារៈសំខាន់ជាងគេ ។ យើងម្នាក់ៗពិសេសចំពោះព្រះអង្គ ។

ព្រះបង្កើតអ្នកមក ដើម្បីអោយយើងរស់ជាមួយព្រះអង្គអស់កល្បជានិច្ច ស្គាល់ព្រះអង្គកាន់តែច្បាស់ និងស្រឡាញ់ទ្រង់ ។ ព្រះយេស៊ូមានបន្ទូលយ៉ាងច្បាស់ចំពោះចំនុចនេះ នៅក្នុងសេចក្តីអធិស្ឋានរបស់ព្រះអង្គ មុនពេលព្រះអង្គសុគត ។

យ៉ូហាន ១៧:៣

**រីឯជីវិតអស់កល្បជានិច្ចនោះ គឺអោយគេស្គាល់ព្រះអង្គ ដែលជាព្រះជាម្ចាស់ដ៏ពិតតែមួយគត់ និង អោយគេស្គាល់ព្រះយេស៊ូគ្រិស្ត ដែលព្រះអង្គចាត់អោយមក។**

សេចក្តីពិតដែលមានអំណាចនៅក្នុងខគម្ពីរនេះ អាចជួយអោយយើងយល់ ហើយធ្វើអោយគ្រប់ទាំងការទទួលខុសត្រូវនិងសំពាធទាំងឡាយដែលមានក្នុងជីវិតនេះ ត្រឡប់ទៅរកសភាពដើមរបស់វាវិញ។ ប្រសិនបើយើងដាក់ព្រះជាម្ចាស់ជាអត្ថិភាពទីមួយនៅក្នុងជីវិតរបស់យើង យើងនឹងអាចបំពេញកិច្ចការសំខាន់ជាងគេ ទៅតាមគំរោងរបស់ព្រះអង្គ ដែលទ្រង់បានបង្កើតរូបយើងមកនៅលើផែនដីនេះ។

**២. តើអ្វីទៅដែលអាចបំពេញជីវិតនេះបាន?**

តើមានមនុស្សប៉ុន្មាននាក់ដែលយើងស្គាល់ ហើយពួកគាត់កំពុងតែស្វែងរកភាពពេញលេញសំរាប់ជីវិតនេះ? តើអ្វីទៅដែលអាចបំពេញពួកគាត់បាន? លុយ? ស្វាមី ឬភរិយាស្អាត? អំណាច? កេរ្តិ៍ឈ្មោះល្អ? ជោគជ័យធំៗជាច្រើន? មនុស្សទាំងនៅអតីតកាល និងបច្ចុប្បន្នកំពុងស្វែងរកអត្ថន័យពិតនៃជីវិត។ ព្រះបាទសាឡូម៉ូនជាមនុស្សដែលមានប្រាជ្ញាលើសគេ។ ព្រះអង្គជាមហាក្សត្រដែលមានអំណាច និងមានទ្រព្យសម្បត្តិ។ ក្នុងពេលដែលព្រះអង្គគង់នៅមានព្រះជន្ម ព្រះអង្គកម្រនឹងមានឱកាសរកឃើញរបស់ ដែលធ្វើអោយព្រះអង្គស្អប់ព្រះទ័យណាស់។ ព្រះអង្គបានមានបន្ទូលប្រាប់អំពីរឿងនេះ នៅក្នុងសៀវភៅសាស្តា។ សេចក្តីសន្និដ្ឋានចុងក្រោយរបស់ព្រះអង្គបានបញ្ជាក់ថា ផ្លូវឆ្ពោះទៅរកសុភមង្គល មិនត្រូវការលុយ អំណាច ឬក៏ឱកាសល្អនោះឡើយ។

សាស្តា ១២:១៣-១៤

**អ្វីៗទាំងប៉ុន្មាន ដូចមានវិយាយខាងលើ យើងអាចទាញជាសេចក្តីសន្និដ្ឋានថា ត្រូវគោរពកោតខ្លាចព្រះជាម្ចាស់ ហើយកាន់តាមបទបញ្ជារបស់ព្រះអង្គ។ នេះហើយជាការដែលមនុស្សគ្រប់ៗរូបត្រូវធ្វើ។ ព្រះម្ចាស់នឹងវិនិច្ឆ័យកិច្ចការទាំងប៉ុន្មានដែលមនុស្សធ្វើ ទោះបីជាអំពើដែលគេធ្វើដោយលាក់កំបាំង ហើយជាការល្អ ឬអាក្រក់ក្តី។**

ប្រាជ្ញាដែលព្រះជាម្ចាស់បានប្រទានដល់ព្រះបាទសាឡាម៉ូន ក៏មានចែងនៅក្នុងសៀវភៅសុភាសិតផងដែរ។

សុភាសិត ៩:១០

**ការគោរពកោតខ្លាចព្រះអម្ចាស់ ជាប្រភពនៃប្រាជ្ញា ការស្គាល់ព្រះជាម្ចាស់ជាប្រភពនៃចំណេះដឹងរបស់ប្រជាជនដ៏វិសុទ្ធ។**

ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានសភាពច្បាស់លាស់។ ប្រសិនបើអ្នកចង់ស្វែងរកជីវិតពិត ចូរដាក់អត្ថិភាពខ្ពស់ចំពោះក្នុងស្គល់ព្រះជាម្ចាស់តាមវិធីផ្ទាល់ខ្លួន។ នៅក្នុងសៀវភៅ "ស្វែងយល់អំពីព្រះជាម្ចាស់" របស់លោក **ជេ អាយ ផាកឺ** បានប្រាប់អំពីគ្រោះថ្នាក់នៃការមិនរស់ជាមួយនឹងព្រះជាម្ចាស់។ "ការមិនស្មោះត្រង់ជាមួយនឹងការសិក្សាអំពីព្រះជាម្ចាស់ អ្នកកំពុងតែធ្វើអោយខ្លួនឯងអោយដួលចុះ និងធ្វើកិច្ចការលេលា ដោយសារជីវិតពេញ

ដោយភាពងងឹតមើលមិនឃើញ គ្មានទិសដៅ ហើយមិនយល់អ្វីទាំងអស់ដែលនៅជុំវិញខ្លួន ។ បែបនេះ អ្នកកំពុងខ្ជះខ្ជាយជីវិតខ្លួនឯង ហើយព្រមទាំងឈានទៅដល់ការបាត់បង់ព្រលឹងទៀតផង" ។

## ខ. តើទំនាក់ទំនងប្រភេទណាដែលយើងអាចបង្កើតជាមួយនឹងព្រះយេស៊ូ?

តើអ្នកធ្លាប់ឆ្ងល់ខ្លួនឯងទេថា "តើមិត្តភាពបែបណា ដែលមនុស្សតូចទាបដូចជាខ្ញុំអាចបង្កើតឡើងជាមួយនឹងព្រះជាម្ចាស់ ដែលជាព្រះអាទិករបង្កើតចក្រវាឡទាំងមូល?" ។ ការពិតនោះគឺ ព្រះជាម្ចាស់ពិតជាចង់ធ្វើមិត្តរបស់យើងមែន ។

### ១. សូមកុំស្វែងរកឫទ្ធិបដិហារអស្ចារ្យខ្លាំងពេក

ព្រះគម្ពីរមិនបានលើកទឹកចិត្ត អោយយើងស្វែងរកឫទ្ធិបដិហាជាមួយនឹងព្រះជាម្ចាស់ឡើយ ។ សូមកុំរំពឹងថានឹងមើលឃើញព្រះជាម្ចាស់ដោយផ្ទាល់ ឬក៏ឮព្រះអង្គមានបន្ទូលមកកាន់អ្នកខ្លាំង១ពីលើស្ថានសួគ៌ ដូចសំលេងផ្គរលាន់អោយសោះ ។

ព្រះជាម្ចាស់ជាវិញ្ញាណ ដូច្នេះទំនាក់ទំនងជាមួយព្រះអង្គក៏ត្រូវធ្វើតាមវិញ្ញាណដែរ ។ ប៉ុន្តែព្រះជាម្ចាស់ទ្រង់ឈ្វេងយល់ថា យើងជាមនុស្សមានសាច់ឈាម រស់នៅក្នុងពិភពលោកនេះដែលមានការប្រាស្រ័យទាក់ទងគ្នាក្នុងរូបភាពជាសាច់ឈាមដែលអាចមើលឃើញ ។ ហេតុដូចនេះហើយបានជាព្រះអង្គបញ្ជូនព្រះយេស៊ូអោយមកយកកំណើតជាមនុស្សលោកធម្មតានៅក្នុងចំណោមយើង ។ ព្រះយេស៊ូមិនមែនជាវិញ្ញាណទេ តែព្រះអង្គរស់ជាមនុស្សរយៈ៣៣ឆ្នាំនៅលើផែនដីនេះ ។ ព្រះអង្គមានរូបកាយដូចជាយើងរាល់គ្នាដែរ ។ ព្រះអង្គហត់ ព្រះអង្គឃ្លាន ហើយបែកញើសដូចជាយើងទាំងអស់គ្នាដែរ ។

កាលដែលព្រះអង្គមានព្រះជន្មនៅលើផែនដីនេះ ព្រះអង្គបានបង្កើតមិត្តភាពជាមួយនឹងមនុស្សជាច្រើន ។ ឥឡូវនេះ ព្រះអង្គកំពុងរស់នៅឯស្ថានបរមសុខ ហើយព្រះអង្គនៅតែចង់មានទំនាក់ទំនងជាមួយអស់អ្នកដែលចង់មានទំនាក់ទំនងជាមួយនឹងទ្រង់ ។ ប៉ុន្តែព្រះអង្គមិនមែននៅមួយកន្លែង ហើយចាំតែនិយាយមកកាន់យើងតែម្នាក់ប៉ុណ្ណោះទេ ។ ព្រះអង្គជាមិត្តរបស់អ្នក ហើយនៅក្នុងពេលជាមួយគ្នានេះដែរ ព្រះអង្គក៏គង់នៅចាំជួយគ្រិស្តបរិស័ទ ២៥០លាននាក់ផ្សេងទៀតផងដែរ ។

ប្រហែលជាយើងមានគំនិតថា "ពីមុនមក ខ្ញុំមិនដែលបង្កើតទំនាក់ទំនងខាងវិញ្ញាណទាល់តែសោះ ។ តើខ្ញុំចាប់ផ្តើមពីណាទៅ?" សូមកុំព្រួយបារម្ភចំពោះការស្វែងរកព្រះជាម្ចាស់ ។ ព្រះអង្គទតឃើញអ្នករួចហើយ ។ ព្រះអង្គរកយើងឃើញ មុនពេលយើងមានចំណាប់អារម្មណ៍ជាមួយនឹងព្រះអង្គទៅទៀត ។ ព្រះយេស៊ូមានបន្ទូលយ៉ាងច្បាស់ថា ព្រះអង្គជាអ្នកដែលចាប់ផ្តើមមិត្តភាពជាមួយយើង ។ "ប្រសិនបើព្រះបិតាដែលចាត់ខ្ញុំអោយមកមិនទាក់ទាញចិត្តគេទេ គ្មាននរណាអាចមករកខ្ញុំបានឡើយ" (យ៉ូហាន ៦:៤៤) ។

## ២. តើខ្ញុំត្រូវតែឈប់ធ្វើតាមចិត្តខ្លួនឯងឬ?

ព្រះជាម្ចាស់មិនបានបង្ខំយើងអោយធ្វើជាមិត្តរបស់ព្រះអង្គឡើយ ។ អ្នកមានសិទ្ធិជ្រើសរើសដើម្បីបង្កើតទំនាក់ទំនាក់ទំនងជាមួយនឹងព្រះអង្គ ។ នៅពេលដែលទំនាក់ទំនងរវាងអ្នកជាមួយនឹងព្រះជាម្ចាស់កាន់តែស៊ីជំរៅ នឹងមានការផ្លាស់ប្រែខ្លះចំពោះអាកប្បកិរិយា  អារម្មណ៍ និងឥរិយាបថរបស់អ្នក ។ នេះមិនមែនមានន័យថា ព្រះជាម្ចាស់ចង់អោយយើងក្លាយជាមនុស្សម្នាក់ទៀតនោះឡើយ ។ តើព្រះជាម្ចាស់គាប់ព្រះទ័យអោយយើងផ្លាស់ប្រែមែនទេ? ពិតមែន ។ ព្រះអង្គគាប់ព្រះទ័យអោយយើងមានអាកប្បកិរិយាដូចជាព្រះគ្រិស្ត ។ ទាំងសកម្មភាព ទាំងគំនិតរបស់យើងដែលពោរពេញដោយអំពើបាប  ត្រូវយកចេញពីជីវិតរបស់យើង ។ ប៉ុន្តែភាពពិតរបស់យើង គឺចេញពីខាងក្នុងមកវិញ គឺបុគ្គលិកលក្ខណៈរបស់យើងដែលជាអំណោយទានមកពីព្រះជាម្ចាស់ ។

ប្រសិនបើយើងពិតជាស្រឡាញ់នរណាម្នាក់យ៉ាងខ្លាំង  យើងប្រហែលជាចង់កែប្រែឥរិយាបថមិនលល្អចេញដើម្បីកុំអោយរំខានដល់មិត្តរបស់យើង ។ នេះជារឿងធម្មតា និងសមរម្យជាទីបំផុត ។ វាក៏ដូចគ្នាជាមួយនឹងទំនាក់ទំនងរវាងយើងនិងព្រះជាម្ចាស់ផងដែរ ។ យើងចង់មានតែអាកប្បកិរិយា និងឥរិយាបថណាដែលធ្វើអោយព្រះអង្គគាប់ព្រះទ័យប៉ុណ្ណោះ ហើយយើងនឹងជំរុះអាកប្បកិរិយា និង ឥរិយាបថទាំងឡាយណាដែលមិនគាប់ព្រះទ័យព្រះអង្គចេញ ។

## ៣. ព្រះជាម្ចាស់គាប់ព្រះទ័យចង់មានមិត្តភាពដ៏ពិសេសជាមួយនឹងយើង

យើងធ្លាប់មានមិត្តភាពជាមួយនឹងមិត្តភក្តិរបស់យើង ដែលមានអាយុស្មើគ្នា ។ គាត់កាលយើងស្គាល់មិត្តរបស់យើងដោយរៀនជាមួយគ្នា  ធ្វើការជាមួយគ្នា  ចូលរួមនៅក្នុងក្រុមជំនុំជាមួយគ្នា  ឬក៏នៅផ្ទះជិតគ្នា ។ មិនមែនជាញឹកញាប់ មនុស្សម្នាក់ៗអាចមានមិត្តភក្តិជាអ្នកមាន ឬក៏អ្នកល្បីល្បាញនោះឡើយ ។ នេះជាមិត្តភាពមួយដែលខុសពីមិត្តភាពជាមួយនឹងអ្នកជិតខាងរបស់យើង ។

ព្រះជាម្ចាស់គាប់ព្រះទ័យចង់មានមិត្តភាពពិសេសជាមួយនឹងយើង ។ ប៉ុន្តែព្រះអង្គជាព្រះជាម្ចាស់ ជាព្រះដែលបង្កើតអ្វីៗទាំងអស់ ហើយត្រួតត្រាលើសកលលោកទាំងមូល ។ ហើយព្រះអង្គក៏ជាព្រះដែលយាងមកសុគតនៅលើឈើឆ្កាង ដើម្បីអោយយើងមានជីវិតថ្មីជាមួយព្រះអង្គដែរ គឺជីវិតអស់កល្ប ។ ព្រះយេស៊ូគឺជាព្រះសង្គ្រោះរបស់យើង  ជាអ្នកដឹកនាំយើង  ហើយព្រះអង្គក៏គាប់ព្រះទ័យចង់ធ្វើជាមិត្តរបស់យើងផងដែរ ។

មិត្តភាពរវាងយើងនឹងព្រះជាម្ចាស់មានលក្ខណៈពិសេស ហើយមិនស្មើគ្នាដូចយើងនិងមិត្តភក្តិរបស់យើងនោះឡើយ ។ យើងជាមិត្តជិតស្និទ្ធរបស់ព្រះអង្គ  មិនមែនមានន័យថាយើងមានឋានៈស្មើព្រះអង្គនោះឡើយ ។ ព្រះអង្គនៅតែជាអ្នកដឹកនាំយើង  ហើយយើងនៅតែជាអ្នកបំរើរបស់ព្រះអង្គ ។ ព្រះអង្គនៅតែរំពឹងថា យើងនឹងប្រណិបត្តិតាមវិន័យរបស់ព្រះអង្គ ។ មិត្តភាពដែលយើងមានជាមួយនឹងព្រះអង្គ មិនមែនផ្តល់សិទ្ធិអោយយើងជ្រើសរើសគោរពវិន័យរបស់ទ្រង់តាមតែចិត្តយើងនោះឡើយ ។

ព្រះយេស៊ូប្រើទំនាក់ទំនងរបស់អ្នកគង្វាលជាមួយនឹងចៀម ដើម្បីអោយយើងយល់ថា ទំនាក់ទំនងបែបណាដែលយើងមានជាមួយព្រះអង្គ។ នៅក្នុងសៀវភៅយ៉ូហានជំពូកទី១០ ព្រះយេស៊ូបានមានបន្ទូលថា ព្រះអង្គជាអ្នកគង្វាលដ៏ល្អសំរាប់ចៀមរបស់ព្រះអង្គ។

**យ៉ូហាន ១០:១៤-១៥**

**ខ្ញុំហ្នឹងហើយជាអ្នកគង្វាលដ៏ល្អ។ ខ្ញុំស្គាល់ចៀមរបស់ខ្ញុំ ចៀមរបស់ខ្ញុំក៏ស្គាល់ខ្ញុំ គឺដូចជាព្រះបិតាស្គាល់ខ្ញុំ ហើយខ្ញុំស្គាល់ព្រះបិតាដូច្នោះដែរ។ ខ្ញុំស៊ូប្តូរជីវិត ដើម្បីចៀមរបស់ខ្ញុំ។**

អ្នកគង្វាលស្រឡាញ់ចៀមរបស់គាត់ ប៉ុន្តែគាត់នៅតែជាអ្នកគង្វាល មិនមែនជាចៀមទេ។ ទោះជាចៀមស្រឡាញ់អ្នកគង្វាលប៉ុនណាក៏ដោយ ចៀមទាំងនោះនឹងមិនអាចក្លាយជាអ្នកគង្វាលបានឡើយ។ អ្នកគង្វាលនិងចៀមមានលក្ខណៈនិងកិច្ចការទទួលខុសត្រូវផ្សេងគ្នា ហើយពួកគេក៏ជាមិត្តជិតស្និទ្ធផងដែរ។

យើងអាចក្លាយជាមិត្តជិតស្និទ្ធជាមួយនឹងព្រះជាម្ចាស់បាន។ ប៉ុន្តែនេះមិនមែនមានន័យថា ព្រះជាម្ចាស់ត្រូវតែធ្វើអោយបាននូវរាល់តំរូវការរបស់យើងនោះឡើយ។ ព្រះជាម្ចាស់គាប់ព្រះទ័យធ្វើអ្វី គឺតាមតែព្រះទ័យរបស់ព្រះអង្គ ព្រោះព្រះអង្គជាព្រះជាម្ចាស់។ លោកយ៉ូបនៅក្នុងសម្ពន្ធមេត្រីចាស់ បានសុំអោយព្រះជាម្ចាស់ពន្យល់អំពីបញ្ហាទាំងឡាយដែលមានឡើងនៅក្នុងជីវិតរបស់គាត់។ គាត់ស្តីបន្ទោសព្រះជាម្ចាស់ ដែលអនុញ្ញាតអោយបញ្ហាទាំងនោះកើតមានចំពោះគាត់។ ច្រើនឆ្នាំក្រោយមក ព្រះជាម្ចាស់ក៏ឆ្លើយតបទៅលោកយ៉ូប ដោយស្តីបន្ទោសគាត់ចំពោះឥរិយាបថមិនល្អដែលគាត់បានប្រព្រឹត្តចំពោះព្រះអង្គ។ សូមអាន យ៉ូប ៣៨-៤១។ ព្រះជាម្ចាស់គាប់ព្រះទ័យចង់បង្ហាញក្តីស្រឡាញ់មកកាន់យើង ប៉ុន្តែយើងត្រូវប្រយ័ត្នក្នុងការផ្តល់កិត្តិយស និងគោរពព្រះអង្គ។

## គ. សិក្សាអំពីព្រះជាម្ចាស់

តើគ្រិស្តបរិស័ទថ្មីចាប់ផ្តើមមិត្តភាពដ៏ពិសេសជាមួយនឹងព្រះជាម្ចាស់ដោយរបៀបណាទៅ? គោលការណ៍ជាច្រើនមានចែងនៅទីនេះ។ ប្រសិនបើយើងមិនសូវស្គាល់ព្រះជាម្ចាស់ យើងគួរសិក្សាអោយបានច្រើនអំពីព្រះអង្គ។ ធ្វើបែបនេះ ក្តីស្រឡាញ់និងការសរសើររបស់យើងចំពោះព្រះអង្គនឹងកើនឡើង។

### ១. សិក្សាអំពីព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរ

យើងមានព័ត៌មានជាច្រើនស្តីអំពីព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរ។ ប្រសិនបើអ្នកចង់សិក្សាអំពីព្រះជាម្ចាស់ សូមអានព្រះគម្ពីរ។ នៅពេលអាន សូមសួរខ្លួនឯង តើជំពូកនេះប្រាប់ខ្ញុំអ្វីខ្លះអំពីព្រះជាម្ចាស់? តើព្រះអង្គបានធ្វើអ្វីខ្លះនៅក្នុងជីវិតរបស់មនុស្សទាំងនេះ? តើព្រះអង្គនៅស្ងាត់ស្ងៀម? នៅត្រង់នេះ តើបន្ទូលអ្វីខ្លះដែលព្រះអង្គបានសន្យា?

សៀវភៅ៤ក្បាលដំបូងនៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីថ្មីគឺ ម៉ាថាយ ម៉ាកុស លូកា យ៉ូហាន បានឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវជីវិតដ៏ពិតរបស់ព្រះគ្រិស្ត កាលដែលព្រះអង្គយាងមកលើផែនដីនេះ។ ប្រសិនបើយើងចង់ស្គាល់

លក្ខណៈរបស់ព្រះជាម្ចាស់ សូមមើលពីទង្វើរបស់ព្រះយេស៊ូ ។ មុនពេលដែលព្រះអង្គសុគត ព្រះយេស៊ូបានបរិភោគរួមជាមួយនឹងពួកសាវ័កជាលើកចុងក្រោយ ។ លោកភីលីពបានទូលសុំអោយព្រះអង្គអោយបង្ហាញព្រះបិតាដល់ពួកសាវ័កទាំងអស់ ។

យ៉ូហាន ១៤:៩-១០

**ព្រះយេស៊ូមានបន្ទូលទៅគាត់ថា: "ភីលីពអើយ ខ្ញុំនៅជាមួយអ្នកតាំងពីយូរមកហើយ ម្ដេចអ្នកនៅតែមិនស្គាល់ខ្ញុំ!។ អ្នកណាបានឃើញខ្ញុំក៏ដូចបានឃើញព្រះបិតាដែរ។ ហេតុដូចម្ដេចជាអ្នកថា សូមបង្ហាញព្រះបិតាអោយយើងខ្ញុំបានឃើញផងដូច្នេះ? តើអ្នកមិនជឿថា ខ្ញុំនៅក្នុងព្រះបិតា ហើយព្រះបិតាគង់នៅក្នុងខ្ញុំទេឬ? សេចក្ដីដែលខ្ញុំនិយាយប្រាប់អ្នករាល់គ្នា មិនមែនចេញពីខ្ញុំផ្ទាល់ទេ គឺព្រះបិតាដែលស្ថិតនៅជាប់នឹងខ្ញុំ ទ្រង់បំពេញកិច្ចការរបស់ព្រះអង្គ។**

ប្រសិនបើអ្នកចង់ស្វែងយល់ថែមទៀតអំពី របៀបដែលព្រះជាម្ចាស់ប្រព្រឹត្តចំពោះអ្នក សូមមើលពីរបៀបដែលព្រះយេស៊ូប្រព្រឹត្តចំពោះមនុស្សនៅសម័យនោះ ។ ព្រះគម្ពីរបានប្រាប់យើងយ៉ាងច្បាស់អំពីអ្វីដែលព្រះជាម្ចាស់គាប់ព្រះទ័យ និងអ្វីដែលព្រះអង្គមិនគាប់ព្រះទ័យ ។ យើងអាចដឹងថាកិច្ចការណាដែលធ្វើអោយព្រះអង្គអរព្រះទ័យ និងកិច្ចការណាដែលធ្វើអោយព្រះមិនគាប់ព្រះទ័យ ។

នៅក្នុងការសិក្សាអំពីព្រះជាម្ចាស់ យើងត្រូវស្វែងយល់អំពីព្រះបន្ទូលដែលព្រះអង្គមានបន្ទូលចំពោះព្រះអង្គផ្ទាល់ ។ សូមសិក្សាអំពីភាពវិសុទ្ធ ក្ដីស្រឡាញ់ ក្ដីមេត្តាករុណា ភាពសច្ចៈទៀងត្រង់ ភាពអត់ធ្មត់ និងភាពយុត្តិធម៌របស់ព្រះអង្គ ។ កាន់តែសិក្សាអំពីព្រះជាម្ចាស់ យើងកាន់តែកោតស្ញប់ស្ញែងព្រះអង្គ ។ ហើយព្រះអង្គក៏ចិត្តទុកដាក់ចំពោះគ្រប់កិច្ចការទាំងតូចទាំងធំ ដែលកើតមានឡើងនៅក្នុងជីវិតរបស់យើងផងដែរ ។

**២. កុំសន្មត់ថាព្រះជាម្ចាស់មានព្រះតំរិះដូចយើង**

ជួនកាល មនុស្សខ្លះព្យាយាមនិយាយមុនអំពី កិច្ចការរបស់ព្រះជាម្ចាស់ ក្នុងពេលដែលព្រះអង្គមិនទាន់ឆ្លើយតបនៅឡើយ ។ ព្រះជាម្ចាស់កំពុងកាត់មនុស្សប្រភេទនេះ ហេតុដូច្នេះហើយបានជាគាត់ឈឺ ។ ឬពេលខ្លះគេគិតថាថ្ងៃនេះ ព្រះជាម្ចាស់ហាក់ដូចជានៅឆ្ងាយពីខ្ញុំ ប្រហែលជាខ្ញុំបានប្រព្រឹត្តអ្វីមួយមិនគាប់ព្រះទ័យព្រះអង្គហើយមើលទៅ ។ យើងត្រូវប្រយ័ត្នអំពីការមិនផ្ដល់ការគោរពដល់ព្រះជាម្ចាស់ ហើយគិតថាព្រះអង្គមានព្រះតំរិះដូចយើង ។ ព្រះជាម្ចាស់មានបន្ទូលយ៉ាងច្បាស់អំពីចំនុចនេះ នៅក្នុងសៀវភៅអេសាយក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ។

អេសាយ ៥៥:៨-៩

**ព្រះអម្ចាស់មានព្រះបន្ទូលថា: គំនិតយើងខុសប្លែកពីគំនិតអ្នករាល់គ្នា រីឯរបៀបដែលយើងប្រព្រឹត្តក៏ខុសប្លែកពីរបៀបដែលអ្នករាល់គ្នាប្រព្រឹត្តដែរ។ មេឃខ្ពស់ជាងផែនដីយ៉ាងណា របៀបដែលយើងប្រព្រឹត្ត ក៏ខុសប្លែកពីរបៀបដែលអ្នករាល់គ្នាប្រព្រឹត្ត ហើយគំនិតរបស់យើងក៏ខុសប្លែកពីគំនិតរបស់អ្នករាល់គ្នាយ៉ាងនោះដែរ។**

តើនេះមានន័យថា យើងមិនអាចស្គាល់ព្រះជាម្ចាស់ច្បាស់ទេឬ? មិនអញ្ចឹងទេ។ ព្រះគម្ពីរបានចែងច្បាស់ថា ព្រះជាម្ចាស់គាប់ព្រះទ័យអោយយើងម្នាក់ៗស្គាល់ព្រះអង្គដោយផ្ទាល់ ហើយស្រឡាញ់ព្រះអង្គថែមទៀតផង។ បើយើងមិនអាចស្គាល់ព្រះអង្គច្បាស់ ព្រះអង្គក៏មិនអោយយើងធ្វើអញ្ចឹងដែរ។ ប៉ុន្តែម៉្យាងវិញទៀត ដោយសារព្រះជាម្ចាស់ធំមហិមានិងអស្ចារ្យ ទើបយើងមិនអាចមានលទ្ធភាពសិក្សាអោយគ្រប់ជ្រុងជ្រោយអំពីព្រះអង្គ។ សូម្បីតែមនុស្សដែលយើងរស់នៅជាមួយដូចជាប្រពន្ធ ឬប្តី ឪពុក ឬម្តាយរបស់យើង ក៏យើងមិនអាចយល់ពីពួកគាត់ទាំងអស់បានដែរ។ តើនៅក្នុងមួយជីវិតនេះ យើងធ្លាប់ស្គាល់មនុស្សម្នាក់ច្បាស់ដែរឬទេ?

**៣. ដឹងអំពីព្រះជាម្ចាស់ ឬស្គាល់ព្រះជាម្ចាស់**

ការសិក្សាសេចក្តីពិតស្តីអំពីព្រះយេស៊ូនៅក្នុងព្រះគម្ពីរ មិនអាចធ្វើអោយយើងក្លាយជាមិត្តស្និតស្នាលរបស់ព្រះអង្គបានឡើយ។ អ្នកប្រហែលជាឮ និងឃើញប្រធានាធិបតីរបស់សហរដ្ឋអាមេរិក ឬក៏មេដឹកនាំនៅប្រទេសមួយចំនួន ប៉ុន្តែអ្នកមិនអាចក្លាយជាមិត្តរបស់ពួកគាត់បានឡើយ។ យើងត្រូវចំណាយពេលជាមួយនឹងពួកគាត់ជាមុនសិន ទើបយើងអាចនិយាយបានថា ពួកគាត់ជាមិត្តរបស់យើង។

នៅពេលដែលព្រះយេស៊ូមានព្រះជន្មនៅលើផែនដីនេះ ប្រជាជននៅតំបន់នោះនិយាយភាសាក្រិក។ ភាសាក្រិកនេះមាន២ពាក្យសំរាប់ពាក្យ "Knowing"។ ពាក្យមួយមានន័យថា ដឹងអំពីនរណាម្នាក់។ ហើយពាក្យមួយទៀតមានន័យថា ស្គាល់ដោយផ្ទាល់ជាមួយនរណាម្នាក់។ មានមនុស្សជាច្រើនដឹងឮអំពីព្រះជាម្ចាស់ ប៉ុន្តែពួកគេមិនដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះយេស៊ូ ហើយសុំយាងព្រះអង្គមកធ្វើជាព្រះសង្គ្រោះ និងយាងមកដឹកនាំពួកគេម្តងណាឡើយ។ ពួកគេជាមនុស្សដែលកាន់សាសនា ហើយប្រកាសអំពីព្រះជាម្ចាស់ និងធ្វើអំពើល្អ។ ព្រះយេស៊ូបានមានបន្ទូលអំពីចំនុចនេះនៅក្នុងសៀវភៅម៉ាថាយ។

**ម៉ាថាយ ៧:២១-២៣**

**អ្នកដែលចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ មិនមែនជាអ្នកដែលគ្រាន់តែហៅខ្ញុំថា "ព្រះអម្ចាស់! ព្រះអម្ចាស់!" ប៉ុណ្ណោះទេ គឺអ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាខ្ញុំ ដែលគង់នៅស្ថានបរមសុខនោះវិញ។ នៅថ្ងៃនោះ នឹងមានមនុស្សជាច្រើនពោលមកខ្ញុំថា "ព្រះអម្ចាស់ ព្រះអម្ចាស់អើយ! យើងខ្ញុំធ្លាប់ថ្លែងព្រះបន្ទូលក្នុងព្រះនាមព្រះអង្គ យើងខ្ញុំធ្លាប់ដេញអារក្សក្នុងព្រះនាមព្រះអង្គ ហើយយើងខ្ញុំក៏ធ្លាប់ធ្វើកិច្ចការអស្ចារ្យជាច្រើន ក្នុងព្រះនាមព្រះអង្គដែរ"។ ពេលនោះខ្ញុំនឹងប្រកាសប្រាប់អ្នករាល់គ្នាថា "ពួកអ្នកប្រព្រឹត្តអំពើទុច្ចរិតអើយ! ចូរថយចេញអោយឆ្ងាយពីខ្ញុំទៅ ខ្ញុំមិនដែលស្គាល់អ្នករាល់គ្នាទេ!"។**

ស្គាល់ព្រះយេស៊ូដោយផ្ទាល់មិនមែនជាការពិបាកនោះឡើយ។ យើងចាប់ផ្តើមដោយធ្វើការជ្រើសរើស។ តើអ្នកចង់ស្គាល់ព្រះអង្គដោយផ្ទាល់ដែរឬទេ? ប្រហែលជាអ្នកមិនយល់ច្បាស់អំពីព្រះជាម្ចាស់ ប៉ុន្តែអ្នកនៅតែអាចចាប់ផ្តើមចូលទៅស្គាល់ព្រះអង្គតាមវិធីផ្ទាល់ខ្លួនរបស់អ្នក។ ព្រះយេស៊ូមានបន្ទូលនៅក្នុងម៉ាថាយ៧:២១ថា ការ

ប្រណិបត្តិព្រះជាម្ចាស់ជាជំហានដំបូង ក្នុងការមានទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះអង្គ ។ ១យ៉ូហាន២:៣ ក៏ចែងដូចគ្នាដែរ ។

យើងអាចសិក្សាបន្ថែមទៀតអំពីព្រះជាម្ចាស់ ដោយសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃ និងអានសៀវភៅគ្រិស្តបរិស័ទដទៃទៀត ។ ប្រសិនបើអ្នកមិនបានធ្វើបែបនេះទេ អ្នកនឹងបាត់បង់ចំនុចដ៏សំខាន់បំផុតនៅក្នុងជីវិត ។ យើងអាចពង្រីកចំណេះដឹងផ្ទាល់ខ្លួនអំពីព្រះជាម្ចាស់ ដោយយកសេចក្តីបង្រៀនរបស់ព្រះអង្គទៅអនុវត្តនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់យើង ។ កាន់តែអនុវត្តតាមសេចក្តីបង្រៀនរបស់ព្រះអង្គ យើងកាន់តែយល់អំពីព្រះជាម្ចាស់ ។

**កូឡូស ១:៩ខ-១០**

**យើងចេះតែអធិស្ឋាន និង ទូលអង្វរព្រះជាម្ចាស់អោយបងប្អូន ឥតឈប់ឈរឡើយ ដើម្បីអោយបងប្អូនស្គាល់ព្រះហឫទ័យរបស់ព្រះអង្គយ៉ាងច្បាស់ ដោយមានគ្រប់ប្រាជ្ញា និង តំរិះដែលមកពីព្រះវិញ្ញាណ។ សូមអោយបងប្អូនរស់នៅបានសមរម្យនឹងព្រះអម្ចាស់ ដើម្បីអោយគាប់ព្រះហឫទ័យព្រះអង្គ ក្នុងគ្រប់វិស័យទាំងអស់។ ដូច្នេះ បងប្អូននឹងបង្កើតផលផ្លែក្នុងគ្រប់អំពើល្អដែលបងប្អូនធ្វើ ហើយបងប្អូននឹងស្គាល់ព្រះជាម្ចាស់កាន់តែច្បាស់ឡើងៗ។**

ព្រះគម្ពីរបានចែងយ៉ាងច្បាស់អំពីភាពខុសគ្នា រវាងដឹងអំពីព្រះជាម្ចាស់ និងស្គាល់ព្រះជាម្ចាស់ដោយផ្ទាល់ ។ ឥឡូវនេះ សូមក្រឡេកមើលចំនុចណាខ្លះដែលអ្នកអាចធ្វើ ដើម្បីបង្កើនទំនាក់ទំនងជាមួយនឹងព្រះយេស៊ូ អោយកាន់តែស្និទ្ធស្នាលថែមទៀត ។

## ឃ. ជំហានជាមូលដ្ឋានដើម្បីបង្កើតទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះយេស៊ូ

គោលការណ៍ជាច្រើននៃការកសាងមិត្តភាព ក៏នឹងប្រើក្នុងការបង្កើនទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះយេស៊ូផងដែរ ។ យើងក៏មិនចង់ធ្វើអោយដំណើរការនៃទំនាក់ទំនងនេះ មានភាពស្មុគស្មាញនោះឡើយ ។ សូម្បីតែកុមារក៏អាចក្លាយជាមិត្តជិតស្និទ្ធរបស់ព្រះយេស៊ូបានដែរ ។

ទោះជានៅលើផែនដីនេះ យើងមិនដែលឃើញព្រះយេស៊ូក៏ដោយ ក៏យើងអាចបង្កើតនិងបង្កើនទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះអង្គបានដែរ ។ យើងអាចទៅដល់ចំនុចមួយដែលយើងគិតថា "ព្រះយេស៊ូជាមិត្តល្អរបស់ខ្ញុំ ។ ខ្ញុំស្រឡាញ់ព្រះអង្គជាងអ្វីៗទាំងអស់នៅក្នុងពិភពលោកនេះ" ។

### ១. ភាគីទាំងសងខាងសុទ្ធតែចង់បានមិត្តភាព

ចំនុចមួយនៅក្នុងជំហានដំបូងចំពោះភាគីខាងយើងគឺ ធ្វើការសំរេចចិត្តថា "ខ្ញុំចង់ក្លាយជាមិត្តជិតស្និទ្ធរបស់ព្រះយេស៊ូ" ។ ព្រះគម្ពីរបានចែងយ៉ាងច្បាស់ថា ព្រះជាម្ចាស់ស្រឡាញ់យើង ហើយព្រះអង្គបានសំដែងចេញតាមរយៈសកម្មភាពរបស់ព្រះអង្គ ។ សូមអាន យ៉ូហាន ៣:១៦ ។ ព្រះអង្គឆ្លើយតបភ្លាមៗចំពោះគ្រប់មនុស្ស ដែលបង្ហាញសេចក្តីស្រឡាញ់ដ៏ពិតទៅកាន់ព្រះអង្គ ។

ព្រះជាម្ចាស់មិនមានកំណត់ដូចយើងនោះឡើយ ។ យើងអាចនិយាយជាមួយមនុស្សម្តង បានតែមួយនាក់ប៉ុណ្ណោះ ។ ព្រះជាម្ចាស់អាចស្តាប់មនុស្ស៥០លាននាក់និយាយទៅកាន់ព្រះអង្គក្នុងពេលតែមួយបាន ។ ព្រះអង្គយកចិត្តទុកដាក់ជាមួយនឹងគ្រប់ហេតុការណ៍ ដែលកើតឡើងជារៀងរាល់ថ្ងៃនៅក្នុងជីវិតរបស់យើង ។ គ្រប់ពេលដែលយើងអេះក្បាល មានសក់មួយ ឬពីរសរសៃជ្រុះមក ។ ព្រះជាម្ចាស់ទតឃើញ ព្រះអង្គក៏រាប់ចំនួនសក់ដែលមាននៅលើកក្បាលយើងឡើងវិញ ។ ( សូមអាន ម៉ាថាយ ១០:៣០) ព្រះអង្គស្គាល់យើងដូចព្រះអង្គស្គាល់លោក **ប៊ីលីហ្គ្រែហាម** ដែរ ។ កិច្ចការចំពោះមុខដែលយើងត្រូវធ្វើគឺ បង្កើតទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះជាម្ចាស់ ។ វាចាប់ផ្តើមជាមួយនឹងការជ្រើសរើសរបស់យើង ដោយគិតថា "ព្រះជាម្ចាស់អើយ! ខ្ញុំចង់ស្គាល់ព្រះអង្គដោយផ្ទាល់" ។

ការជ្រើសរើសជាជំហានសំខាន់ទីមួយ ប៉ុន្តែសូមមានទូវសកម្មភាពមកជាមួយផង ។ សូមដាក់វាជាអត្ថិភាពនៅក្នុងជីវិតរបស់អ្នក ។ ដំបូងវាមានការពិបាក ប៉ុន្តែសូមកុំបញ្ឈប់ ។ សូមរក្សាភ្ជាប់នូវការសំរេចចិត្តរបស់អ្នកទោះជាអ្នកមិនមានអារម្មណ៍ថាព្រះជាម្ចាស់គង់នៅជិតអ្នកក៏ដោយ ។

### ២. រៀនអំពីវិធីប្រាស្រ័យទាក់ទងជាមួយនឹងព្រះយេស៊ូ

យើងទាំងអស់គ្នាសុទ្ធតែដឹងអំពីសារៈសំខាន់នៃការប្រាស្រ័យទាក់ទង ដែលមាននៅក្នុងការបង្កើតមិត្តភាព ។ ប្រសិនបើគ្មានការប្រាស្រ័យទាក់ទងគ្នានោះទេ មិត្តភាពប្រាកដជារលាយនៅថ្ងៃណាមួយ ។ យើងរក្សានូវមិត្តភាពដោយរក្សានូវការប្រាស្រ័យទាក់ទងល្អជាមួយនឹងគ្នា ។

ការអធិស្ឋានជាវិធីល្អបំផុតក្នុងការទាក់ទងរវាងព្រះយេស៊ូ និងរូបយើងផ្ទាល់ ។ ប្រសិនបើយើងពិបាកក្នុងការអធិស្ឋានទៅកាន់ព្រះដែលយើងមើលមិនឃើញ សូមបង្កើតរូបភាពនៅក្នុងគំនិត ដោយគិតថាព្រះយេស៊ូគង់នៅជិតយើង ។ ប្រាប់ព្រះអង្គអំពីខ្លួនយើង និងអ្វីៗដែលបានកើតឡើងនៅថ្ងៃនេះ ។ សូមធ្វើអោយព្រះអង្គមានព្រះតំរិះថា យើងពិតជាចង់ឮព្រះអង្គមានបន្ទូលមកយើងអំពីកិច្ចការទាំងនេះមែន ។

យើងត្រូវតែរៀនបើកចិត្តចំហរទៅកាន់ព្រះជាម្ចាស់ ហើយប្រាប់ព្រះអង្គអំពីអារម្មណ៍របស់យើង ។ ព្រះអង្គឈ្វេងយល់គ្រប់កិច្ចការទាំងអស់ យើងមិនអាចលាក់ជាមួយនឹងព្រះអង្គបានឡើយ ។ ប៉ុន្តែព្រះអង្គគាប់ព្រះទ័យចង់ឮយើងនិយាយដោយផ្ទាល់ចេញពីមាត់ ។ សូមទូលព្រះអង្គថា យើងចង់រៀនស្រឡាញ់ព្រះអង្គថែមទៀត ។ នៅពេលយើងបំពេញកិច្ចការប្រចាំថ្ងៃ សូមអោយការគិតរបស់យើងបែរទៅរកព្រះអង្គ ។ ពិភាក្សាជាមួយនឹងព្រះអង្គអំពីស្ថានការណ៍ដែលយើងកំពុងជួបប្រទះ ។ ព្រះបាទដាវីឌនៅក្នុងសម្ពន្ធមេត្រីចាស់ បានបង្កើតមិត្តភាពយ៉ាងស៊ីជំរៅជាមួយនឹងព្រះជាម្ចាស់ ។ នៅក្នុងព្រះគម្ពីរ ព្រះជាម្ចាស់បញ្ជាក់ថាព្រះបាទដាវីឌជាមិត្តរបស់ព្រះអង្គ ។ សូមអានសៀវភៅទំនុកតម្កើង និងមើលពីរបៀបដែលព្រះបាទដាវីឌបង្ហាញពីអារម្មណ៍របស់ទ្រង់ទៅព្រះជាម្ចាស់ ។

### ៣. សូមបង្កើនការទុកចិត្ត និងភាពស្មោះត្រង់

សូមកុំព្យាយាមលាក់កំបាំងបញ្ហារបស់យើង នៅពេលនិយាយជាមួយនឹងព្រះជាម្ចាស់ ។ សូមក្លាហាន និងនិយាយដោយទៀងត្រង់ទៅកាន់ព្រះអង្គ ។ ប្រសិនបើអ្នកបានប្រព្រឹត្តអំពើបាប សូមកុំដាក់កំហុសទៅលើអ្នកដទៃ ។ សូមទទួលខុសត្រូវរាល់សកម្មភាព និងទទួលស្គាល់អំពើបាបដែលអ្នកបានប្រព្រឹត្ត ។ ទូលសុំព្រះអង្គអោយ

ជួយយើងមើលឃើញខ្លួនឯងច្បាស់ជាងមុន។ ជួនកាលយើងបោកបញ្ឆោតខ្លួនឯង ហើយយើងត្រូវការមនុស្សផ្សេងទៀត មកជួយធ្វើអោយយើងដឹងខ្លួននិងទទួលស្គាល់ការពិត។ ចំនុចនេះ ព្រះគម្ពីរជាជំនួយដ៏ល្អសំរាប់យើង។ ព្រះជាម្ចាស់មានព្រះបន្ទូលយ៉ាងច្បាស់អំពី អំពើបាប ហើយនិងឥរិយាបថដែលធ្វើអោយព្រះអង្គគាប់ព្រះទ័យ។

ប្រសិនបើយើងចង់បង្កើនទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះយេស៊ូ យើងត្រូវតែជ្រើសរើសជឿលើព្រះអង្គ។ ជំនឿលើព្រះជាម្ចាស់ជាអំណោយដ៏ល្អសំរាប់យើង។ បើយើងទៅប្រាប់នរណាម្នាក់ថា "ខ្ញុំបានសំរេចចិត្តថា ជឿអ្នក ហើយខ្ញុំគ្មានអ្វីត្រូវលាក់បាំងជាមួយអ្នកឡើយ" យើងប្រាកដជាឈឺចាប់និងអស់ទីពឹងនៅថ្ងៃណាមួយជាមិនខាន។

នៅពេលយើងសំឡឹងមើលទៅព្រះយេស៊ូ តើយើងអាចទុកចិត្តព្រះអង្គបានដែរឬទេ? តើមានភស្តុតាងអ្វីខ្លះដែលបញ្ជាក់ថា ការជឿទុកចិត្តលើព្រះយេស៊ូ ជាការសំរេចចិត្តដ៏ឆ្លាតវៃនោះ? ចរិករបស់ព្រះអង្គគឺខុសប្លែកទាំងស្រុងពីចរិកបាប។ ព្រះអង្គមានពេញដោយសេចក្តីស្រឡាញ់ និងភាពស្មោះត្រង់។ ព្រះអង្គមានភាពសុចរិតឥតខ្ចោះ ហើយហេតុអ្វីបានជាយើងត្រូវខ្វាស់អៀនក្នុងការជឿទុកចិត្តព្រះយេស៊ូ? យើងខ្លាច? ព្រះអង្គនឹងធ្វើអោយយើងបាក់ទឹកចិត្ត? សូមរកមើលនៅក្នុងព្រះគម្ពីរ តើព្រះយេស៊ូធ្លាប់បោកប្រាស់នរណាដែរឬទេ? គ្រប់មនុស្សដែលស្មោះត្រង់ជាមួយនឹងព្រះជាម្ចាស់នឹងឃើញថា ព្រះអង្គពិតជាអាចទុកចិត្តបានមែន។

សូមទូលដល់ព្រះជាម្ចាស់ថា យើងពិតជាចង់ជឿទុកចិត្តព្រះអង្គខ្លាំងជាងមុន។ សូមទូលសុំព្រះអង្គ អោយជួយយើងស្គាល់ខ្លួនឯងច្បាស់ជាងមុន ហើយឈ្នះលើការភ័យខ្លាចទាំងឡាយ ដែលធ្វើអោយយើងមិនអាចជឿទុកចិត្តព្រះអង្គបាន។

## ៤. រៀនគោរព និងស្រឡាញ់ព្រះអង្គ

ព្រះគម្ពីរមិនបានថែងច្បាស់អំពីក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើង ប៉ុន្តែការសុគតរបស់ព្រះយេស៊ូនៅលើឈើឆ្កាង បានបង្ហាញយ៉ាងច្បាស់អំពីក្តីស្រឡាញ់របស់ព្រះអង្គចំពោះយើង។ ព្រះយេស៊ូចំណាយពេលជារៀងរាល់ថ្ងៃ ដើម្បីជួយមនុស្សដែលខ្វះខាត។ ព្រះអង្គធ្វើកិច្ចការនេះដោយសារតែសេចក្តីស្រឡាញ់ មិនមែនដោយសារលុយ ឬក៏អំណួតផ្ទាល់ខ្លួននោះឡើយ។

គ្រប់មិត្តភាពអាចនៅស្ថិតស្ថេរគង់វង្សបាន គឺដោយសារមិត្តភាពនោះបានសង់នៅលើគ្រឹះនៃក្តីស្រឡាញ់។ ក្រិត្យវិន័យដែលសំខាន់ជាងគេនៅក្នុងព្រះគម្ពីរគឺ ចូរស្រឡាញ់ព្រះជាម្ចាស់អោយអស់ពីចិត្ត អស់ពីព្រលឹង អស់ពីគំនិត និងអស់ពីកំលាំងរបស់អ្នក។ សូមអាន ម៉ាថាយ ១២:៣០។ ព្រះយេស៊ូមិនបានរំពឹងថា យើងធ្វើជាមិត្តរបស់ព្រះអង្គដោយសារតែនេះជាក្រិត្យវិន័យសំរាប់យើងនោះឡើយ។ ព្រះអង្គអនុញ្ញាតអោយយើងមានសិទ្ធិក្នុងការជ្រើសរើសស្រឡាញ់ព្រះអង្គ។

ឆ្លងកាត់តាមបទពិសោធន៍នៃមិត្តភាពពីអតីតកាល បានធ្វើអោយយើងដឹងថា ក្តីស្រឡាញ់ត្រូវតែបញ្ចេញជារៀងរាល់ថ្ងៃ ប្រកបដោយមនោសញ្ចេតនាយ៉ាងជ្រាវជ្រៅ។ វានឹងមិនគ្រប់គ្រាន់នោះឡើយ បើមួយឆ្នាំម្តងយើងនិយាយទៅកាន់ប្តីឬប្រពន្ធរបស់យើងថា "អូនសម្លាញ់! បងបានស្រឡាញ់អូនតាំងពីមុនមក ហើយនៅឆ្នាំក្រោយ បងក៏នៅតែស្រឡាញ់អូនដែរ ដូច្នេះសប្តាហ៍ក្រោយសូមកុំសួរថា បងនៅស្រឡាញ់អូនទេ អោយសោះ"។

ព្រះជាម្ចាស់មិនបានរំពឹងថា យើងនឹងទិញក្ដីស្រឡាញ់របស់ព្រះអង្គឡើយ ។ ព្រះអង្គនឹងមានព្រះហឫទ័យរំភើប នៅពេលឃើញយើងបង្ហាញក្ដីស្រឡាញ់តាមរយៈគំនិត ពាក្យសំដី និងសកម្មភាពរបស់យើង ។ ប្រសិនបើយើង ស្រឡាញ់ព្រះអង្គ យើងនឹងប្រណិបត្តិតាមព្រះអង្គ ។ យើងមិនចាំបាច់ដេកនៅលើដែកគោល ឬក៏ដើរនៅលើភ្លើង ដើម្បីបញ្ជាក់ពីសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះអង្គនោះឡើយ ។ យើងបង្ហាញក្ដីស្រឡាញ់ទៅព្រះអង្គតាម រយៈកិច្ចការដែលយើងជួបប្រទះប្រចាំថ្ងៃ ។

ធាតុផ្សំសំខាន់មួយទៀតនៃមិត្តភាពដ៏ជ្រាវជ្រៅនោះគឺ ការគោរព ។ សូមប្រព្រឹត្តជាមួយអ្នកដទៃប្រកប ដោយការគោរព និងការសរសើរ ។ សុំកុំលេងសើចជាមួយនឹងព្រះជាម្ចាស់ ។ ព្រះជាម្ចាស់មិនដែលជំពាក់អ្វីពីយើង ឡើយ ដោយរាប់ទាំងគ្រប់កិច្ចការដែលយើងបានធ្វើថ្វាយព្រះអង្គ ។ សូមធ្វើអោយមិត្តភាពរវាងយើង និងព្រះជា ម្ចាស់កាន់តែល្អកល្អើន ។ ផ្ដល់កិត្តិយសដល់ព្រះអង្គ ។ គោរពព្រះអង្គ ដោយមិនយកព្រះនាមរបស់ព្រះអង្គទៅជេរ នៅពេលយើងមានកំហឹង ។

នៅពេលយើងបង្កើនមិត្តភាពជាមួយនឹងព្រះយេស៊ូអោយស្និទ្ធស្នាលជាងមុន យើងនឹងមានអារម្មណ៍កាន់តែ ខិតជិតព្រះអង្គ ។ ប្រហែលជាយើងមិនអាចមានអារម្មណ៍ស្រឡាញ់ព្រះអង្គ២៤ម៉ោងក្នុង១ថ្ងៃនោះឡើយ ហើយ បែបនេះក៏មិនមែនជាសញ្ញានៃក្ដីស្រឡាញ់ដ៏ពិតដែរ ។ ការបង្កើនមិត្តភាពជាមួយនឹងព្រះយេស៊ូ មិនគ្រាន់តែជាការ ជ្រើសរើសមួយប៉ុណ្ណោះទេ តែវាជាការជ្រើសរើសដែលមានរយៈពេលយូរនិងត្រូវធ្វើឡើងជារៀងរាល់ថ្ងៃ ។ ជា រៀងរាល់ថ្ងៃ យើងមានឱកាសជាច្រើនដើម្បីប្រណិបត្តិព្រះអង្គ ។ ការគោរពប្រណិបត្តិនេះហើយ ដែលជាភាសានៃ ក្ដីស្រឡាញ់ទៅកាន់ព្រះយេស៊ូ ។ ព្រះអង្គមិនដែលធុញទ្រាន់នឹងសកម្មភាព ឬក៏គំនិតដែលពោរពេញដោយក្ដី ស្រឡាញ់ទាំងនេះឡើយ ។

## ង. តើអ្វីទៅជាលទ្ធផលនៃការស្គាល់ព្រះជាម្ចាស់ដោយផ្ទាល់នោះ?

ស្គាល់ព្រះជាម្ចាស់ដោយផ្ទាល់ខ្លួន នឹងធ្វើអោយបញ្ហារបស់យើងរលាយ ។ មិត្តភាពដ៏ពិសេសនេះ នឹងនាំមក នូវភាពសំបូរសប្បាយដល់ជីវិតរបស់យើង ។ ទោះធ្វើយ៉ាងណា ក៏យើងមិនអាចរកនៅលើផែនដីនេះបានដែរ ។ ខាង ក្រោមនេះជាអត្ថប្រយោជន៍ដែលទទួលបានមកពីការស្គាល់ព្រះជាម្ចាស់ ។

### ១. ភាពសុខសាន្ត

ព្រះយេស៊ូបានមានព្រះបន្ទូលសន្យាថា នឹងផ្ដល់ភាពសុខសាន្តរបស់ព្រះអង្គដល់គ្រប់មនុស្សដែលបាន ស្រឡាញ់ និងជឿទុកចិត្តព្រះអង្គ ។ សូមអាន យ៉ូហាន ១៤:២៧ ។ សូមសាកសួរអស់អ្នកដែលមានមិត្តភាពជិតស្និទ្ធ ជាមួយនឹងព្រះជាម្ចាស់ ។ ពួកគេប្រាកដជាប្រាប់យើងអំពីភាពសុខសាន្តនិងសន្តិភាពដែលព្រះបានដាក់មកក្នុងចិត្ត របស់ពួកគេ ។ ប្រសិនបើអ្នកគ្មានភាពសុខសាន្តនៅក្នុងចិត្ត សូមទូលប្រាប់ព្រះជាម្ចាស់ ។ សូមរកអោយឃើញ នូវ

ចំនុចណាដែលមិនគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ការមិនស្តាប់បង្គាប់ទាំងនោះហើយដែលធ្វើអោយយើង មិនអាចទទួលភាពសុខសាន្តរបស់ព្រះអង្គបាន ។

**២. ភាពរីករាយក្នុងចិត្ត**

មានវិធីតែមួយគត់ដែលអាចរកឃើញភាពរីករាយក្នុងចិត្តដ៏ពិតប្រាកដ គឺតាមរយៈការមានទំនាក់ទំនងផ្ទាល់ ជាមួយនឹងព្រះយេស៊ូ ។ ទាល់តែព្រះយេស៊ូប្រទានអោយ ទើបយើងអាចស្គាល់អត្ថន័យពិតនៃភាពរីករាយនៅក្នុង ចិត្ត ។ នៅពេលដែលព្រះអង្គប្រទានអោយយើងហើយ គ្មានអ្វីអាចដកវាចេញពីយើងបានឡើយ ។ នៅក្នុងព្រះគម្ពីរ រ៉ូម ៨:៣៨-៣៩ លោកប៉ូលបានមានប្រសាសន៍ថា មានបញ្ហាជាច្រើន ដែលព្យាយាមបំបែកយើងចេញក្តីស្រឡាញ់ និងភាពរីករាយ ដែលព្រះគ្រិស្តដាក់នៅក្នុងជីវិតរបស់យើង ។ លោកប៉ូលមានប្រសាសន៍យ៉ាងច្បាស់ថា គ្មានអ្វីអាច បំបែកយើងចេញពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បានឡើយ ។ នេះហើយជាសេចក្តីសុខដ៏ពិតប្រាកដ ។

**៣. យើងនឹងមានអារម្មណ៍អំពីព្រះវត្តមានរបស់ព្រះជាម្ចាស់**

នៅពេលដែលមិត្តភាពរបស់យើងជាមួយនឹងព្រះជាម្ចាស់បានរីកចំរើនឡើង យើងនឹងយល់កាន់តែច្បាស់អំពី ព្រះវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង ។ (យល់ មិនមែនមានអារម្មណ៍) ព្រះអង្គគង់នៅជាមួយ គ្រប់គ្រិស្តបរិស័ទទាំងអស់ ប៉ុន្តែមិនមែនគ្រប់គ្នាសុទ្ធតែមានអារម្មណ៍អំពីព្រះវត្តមានរបស់ព្រះអង្គនោះឡើយ ។ កាន់តែស្គាល់ព្រះអង្គ យើងកាន់តែស្គាល់ព្រះវត្តមានរបស់ព្រះអង្គ ។ យើងអាចចំណាយពេលរហូតអស់មួយជីវិត ប៉ុន្តែសូមចំណាយពេលរៀនស្តាប់ព្រះសូរសៀងរបស់ព្រះវិញ្ញាណ នៅពេលព្រះអង្គមានបន្ទូលមកកាន់ចិត្តរបស់ យើងម្នាក់ៗវិញ ។

**៤. យើងនឹងនឹកគិតដល់ព្រះជាម្ចាស់ថែមទៀត**

ប្រសិនបើយើងលង់ស្នេហ៍ជាមួយនរណាម្នាក់យ៉ាងខ្លាំង នោះយើងនឹងគិតដល់រូបគេពេញមួយថ្ងៃ ។ ទំនាក់ ទំនងជាមួយនឹងព្រះជាម្ចាស់ក៏យ៉ាងដូច្នោះដែរ ។ នៅក្នុងគ្រប់កិច្ចការប្រចាំថ្ងៃ សូមនឹកគិតដល់ព្រះជាម្ចាស់ ។ សូម ទូលព្រះអង្គអំពីអារម្មណ៍របស់បងប្អូន ។ សូមទូលព្រះអង្គអំពីសេចក្តីសំរេចចិត្ត ដែលបងប្អូនកំពុងធ្វើការសំរេច ។ សូមចងចាំនូវសេចក្តីបង្រៀនរបស់ព្រះអង្គ ហើយពិភាក្សាសេចក្តីបង្រៀនទាំងនេះជាមួយនឹងព្រះអង្គ ។

**៥. យើងនឹងចង់ប្រាប់មនុស្សផ្សេងទៀតអំពីព្រះយេស៊ូ**

នៅពេលយើងលង់ស្នេហ៍ជាមួយនឹងនរណាម្នាក់ យើងចង់និយាយអំពីគាត់ខ្លាំងណាស់ ។ ប្រសិនបើយើងពិត ជាស្រឡាញ់ព្រះយេស៊ូមែន យើងប្រាកដជាចង់អោយអ្នកដទៃផ្សេងទៀត មានបទពិសោធន៍ដូចគ្នាជាមួយនឹង អំណរដែលយើងមាន ។ ព្រះយេស៊ូមានបន្ទូលទៅកាន់លោកពេត្រុស មុនពេលព្រះអង្គយាងត្រឡប់ទៅស្ថានបរម សុខវិញថា "តើអ្នកស្រឡាញ់ខ្ញុំឬទេ?" ពេត្រុសទូលថា "ទូលបង្គំស្រឡាញ់ព្រះអង្គ" ។ ព្រះយេស៊ូមានព្រះបន្ទូលទៅ គាត់ថា "សូមថែរក្សាហ្វូងចៀមរបស់ខ្ញុំផង" ។ (ព្រះយេស៊ូមានបន្ទូលអំពីអ្នកដើរតាមព្រះអង្គ) ។ ទំនាក់ទំនងជា មួយនឹងព្រះជាម្ចាស់ មិនមែនជារឿងដែលយើងទុកសំងាត់តែម្នាក់ឯងនោះឡើយ ។ យើងចាំបាច់ត្រូវតែអោយ មនុស្សផ្សេងទៀតដឹងថា យើងស្រឡាញ់ព្រះយេស៊ូ ។

រៀនស្គាល់ និងស្រឡាញ់ព្រះជាម្ចាស់អោយកាន់តែខ្លាំង ជាកិច្ចការដែលយើងត្រូវធ្វើក្នុងមួយជីវិតនេះ។ ព្រះជាម្ចាស់គាប់ព្រះហឫទ័យចង់បង្កើនមិត្តភាពជាមួយយើង អោយកាន់តែស្និទ្ធជាងមុន។ សូមដាក់ចំនុចនេះជាអាទិភាពទីមួយនៅក្នុងជីវិតរបស់បងប្អូន នោះបងប្អូននឹងទទួលបានជោគជ័យយ៉ាងត្រចះត្រចង់នៅក្នុងជីវិតនេះ។

# ជំពូកទី៤

## តើខ្ញុំអាចធ្វើអ្វីបាន នៅពេលខ្ញុំមានមន្ទិលសង្ស័យចំពោះជំនឿរបស់ខ្លួន?

ជីវិតរបស់គ្រិស្តបរិស័ទថ្មីខុសទាំងស្រុងជាមួយនឹងរឿងនិទានសំរាប់កុមារ ។ នៅក្នុងរឿងនិទាន មនុស្សនឹងរស់ដោយសុភមង្គល បន្ទាប់ពីវិបត្តិដ៏ធំនៅក្នុងរឿងនោះត្រូវបានដោះស្រាយ ។ តាមពិត គ្រិស្តបរិស័ទថ្មីនឹងជួបនូវបញ្ហាជាច្រើន ជួនកាលវាធំជាងបញ្ហាទាំងឡាយដែលធ្លាប់កើតមានតាំងពីឆ្នាំមុនទៅទៀត ។ មានគ្រិស្តបរិស័ទថ្មីជាច្រើន មានមន្ទិលសង្ស័យចំពោះការសំរេចចិត្ត និងជំនឿរបស់ខ្លួនឯង ។

មន្ទិលសង្ស័យមានទំរង់ខុស១ពីគ្នា ហើយវាធ្វើអោយប៉ះពាល់ដល់មនុស្សផ្សេង១ពីគ្នាដែរ ។ សំរាប់គ្រិស្តបរិស័ទមួយចំនួន មន្ទិលសង្ស័យបានចូលមក ហើយក៏ចាកចេញក្នុងពេលដ៏ខ្លី ។ ចំណែកគ្រិស្តបរិស័ទខ្លះទៀត មានវិបត្តិជាមួយនឹងជំនឿរបស់ខ្លួន ដែលមានចំពោះព្រះជាម្ចាស់ ហើយមានការឆ្ងល់ជាច្រើនចំពោះបទពិសោធន៍ដែលខ្លួនធ្លាប់ឆ្លងកាត់ និងព្រមទាំងឆ្ងល់អំពីព្រះជាម្ចាស់ទៀតផង ។ គេគិតថា "ប្រសិនបើមានព្រះជាម្ចាស់មែន ហើយបើព្រះអង្គពិតជាស្រឡាញ់ខ្ញុំមែន ហេតុអ្វីបានជាខ្ញុំមានបញ្ហា និងភាពសង្ស័យទាំងនេះ? ប្រហែលនេះគ្រាន់តែជាលក្ខណៈសាសនា ហើយមិនមែនសំរាប់រូបខ្ញុំនោះឡើយ ។ មើលយូរទៅហាក់បីដូចជាជំនួញមួយដ៏ធំ ដែលគ្មានប្រាក់ចំណេញអ្វីទាល់តែសោះ" ។

តើបងប្អូនធ្លាប់ឆ្ងល់ដែលឬទេ? មានព្រះជាម្ចាស់ ឬអត់? តើមានប៉ុន្មានដង ដែលបងប្អូនមានចំងល់ និងមានអារម្មណ៍ថា "ខ្ញុំប្រហែលជាមិនមែនគ្រិស្តបរិស័ទទេមើលទៅ?" សូមកុំភ្ញាក់ផ្អើល ប្រសិនបើបងប្អូនកំពុងតែជួបប្រទះ ហើយកំពុងស្វែងរកការពិត ។ បញ្ហារបស់បងប្អូនដូចទៅនឹងបញ្ហា ដែលកើតមានឡើងជារឿយ១ជាមួយនឹងគ្រិស្តបរិស័ទថ្មី (និងចាស់)ជាច្រើននាក់ផ្សេងទៀត ។ ឥទ្ធិពលនៃមន្ទិលសង្ស័យ និងចំងល់ទាំងនេះបានចូលមកក្នុងជីវិតរបស់បងប្អូន គឺវាមានជាប់ទាក់ទងជាមួយនឹង ទំនាក់ទំនងផ្ទាល់របស់បងប្អូនជាមួយនឹងព្រះយេស៊ូ ។

បងប្អូនប្រហែលជាមិនអាចបញ្ឈប់មន្ទិលសង្ស័យទាំងឡាយ ដែលចូលមកក្នុងគំនិតរបស់បងប្អូន ប៉ុន្តែយើងអាចប្រឹងអោយអស់ពីលទ្ធភាព ដើម្បីរកអោយឃើញពីមូលហេតុ ដែលធ្វើអោយមន្ទិលសង្ស័យទាំងនោះចូលមកជីវិតរបស់យើង ។ ព្រះជាម្ចាស់មិនទុកអោយយើងនៅជាមួយនឹងមន្ទិលសង្ស័យទាំងនោះ ហើយអោយយើងដោះស្រាយតែម្នាក់ឯងនោះឡើយ ។ ព្រះអង្គត្រៀមជាស្រេចដើម្បីជួយយើង ប្រសិនបើយើងចង់អោយព្រះអង្គជួយ ។ ក្នុងពេលដែលព្រះបាទដាវីឌនៅក្នុងសម្ពន្ធមេត្រីចាស់មានបញ្ហាជាមួយនឹងមន្ទិលសង្ស័យ ព្រះអង្គបានទតទៅរកព្រះជាម្ចាស់ដើម្បីសុំជំនួយពីព្រះអង្គ ។

**ទំនុកតម្កើង ៩៤:១៩**

**ពេលណាមានទុក្ខកង្វល់ញាំញីក្នុងដួងចិត្តទូលបង្គំ ព្រះអង្គសំរាលទុក្ខទូលបង្គំ ដោយប្រទានអោយទូលបង្គំមានអំណរសប្បាយ។**

ព្រះបាទដាវីឌុទតឃើញក្តីសង្ឃឹមនៅខាងមុខ ។ បងប្អូនក៏ដូច្នោះដែរ បងប្អូនអាចមានទំនុកចិត្តថា ដោយមានជំនួយពីព្រះជាម្ចាស់ យើងនឹងអាចយកឈ្នះលើមន្ទិលសង្ស័យរបស់បងប្អូនបាន ។ សង្គ្រាមដែលកើតមានឡើងនៅក្នុងគំនិតរបស់យើង អាចជួយយើងអោយរីកចំរើនខាងផ្នែកព្រលឹងវិញ្ញាណ ។ នៅពេលយើងកំពុងតែមានមន្ទិលសង្ស័យ យើងចុះខ្សោយ ហើយចង់បោះបង់ជំនឿរបស់ខ្លួនចោល ។ ប៉ុន្តែសូមឈរយ៉ាងរឹងមាំនៅលើព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ។

ព្រះជាម្ចាស់មិនដែលបោះបង់យើងចោលម្តងណាឡើយ ។ ប៉ុន្តែនៅក្នុងព្រះគម្ពីរមិនបានថែងទេថា ព្រះអង្គនឹងជួយយើងកុំអោយមានមន្ទិលសង្ស័យ ។ យើងត្រូវតែទទួលស្គាល់ការពិត ហើយប្រឈមជាមួយនឹងមន្ទិលសង្ស័យទាំងនោះ ។ ការប្រងើយកន្តើយ មិនអាចដកមន្ទិលសង្ស័យទាំងនោះចេញបានឡើយ ។

## ក. តើនរណាជាអ្នកនាំយកមន្ទិលសង្ស័យទាំងនេះចូលមកក្នុងគំនិតរបស់យើង?

មន្ទិលសង្ស័យមានលក្ខណៈខុសប្លែកពីគ្នា ។ មន្ទិលសង្ស័យខ្លះមានជាប់ទាក់ទងទៅនឹងសេចក្តីបង្រៀនដែលបងប្អូនបានទទួល និងជំនឿរបស់បងប្អូន ។ ប្រសិនបើឪពុកម្តាយរបស់បងប្អូនមិនមានជំនឿលើព្រះជាម្ចាស់ បងប្អូនអាចនឹងមានមន្ទិលសង្ស័យចំពោះខ្លួនឯងថា: "តើខ្ញុំអាចដឹងប្រាកដថាមានព្រះជាម្ចាស់ដោយរបៀបណា?" ។ ប្រសិនបើភាពសុខសាន្ត និងអំណរមិនបានចូលមក ហើយមានតែភាពស្មុគស្មាញ បងប្អូនអាចនឹងឆ្ងល់ថា តើខ្លួនឯងជាគ្រិស្តបរិស័ទមែនដែរឬទេ? ពីព្រោះមានគេប្រាប់យើងថា នៅថ្ងៃដែលយើងក្លាយជាគ្រិស្តបរិស័ទ យើងនឹងមានភាពសុខសាន្ត និងក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ។

មន្ទិលសង្ស័យមានប្រភពផ្សេងៗពីគ្នា ។ មុនពេលដែលយើងចូលទៅសិក្សាអំពីមូលហេតុនៃភាពសង្ស័យ និងដំណោះស្រាយសំរាប់ មន្ទិលសង្ស័យទាំងនោះ យើងត្រូវពិចារណាសិនថា តើនរណាជាអ្នកនាំបញ្ហាចូលមកក្នុងគំនិតរបស់យើង?

### ១. មារសាតាំង

ប្រសិនបើមារសាតាំងមិនអាចបញ្ឈប់ជីវិតគ្រិស្តបរិស័ទរបស់យើងបាន វានឹងដាក់មន្ទិលសង្ស័យ និងចំងល់ជាច្រើនអោយយើងឆ្ងល់ខ្លួនឯងថា ហេតុអ្វីបានជាយើងសំរេចចិត្តធ្វើជាគ្រិស្តបរិស័ទ? បែបនេះកើតឡើងចំពោះគ្រិស្តបរិស័ទចាស់ និងគ្រិស្តបរិស័ទថ្មី ។

មន្ទិលសង្ស័យប្រភេទនេះ យើងហៅថាការល្បួង ។ ព្រះគម្ពីរបានថែងថា មារសាតាំងជាបិតានៃមេកុហក ។ វាជាមេបោកបញ្ឆោតមនុស្ស ។ ព្រះជាម្ចាស់បានមានបន្ទូលសន្យាថា ព្រះអង្គនឹងជួយយើងនៅពេលណាយើងជួបជាមួយនឹងការល្បួង ។ បងប្អូនគ្រាន់តែចាំថា តើនរណាជាអ្នកដឹកនាំជីវិតរបស់យើង ហើយកុំស្តាប់សេចក្តីកុហកដែលមារសាតាំងដាក់មកក្នុងគំនិតរបស់យើង ។

## ២. អ្នកដទៃ

អ្នកដទៃផ្សេងទៀតអាចនិយាយ ឬធ្វើអ្វីមួយដែលនាំអោយយើងមានការសង្ស័យជាមួយព្រះគ្រិស្ត ឬក៏ការប្តេជ្ញាចិត្តរបស់យើងចំពោះព្រះអង្គ។ មនុស្សដែលមិនមែនជាគ្រិស្តបរិស័ទ មិនយល់អំពីការប្តេជ្ញាចិត្តរបស់យើងចំពោះព្រះយេស៊ូគ្រិស្តឡើយ។ ពួកគេអាចនឹងសើចចំពោះការសំរេចចិត្តរបស់យើងធ្វើជាគ្រិស្តបរិស័ទ។ សូមកុំភ្ញាក់ផ្អើល នៅពេលពួកគេសួរអំពីជំនឿរបស់យើង ឬជជែកវែកញែកអំពីរឿងសាសនា។

គួរអោយស្តាយ ប៉ុន្តែវាជាការពិតដែលមនុស្សធ្លាប់មានជំនឿលើព្រះគ្រិស្ត បែរជានាំមន្ទិលសង្ស័យចូលមកក្នុងគំនិតរបស់យើងទៅវិញ។ ពួកគេនិយាយថា "ខ្ញុំបានសាកល្បងជាមួយនឹងព្រះយេស៊ូដែរ ប៉ុន្តែដូចជាគ្មានអ្វីកើតឡើងចំពោះខ្ញុំទាល់តែសោះ។ សូមកុំជឿពួកគ្រិស្តបរិស័ទ សំដីពួកគេសុទ្ធតែកុហក"។ ក្រោយមក នៅពេលមានបញ្ហាមកដល់ សំដីរបស់ពួកគេបានដាស់យើងថា "ប្រហែលជាគ្មានអ្វីកើតឡើងចំពោះខ្ញុំដែរហើយមើលទៅ!"។ សូមពិនិត្យចំនុចនេះអោយច្បាស់ទាំងអស់គ្នា។ ព្រះយេស៊ូចង់អោយមនុស្សគ្រប់គ្នាទទួលបទពិសោធន៍រីករាយជាមួយនឹងការសង្គ្រោះរបស់ព្រះអង្គ។ ប្រសិនបើអ្នកទាំងនោះនៅតែមិនអាចទទួលភាពរីករាយនោះបានទៀត សូមកុំបន្ទោសព្រះជាម្ចាស់។ ព្រះអង្គនឹងជួយបងប្អូនប្រឈមមុខជាមួយគ្រប់បញ្ហា។

គ្រិស្តបរិស័ទដ៏ពិតក៏អាចនាំមន្ទិលសង្ស័យចូលមកក្នុងខ្លួនយើងបានដែរ។ ប្រសិនបើគេបង្រៀនខុសៗពីគ្នាអំពីរបៀបរស់ជីវិតជាគ្រិស្តបរិស័ទ យើងប្រហែលជាឆ្ងល់ថា តើមួយណាត្រូវ? បើពីមុនមកមានគេបង្រៀនថា ធ្វើបែបនេះមិនអីទេ តែក្រោយមកមានម្នាក់ទៀតបង្រៀនថា ធ្វើបែបនេះជាអំពើបាប នោះយើងប្រាកដជាឆ្ងល់។ បែបនេះបានកើតឡើងចំពោះគ្រិស្តបរិស័ទថ្មីនៅក្នុងសម្ពន្ធមេត្រីថ្មី។ អ្នកដឹកនាំក្រុមជំនុំនៅក្នុងទីក្រុងយេរូសាឡឹមបានសរសេរសំបុត្រទៅពួកគេ ដែលមានខ្លឹមសារថា "យើងខ្ញុំបានទទួលដំណឹងថា មានពួកយើងខ្លះបាននាំអោយបងប្អូនជ្រួលច្របល់ មកពីពាក្យដែលគេនិយាយប្រាប់បងប្អូន បណ្តាលអោយបងប្អូនមានកង្វល់ក្នុងចិត្ត" កិច្ចការ ១៥:២៤។ ទោះវាជាការបង្រៀនខុស ឬអំពើបាបរបស់ពួកគេក៏ដោយ សូមប្រយ័ត្ន! កុំអនុញ្ញាតអោយកំហុសរបស់ពួកគេមកបំផ្លាញការអស្ចារ្យនៃការសង្គ្រោះ ដែលបានកើតឡើងនៅក្នុងជីវិតរបស់យើងអោយសោះ។

ចំនុចមួយទៀតដែលគ្រិស្តបរិស័ទអាចនាំមន្ទិលសង្ស័យចូលមកក្នុងគំនិតរបស់យើងដែរនោះ គឺមកពីយើងគិតថាពួកគេល្អឥតខ្ចោះ។ សូមប្រយ័ត្នចំពោះការប្រៀបធៀបខ្លួនឯង ជាមួយនឹងគ្រិស្តបរិស័ទផ្សេងទៀត។ គ្រប់គ្រិស្តបរិស័ទនៅមានការរីកចំរើនទៅមុខជាច្រើនទៀត។ យើងអាចឃើញគ្រិស្តបរិស័ទខ្លះមិនដែលមានបញ្ហាធ្ងន់ធ្ងរទេ។ ពួកគេតែងតែសប្បាយ ហើយតែងតែញញឹមជានិច្ច។ បន្ទាប់មកយើងក្រឡេកមកមើលខ្លួនឯងដែលមានបញ្ហា យើងចាប់ផ្តើមគិតថា "ខ្ញុំធ្វើអ្វីខុសទេដឹង! បញ្ហារបស់ខ្ញុំកើតឡើងមិនចេះចប់មិនចេះហើយ"។ សូមអត់ធ្មត់ឡើង! ព្រះជាម្ចាស់កំពុងតែធ្វើការនៅក្នុងយើង។

៣. ខ្លួនយើងផ្ទាល់

ជាញឹកញាប់គេតែងតែសង្ស័យថា តើខ្ញុំជាគ្រិស្តបរិស័ទ ឬមិនមែន? ពួកគេតែងតែស្តីបន្ទោសខ្លួនឯង។ ព្រះគម្ពីរបានប្រាប់យើងយ៉ាងច្បាស់អំពី របៀបដែលយើងក្លាយជាគ្រិស្តបរិស័ទ។ មនុស្សខ្លះហាក់ដូចជាមិនសូវមានជំនឿទៅលើព្រះគម្ពីរ ហើយពួកគេចេះតែមានមន្ទិលសង្ស័យ។

៤. ព្រះជាម្ចាស់

ព្រះជាម្ចាស់អាចនឹងដាក់មន្ទិលសង្ស័យមកក្នុងគំនិតយើងថា តើយើងជាគ្រិស្តបរិស័ទពិតប្រាកដ ឬមិនមែន? បើយើងគិតថា យើងបានប្រណិបត្តិតាមព្រះអង្គ ប៉ុន្តែព្រះអង្គទ្រង់ឈ្វេងយល់ឃើញថា យើងនៅមានកង្វះខាតខ្លះនៅឡើយ នោះព្រះអង្គនឹងដាក់មន្ទិលសង្ស័យមកក្នុងគំនិតរបស់យើង ប្រសើរជាងអោយយើងរស់ជាគ្រិស្តបរិស័ទ ហើយមិនបានដឹងថាខ្លួនខុស។

ភាពសង្ស័យក៏ចូលមកដែរ ប្រសិនបើយើងប្រព្រឹត្តអំពើបាប ហើយមិនបានសារភាពប្រាប់ទៅព្រះជាម្ចាស់។ បែបនេះយើងហៅថា ការដាស់តឿនរបស់ព្រះវិញ្ញាណ ឬក៏អារម្មណ៍សោកស្តាយ។ ព្រះជាម្ចាស់នឹងបន្តដាក់មន្ទិលសង្ស័យនេះទៅក្នុងគំនិតរបស់យើង ទាល់តែយើងសារភាពអំពើបាបរបស់យើងទៅព្រះអង្គ។

ប្រសិនបើព្រះជាម្ចាស់ដាក់មន្ទិលសង្ស័យទៅក្នុងនរណាម្នាក់ ជាធម្មតាដោយសារម្នាក់នោះរស់នៅដោយបោកបញ្ឆោតខ្លួនឯង។ ព្រះជាម្ចាស់នឹងធ្វើបែបនេះ ទាល់តែអាចបំបែកការបោកបញ្ឆោតនោះបាន។ ព្រះអង្គប្រៀនប្រដៅយើង ដោយសារព្រះអង្គស្រឡាញ់យើង។ ប៉ុន្តែព្រះអង្គមិនដែលបង្ខំមនុស្សអោយធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គម្តងណាឡើយ។ ប្រសិនបើបងប្អូនស្មោះត្រង់ចង់បំរើព្រះជាម្ចាស់អោយអស់ពីចិត្ត ព្រះជាម្ចាស់នឹងមិនដាក់មន្ទិលសង្ស័យទាំងនោះមកក្នុងគំនិតយើងឡើយ។

មានរឿងមួយនៅក្នុងព្រះគម្ពីរបានបង្ហាញអំពីស្ថានភាពមួយ ដែលព្រះជាម្ចាស់ដាក់មន្ទិលសង្ស័យមកក្នុងគំនិតរបស់អ្នកជឿម្នាក់។ លូកា ១៨:១៨-៣០ បានថែងអំពីបុរសអ្នកមានម្នាក់។ គាត់ចង់ដឹងពីរបៀបទទួលជីវិតអស់កល្ប។ ព្រះយេស៊ូមានបន្ទូលសួរគាត់អំពី ការគោរពតាមក្រិត្យវិន័យដែលមាននៅក្នុងព្រះគម្ពីរ។ បុរសនោះបានស្មោះត្រង់គោរពតាមក្រិត្យវិន័យរបស់ព្រះជាម្ចាស់តាំងពីដើមមក។ ព្រះយេស៊ូមានបន្ទូលប្រាប់អោយគាត់លក់ព្រទ្យសម្បត្តិរបស់គាត់ ហើយយកលុយទៅចែកដល់អ្នកក្រ ទើបគាត់អាចដើរតាមព្រះយេស៊ូបាន។ ឮបែបនេះបុរសអ្នកមាននោះក៏បដិសេធព្រះយេស៊ូ។

ប្រសិនបើមារសាតាំងដឹងថា បុរសនោះគិតថាព្រទ្យសម្បត្តិសំខាន់ចំពោះគាត់ជាងការគោរពប្រណិបត្តិព្រះជាម្ចាស់ គ្មានមូលហេតុណាដែលមារសាតាំងត្រូវដាក់មន្ទិលសង្ស័យទៅក្នុងបុរសនោះឡើយ។ ផ្ទុយទៅវិញ មារសាតាំងបែរជាអង្គុយយ៉ាងស្ងៀម ហើយអបអរបុរសនោះ ព្រោះគាត់នឹងមានព្រទ្យសម្បត្តិច្រើនជាងមុន។ មារសាតាំងចង់អោយបុរសនោះគិតថា ខ្ញុំសុខសាន្តហើយ។ បើដាក់មន្ទិលសង្ស័យចូលទៅក្នុងបុរសនោះ គាត់នឹងស្វែងរកចំលើយពិត ដូចកាលដែលគាត់ទៅរកព្រះយេស៊ូ។

មើលទៅហាក់ដូចជាព្រះជាម្ចាស់ជាប្រភពនៃចំងល់របស់បុរសម្នាក់នោះ ។ ព្រះជាម្ចាស់ឈ្វេងយល់ពីចិត្ត របស់គាត់ ហើយដឹងថា បើមិនផ្លាស់ប្តូរអាកប្បកិរិយារបស់គាត់ដែលមានជាមួយព្រទ្យសម្បត្តិនោះចោលទេ នោះនៅពេលគាត់ស្លាប់ គាត់មិនអាចទៅស្ថានបរមសុខបានឡើយ ។ ព្រះជាម្ចាស់ចង់អោយបុរសម្នាក់នេះឃើញពី កំហុសរបស់ខ្លួន ហើយកែប្រែ ។ ព្រះយេស៊ូបានជួយបុរសអ្នកមាននោះអោយដឹងពីមូលហេតុ ដែលគាត់មានចំងល់ និងមន្ទិលសង្ស័យ ។ នៅពេលយើងដឹងពីមូលហេតុដែលនាំមកនូវមន្ទិលសង្ស័យ យើងនឹងត្រូវធ្វើការជ្រើសរើស - តើយើងនឹងឈានទៅដោះស្រាយជាមួយនឹងបញ្ហា ដែលបង្កអោយមានមន្ទិលសង្ស័យ ឬអត់?

## ១. តើអ្វីខ្លះជាដើមហេតុនៃមន្ទិលសង្ស័យ?

ធ្លាប់មានគេប្រាប់បងប្អូនថា "បើយើងមានមន្ទិលសង្ស័យចំពោះព្រះជាម្ចាស់ ហើយបើនៅតែធ្វើជាគ្រិស្ត បរិស័ទទៀត មិនមែនជាការល្អឡើយ" ។ ស្តាប់ទៅដូចជាសំដីមិត្តភក្តិរបស់លោក**យ៉ូប** ដែលបានប្រាប់គាត់ នៅពេលដែលគាត់កំពុងជួបទុក្ខលំបាក និងការឈឺចាប់ ។ បើយើងសង្ស័យ មិនមែនមានន័យថា យើងបានប្រព្រឹត្ត អំពើបាបនោះឡើយ ។

គ្រប់ការសង្ស័យសុទ្ធតែមានដើមហេតុ ។ ប្រសិនបើចង់កំចាត់មន្ទិលសង្ស័យទាំងនោះចេញ សូមស្វែងរក ដើមហេតុដែលធ្វើអោយយើងមានបញ្ហានៅក្នុងជីវិតនេះ ។ យើងនឹងយកដើមហេតុនៃមន្ទិលសង្ស័យទាំងអស់មក ហើយចែកវាចេញជាបីក្រុម ។

### កង្វះខាតខាងចំណេះដឹង

កង្វះខាតខាងចំណេះដឹងក៏អាចជាដើមហេតុនៃមន្ទិលសង្ស័យដែរ ។ នៅពេលដែលយើងទទួលបាននូវព័ត៌មាន ត្រឹមត្រូវ បញ្ហារបស់យើងត្រូវបានបំភ្លឺ ហើយយើងក៏អាចកំចាត់មន្ទិលសង្ស័យចេញពីខ្លួនយើងដែរ ។ ឧទាហរណ៍: យើងធ្លាប់ឮគេប្រាប់ថា ដរាបណាយើងជាគ្រិស្តបរិស័ទ យើងនឹងមានអារម្មណ៍ថាមានសេចក្តីស្រឡាញ់ អំណរ និង ភាពសុខសាន្តជារៀងរាល់ថ្ងៃ ។ នៅថ្ងៃមួយ ក្នុងពេលដែលយើងបាត់បង់អារម្មណ៍បែបនេះ មន្ទិលសង្ស័យនឹងចូល មកក្នុងគំនិតរបស់យើងភ្លាម ។ នៅពេលយើងដឹងពីសេចក្តីពិត យើងនឹងដឹងថា ព្រះគម្ពីរមិនបានចែងបែបនេះទេ ។ មន្ទិលសង្ស័យអាចចាក់ចេញពីគំនិតរបស់យើង ដោយសារតែយើងដឹងថា គ្រិស្តបរិស័ទមិនមែនរស់ទៅតាមអា រម្មណ៍នោះឡើយ ។

### កង្វះខាតខាងការយល់ដឹង

ការសង្ស័យខ្លះកើតចេញពីការស្គាល់សេចក្តីពិត តែមានបានយល់អោយច្បាស់អំពីសេចក្តីពិតនោះ ដែលមាន ជាប់ទាក់ទងជាមួយនឹងជីវិតរបស់យើង ។ គ្រិស្តបរិស័ទខ្លះបានស្គាល់ព្រះបន្ទូលដែលមាននៅក្នុងព្រះគម្ពីរ ប៉ុន្តែពួក គេមិនដឹងពីរបៀបអនុវត្តតាមព្រះបន្ទូល នៅពេលខ្លួនជួបបញ្ហាផ្ទាល់នោះឡើយ ។ ពួកគេដឹងខគម្ពីរ ភីលីព ៤:១៩ បានចែងថា "ព្រះរបស់ខ្ញុំនឹងបំពេញគ្រប់សេចក្តីត្រូវការរបស់បងប្អូន ស្របតាមសេចក្តីរុងរឿងដ៏ប្រសើរបំផុតរបស់

ព្រះអង្គ ដោយរួមក្នុងអង្គព្រះគ្រិស្តយេស៊ូ" ។ ប៉ុន្តែពួកគេនៅមានតំរូវការជាច្រើន ហើយពួកគេមិនយល់ទាល់តែសោះ តើពួកគេធ្វើអ្វីខុស បានជាពួកគេនៅតែខ្វះខាត ។

ពួកគេអាន យ៉ាកុប ៤:៧-៨ ដើម្បីប្រឆាំងជាមួយនឹងមារ ហើយចូលទៅជិតព្រះជាម្ចាស់ ។ ខគម្ពីរបានប្រាប់យ៉ាងច្បាស់ ប៉ុន្តែរបៀបអនុវត្តដូចជាមិនច្បាស់សោះ ។ បើលំអិតជាងនេះទៀត ប្រាកដជាល្អ ។ ប៉ុន្តែជួនកាលការយល់អាចចេញមកពីបទពិសោធន៍ ។ បន្ទាប់ពីយើងឆ្លងកាត់បទពិសោធន៍លំបាករួចមក យើងនឹងយល់ថា ហេតុអ្វីបានជាព្រះជាម្ចាស់អោយការលំបាកនេះកើតឡើង ។ នៅពេលយើងកំពុងជួបបញ្ហា ទោះជាប្រាប់យ៉ាងណា ក៏យើងពិបាកទទួលដែរ ។

## កង្វះខាតខាងឥរិយាបថ

មន្ទិលសង្ស័យជាច្រើនបានកើតឡើងដោយសារ យើងមិនធ្វើកិច្ចការណាដែលយើងគួរធ្វើ ។ យើងចូលចិត្តធ្វើកិច្ចការណាដែលធ្វើអោយខ្លួនឯងធ្លាក់ទៅក្នុងការល្បួង និងអំពើបាប ។ មារសាតាំងតែងតែដាក់គំនិតនៃការស្តីបន្ទោសមកយើងថា "អ្នកឯងមិនមែនជាគ្រិស្តបរិស័ទល្អទេ អំពើដែលអ្នកទើបតែធ្វើ ជាអំពើអាក្រក់ណាស់! បែបនេះ អ្នកនឹងមិនអាចធ្វើជាគ្រិស្តបរិស័ទបានឡើយ" ។ ពេលខ្លះ យើងនាំមន្ទិលសង្ស័យចូលមកក្នុងខ្លួនយើង នៅពេលយើងមានគោលដៅមិនសមហេតុផលសំរាប់ជីវិត ។ ដំណើរការធំធាត់ខាងជីវិតជាគ្រិស្តបរិស័ទ រហូតដល់ក្លាយជាអ្នកដឹកនាំផ្នែកព្រលឹងវិញ្ញាណ មិនអាចកើតឡើងមួយសប្តាហ៍ ឬពីរសប្តាហ៍បានឡើយ ។

គ្រិស្តបរិស័ទភាគច្រើនដឹងអំពីសេចក្តីពិតរបស់ព្រះជាម្ចាស់ ជាងរបៀបអនុវត្តសេចក្តីពិតទាំងនេះនៅក្នុងជីវិតរបស់ពួកគេ ។ ការពិតនោះគឺ បើអនុវត្តច្រើន និងកើនច្រើន ឬ បងប្អូនគ្រាន់តែចង់ស្គាល់សេចក្តីពិតតែប៉ុណ្ណោះទេ? ប្រសិនបើបងប្អូនបោកបញ្ឆោតខ្លួនឯង ដោយជឿថាយើងស្គាល់តែសេចក្តីពិតទៅបានហើយ នោះព្រះជាម្ចាស់នឹងដាក់មន្ទិលសង្ស័យចូលមកក្នុងគំនិតរបស់បងប្អូន ពីព្រោះបងប្អូនកំពុងតែដើរផ្លូវខុស ។

មានបញ្ហាជាច្រើន ដែលធ្វើអោយគ្រិស្តបរិស័ទសង្ស័យជាមួយជំនឿរបស់ខ្លួន ។ ខាងក្រោមនេះជាបញ្ហាខ្លះៗ ដែលធ្វើអោយយើងមានមន្ទិលសង្ស័យ ។

## បញ្ហាទី១: នៅពេលដែលលែងមានអារម្មណ៍ល្អ

នៅជំពូកមុនៗ យើងបានសិក្សាអំពីអារម្មណ៍ចំពោះការប្តេជ្ញាចិត្តរបស់យើងចំពោះព្រះគ្រិស្ត ។ មានមនុស្សជាច្រើនបានទទួលបទពិសោធន៍នៃការផ្លាស់ប្តូរអារម្មណ៍ នៅពេលពួកគេបានក្លាយជាគ្រិស្តបរិស័ទ ។ អ្នកខ្លះនិយាយថា "វាមានលក្ខណៈដូចជារាត្រីក្រេបទឹកឃ្មុំអញ្ចឹង" ។ ភាពរីករាយ និងភាពសុខសាន្ត ដែលបានមកពីការលើកលែងទោសនៃអំពើបាប ជាការផ្លាស់ប្តូរមួយដែលពោរពេញដោយការរំភើប ។ បែបនេះទើបពួកគេដឹងថា ពិតជាមានព្រះជាម្ចាស់មែន ។

រាត្រីក្រេបទឹកឃ្មុំក៏បានចាកចេញទៅ ។ យើងដឹងខ្លួនឡើងនៅពេលព្រឹក ភាពរីករាយក៏មិននៅជាមួយយើងដូចយប់មិញដែរ ។ យើងអធិស្ឋាន ហាក់ដូចជាគ្មានអារម្មណ៍ជាមួយព្រះវត្តមានរបស់ព្រះជាម្ចាស់ទាល់តែសោះ ។

ការដែលអាក្រក់ជាងនេះទៀតនោះគឺ អារម្មណ៍ខឹង និងបាក់ទឹកចិត្តដែលធ្លាប់មានពីមុនមក ហាក់ដូចជាលេចឡើងវិញ។ ហើយបញ្ហាក៏កើតឡើងច្រើនជាងមុនដែរ។

នៅពេលអានព្រះគម្ពីរ ព្រះបន្ទូលហាក់ដូចជាមិនរស់សោះ។ កាន់តែអាន កាន់តែងងុយគេង។ យើងសួរខ្លួនឯង "ម៉េចក៏អញ្ចឹង?"។ នៅក្នុងស្ថានការណ៍បែបនេះ មន្ទិលសង្ស័យងាយនឹងចូលក្នុងគំនិតរបស់យើងជាទីបំផុត។

## បញ្ហាទី២: បន្តធ្លាក់ចុះ ឬក៏បន្តប្រព្រឹត្តអំពើបាប

ជាញឹកញាប់ គ្រិស្តបរិស័ទថ្មីចងចាំនូវព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ នៅក្នុងខគម្ពីរ ភីលីព ៤:១៣ និង ២កូរិនថូស៥:១៧។ ប៉ុន្តែនៅពេលដែលទៅធ្វើការ ទៅរៀន នៅផ្ទះ ជួបជាមួយអ្នកជិតខាង រស់នៅជាមួយមិត្តរួមបន្ទប់ - ទាំងនេះនាំមកនូវសំពាធយ៉ាងខ្លាំង និងបញ្ហាជាច្រើន។ ពីមួយថ្ងៃទៅមួយថ្ងៃ ការល្បួងអោយប្រព្រឹត្តអំពើបាប កាន់តែខ្លាំងឡើង១។ យើងចង់ផ្លាស់ប្រែ និងចង់ដូចព្រះគ្រិស្ត ប៉ុន្តែចំណង់របស់យើងមិនដើរស្របជាមួយនឹងឥរិយាបថរបស់យើងសោះ។ យូរ១ទៅ ការល្បួងកាន់តែមិនភាពទាក់ទាញខ្លាំងជាងមុន។ ព្រះជាម្ចាស់ហាក់ដូចជានៅឆ្ងាយណាស់។

មារសាតាំងនឹងដាក់នូវការស្តីបន្ទោសមកក្នុងគំនិតរបស់យើង បន្ទាប់ពីយើងធ្លាក់ចុះហើយបានប្រព្រឹត្តអំពើបាបរួចហើយ។ វានិយាយថា "ឯងមិនអាចធ្វើគ្រិស្តបរិស័ទបានទេ"។ យើងទូលសុំអោយព្រះជាម្ចាស់ជួយ ប៉ុន្តែអត់មានការអស្ចារ្យណាមួយកើតឡើងទាល់តែសោះ — មានតែបញ្ហា។

យើងប្រាប់ខ្លួនឯងថា "គ្មានការអស្ចារ្យអ្វីកើតឡើងសំរាប់ខ្លួនខ្ញុំទាល់តែសោះ ប្រសិនបើខ្ញុំមិនអាចយកជ័យជំនះលើអំពើបាបបាន ពិតណាស់ ខ្ញុំមិនមែនជាគ្រិស្តបរិស័ទដែលមានជោគជ័យ"។ យើងមានអារម្មណ៍ហាក់ដូចជាមិនស៊ីបជាមួយនឹងការប្តេជ្ញាចិត្តចំពោះព្រះគ្រិស្តទាល់តែសោះ។ បែបនេះមានជាប់ទាក់ទងជាមួយនឹងចំនុចនេះ សូមពិចារណាអំពីទំលាប់ចាស់របស់យើងដែលជាអំពើបាប ដែលមានតាំងពីយូរមកហើយ។

ព្រះជាម្ចាស់មិនដែលមានព្រះបន្ទូលសន្យាថា នឹងដកយកគ្រប់បញ្ហាចេញពីយើង នៅថ្ងៃដែលយើងក្លាយជាគ្រិស្តបរិស័ទនោះឡើយ។ យើងត្រូវតែរៀននូវឥរិយាបថថ្មី និងគំរូថ្មីក្នុងការប្រឈមមុខនឹងបញ្ហាទាំងឡាយ។ បែបនេះត្រូវចំណាយពេលយូរ និងការខិតខំជាច្រើន។ សូមគិតដល់កូនក្មេង តើវាដួលប៉ុន្មានដង នៅពេលដែលវារៀនដើរ? ហើយវានៅតែព្យាយាមក្រោកឡើងជានិច្ច។ ពីរបីសប្តាហ៍ ឬក៏ពីរបីខែក្រោយមក វាអាចរត់លេងពេញផ្ទះ។ យើងត្រូវចំណាយពេលច្រើនសប្តាហ៍ ឬក៏ច្រើនខែដើម្បីឈានទៅដល់ជោគជ័យលើបញ្ហារបស់យើង។

## បញ្ហាទី៣: ថ្វាយព្រះយេស៊ូតែផ្នែកខ្លះនៃជីវិតរបស់យើង

មានគ្រិស្តបរិស័ទថ្មីម្នាក់បាននិយាយថា "ខ្ញុំចង់អោយព្រះជាម្ចាស់ជួយខ្ញុំនៅក្នុងជីវិតនេះ ព្រោះខ្ញុំមានផ្នែកជាច្រើននៅក្នុងជីវិត ដែលចង់ទទួលនូវការរីកចំរើនឡើង។ ប៉ុន្តែព្រះជាម្ចាស់គ្មានសិទ្ធិមានបន្ទូលមកខ្ញុំ ចំពោះគូរស្រករបស់ខ្ញុំឡើយ"។ ចំនុចបញ្ចប់ដែលគួរអោយសោកស្តាយនៃរឿងនេះគឺ ពីរបីសប្តាហ៍ក្រោយមកបុរសម្នាក់នេះ បានជ្រើសរើសដើរតាមផ្លូវរបស់ខ្លួន ជាជាងថ្វាយជីវិតរបស់គាត់ទាំងមូលទៅព្រះគ្រិស្ត។

បងប្អូនមិនអាចរក្សាទុកដោយខ្លួនឯង នូវផ្នែកពិសេសណាមួយនៃជីវិតរបស់បងប្អូនបានឡើយ ។ ព្រះយេស៊ូត្រូវតែជាអ្នកដឹកនាំគ្រប់ផ្នែកនៅក្នុងជីវិតរបស់យើង ។ បែបនេះទើបព្រះអង្គសមជាម្ចាស់ជីវិតរបស់យើង ។ ប្រសិនបើយើងដឹងច្បាស់អំពីព្រះហឫទ័យរបស់ព្រះគ្រិស្ត នោះទើបយើងអាចធ្វើការជ្រើសរើសដោយត្រឹមត្រូវបាន ។ បើមិនថ្វាយជីវិតទាំងមូលទៅព្រះគ្រិស្តទេ មន្ទិលសង្ស័យនឹងចូលមកក្នុងពេលឆាប់ៗនេះ ។

**បញ្ហាទី៤: ក្លាយជាគ្រិស្តបរិស័ទដោយស្ងាត់ៗ**

មន្ទិលសង្ស័យអាចចូលមកក្នុងមនុស្ស ដែលមិនបានធ្វើការថ្វាយខ្លួនដល់ព្រះយេស៊ូជាសាធារណៈ ។ មនុស្សប្រភេទនេះ មានការភ័យខ្លាចចំពោះអ្នកផ្ទះ និងមិត្តរបស់ខ្លួន ។ ពួកគេគិតថា "អ្នកផ្ទះមិនយល់ពីខ្ញុំទេ" ។ ចំពោះមនុស្សដែលមិនចង់ចេញមុខមាត់ជាសាធារណៈដើម្បីព្រះគ្រិស្ត មន្ទិលសង្ស័យប្រាកដជាចូលមក ។ សូមអាន ភីលីព៣:៧ ១ពេត្រុស៣:១៥ អេភេសូ៤:២០-២៤ លូកា៩:២៦ និង រ៉ូម១:១៦ ។

**បញ្ហាទី៥: ការល្បួង**

គ្រប់គ្រិស្តបរិស័ទនឹងជួបនឹងការល្បួងអោយប្រព្រឹត្តអំពើបាប ។ ជាញឹកញាប់ គ្រិស្តបរិស័ទថ្មីមិនទាន់មានបទពិសោធន៍ជាមួយនឹងការល្បួងនៅឡើយទេ ក្នុងកំឡុងពេលពីរបីសប្តាហ៍ដំបូង ។ ហាក់ដូចជាព្រះជាម្ចាស់បានដាក់របាំងជញ្ជាំងការពារពួកគេ ដើម្បីអោយពួកគេមានឱកាសរីកចំរើនឡើងខាងផ្នែកព្រលឹងវិញ្ញាណ ។ ប៉ុន្តែពីរបីសប្តាហ៍ ឬពីរបីខែក្រោយមក ការល្បួងទាំងចាស់ទាំងថ្មីបានចូលមកដូចជាទឹកជំនន់ ហើយហូរចូលមកយ៉ាងខ្លាំងគ្រប់ច្រកល្ហក ។ ពួកគេសួរខ្លួនឯងថា "មិនរឿងអីកើតឡើងហ្នឹង? តើខ្ញុំដាច់ទំនាក់ទំនងជាមួយនឹងព្រះយេស៊ូហើយឬ? តើមានការល្បួងមកពីណាមក បើខ្ញុំបំរើព្រះយេស៊ូ?"

ការល្បួងអោយប្រព្រឹត្តអំពើបាបក៏បានមានកើតឡើងចំពោះព្រះយេស៊ូដែរ ។ ព្រះអង្គស្មោះត្រង់បំរើព្រះជាម្ចាស់អស់ពីជីវិតរបស់ព្រះអង្គ ។ មូលហេតុទីមួយគឺ ព្រះជាម្ចាស់ជឿជាក់ថា យើងអាចប្រឈមជាមួយនឹងការល្បួងទាំងនេះបាន ដោយមានជំនួយពីព្រះអង្គ ។ សូមអាន ១កូរិនថូស ១០:១៣ ។ មូលហេតុទីពីរគឺ មារសាតាំងមិនសប្បាយចិត្តទេ ចំពោះហេតុការណ៍ល្អៗដែលកើតឡើងក្នុងជីវិតយើង ។ វាមកបំផ្លាញគំរោងការណ៍ដ៏ល្អដែលព្រះជាម្ចាស់មានសំរាប់ជីវិតរបស់យើង ។ សូមកុំភ្ញាក់ផ្អើល នៅពេលឃើញការល្បួងចូលមកក្នុងជីវិតយើងដូចជាទឹកជំនន់ ។ សូមកុំសង្ស័យជាមួយនឹងព្រះជាម្ចាស់ តែសូមចូលទៅជិតព្រះអង្គ ហើយតយុទ្ធប្រឆាំងនឹងពួកមារវិញ ។

**បញ្ហាទី៦: ភាពល្ងីងល្ងចត់ដែលសំដែងទៅអ្នកដទៃ**

បញ្ហាខ្លះដែលបង្កជាភាពសង្ស័យ អាចមានដើមហេតុច្រើនផ្សេងទៀត ។ ភាពល្ងីងជូចត់ជាដើមហេតុមួយក្នុងចំណោមដើមហេតុទាំងឡាយនោះ ។ នៅពេលដែលយើងខឹង ហើយស្អប់ខ្ពើមនរណាម្នាក់ យើងកំពុងនាំយកមន្ទិលសង្ស័យចូលមកដោយមិនដឹងខ្លួន ។ ភាពល្ងីងជូចត់ដែលសំដែងទៅកាន់អ្នកដទៃ គឺជាបទល្មើសដែលប្រឆាំងនឹងក្រិត្យវិន័យរបស់ព្រះជាម្ចាស់ ព្រោះព្រះអង្គគាប់ព្រះហឫទ័យអោយយើង អត់ទោសដល់គ្រប់មនុស្ស ដែលធ្វើខុសប្រឆាំងនឹងយើង ។ នៅពេលយើងមិនប្រណិបត្តិតាមព្រះជាម្ចាស់ យើងកំពុងតែដើរក្នុងសមុទ្រទុក្ខហើយ ។

ភាពល្ងីងឆ្គួតនឹងជះឥទ្ធិពលអាក្រក់ទៅក្នុងជីវិតរបស់បុគ្គល ដែលចង់អោយវានៅ ។ វានឹងបំផ្លាញភាពសុខសាន្ត និងភាពរីករាយ ដែលព្រះជាម្ចាស់គាប់ព្រះទ័យប្រទានអោយយើង ។ វានឹងបង្កភាពងាយស្រួលដល់មន្ទិលសង្ស័យក្នុងការចាក់ឫស និងរីកធំធាត់ឡើងនៅក្នុងជីវិតរបស់យើង ។

ប្រសិនបើយើងជាប់អន្ទាក់របស់ភាពល្ងីងឆ្គួត សូមចូលមករកព្រះជាម្ចាស់ ហើយស្វែងរកជំនួយពីព្រះអង្គ ដើម្បីកំចាត់ភាពល្ងីងឆ្គួតនោះចោល ។ នៅពេលយើងមានសេរីភាពពីភាពល្ងីងឆ្គួត មន្ទិលសង្ស័យក៏ចាកចេញឆ្ងាយពីយើងដែរ ។

## បញ្ហាទី៧: នៅពេលដែលសេចក្តីអធិស្ឋានយើងមិនទទួលការឆ្លើយតប

ព្រះជាម្ចាស់តែងឆ្លើយតបគ្រប់សេចក្តីអធិស្ឋាន ដែលយើងទូលសុំ ។ ម៉ាថាយ ៧:៧-១១ លើកទឹកចិត្តយើងអោយទូលសុំព្រះជាម្ចាស់ ចំពោះគ្រប់តំរូវការរបស់យើង ហើយព្រះអង្គនឹងឆ្លើយតប ។ មានគ្រិស្តបរិស័ទជាច្រើនទទួលនូវការបាក់ទឹកចិត្តចំពោះការអធិស្ឋាន ដោយសារព្រះជាម្ចាស់មិនទាន់ឆ្លើយតប ។ យើងគិតថា "ខ្ញុំធ្វើអីខុសទេដឹង?" ឬក៏ "ព្រះជាម្ចាស់យ៉ាងម៉េចហ្នឹង? ហេតុអ្វីបានជាព្រះអង្គមិនឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ?" ។ ក្នុងកំឡុងពេលនេះ យើងពិតជាឆាប់សង្ស័យ ។

ហេតុអ្វីបានជារឿយៗ ព្រះជាម្ចាស់នៅស្ងៀម? ហេតុអ្វីបានជាព្រះអង្គមិនយាងមក នៅពេលយើងទូលសុំជំនួយពីព្រះអង្គ? ចំលើយនោះ គឺពិបាកយល់ណាស់ ។ ប្រហែលជាពេលខ្លះ វាជាបញ្ហារបស់យើង ព្រោះយើងរំពឹងចង់ឃើញព្រះជាម្ចាស់ឆ្លើយតប់គ្រប់សេចក្តីអធិស្ឋានរបស់យើង ។ ព្រះជាម្ចាស់អាចនឹងមិនឆ្លើយតប ឬក៏អោយយើងចាំសិន ។

នៅក្នុងសម្ពន្ធមេត្រីចាស់ មនុស្សដែលស្មោះត្រង់ជាមួយនឹងព្រះជាម្ចាស់ម្នាក់ ឈ្មោះលោក**យ៉ូប** បានអធិស្ឋាន ហើយអធិស្ឋានទៀត ប៉ុន្តែពុំបានទទួលនូវការឆ្លើយតប ចំពោះបញ្ហាដែលកំពុងកើតមានឡើងនោះឡើយ ។ ព្រះជាម្ចាស់ប្រហែលជាមានហេតុផលល្អ ក្នុងការមិនឆ្លើយតបនឹងសេចក្តីអធិស្ឋានរបស់យើង ។ ឬក៏ព្រះអង្គកំពុងតែឆ្លើយតប ប៉ុន្តែយើងស្តាប់មិនឮ ។ នៅពេលដែលបងប្អូនមិនទាន់ទទួលនូវការឆ្លើយតប ចំពោះសេចក្តីអធិស្ឋានរបស់បងប្អូន សូមកុំអនុញ្ញាតអោយមន្ទិលសង្ស័យដែលមកពីមារសាតាំង ចូលមកក្នុងគំនិតរបស់បងប្អូនអោយសោះ ។ សូមសិក្សាព្រះគម្ពីរ ហើយរៀនស្តាប់ព្រះជាម្ចាស់តាមរយៈព្រះបន្ទូលរបស់ព្រះអង្គ ដែលមាននៅក្នុងព្រះគម្ពីរ ។

## បញ្ហាទី៨: ចិត្តមិនចង់កែតំរូវកំហុសពីអតីតកាល

ព្រះជាម្ចាស់ពិតជាមានព្រះហឫទ័យបារម្ភក្នុងការជួយមនុស្សលោក អោយត្រឡប់មករកព្រះអង្គវិញ ។ ការសង្គ្រោះជាចំនុចសំខាន់ទីមួយនៃដំណើរការស្ថាបនាទំនាក់ទំនងជាមួយព្រះអង្គឡើងវិញ ។ អំពើបាបបានញែកយើងអោយចេញឆ្ងាយពីព្រះជាម្ចាស់ ។ ឥឡូវនេះ ព្រះអង្គមានបន្ទូលហៅយើងថា បុត្រាបុត្រីរបស់ព្រះអង្គ ។ ព្រះអង្គលើកលែងទោសរាល់អំពើបាបរបស់យើង ។ ចុះចំណែកមនុស្សផ្សេងទៀត ដែលជាប់ពាក់ព័ន្ធជាមួយនឹងអំពើបាបពីអតីតកាលរបស់យើងវិញ?

ព្រះជាម្ចាស់បានលើកលែងទោសអោយយើង ប៉ុន្តែជាច្រើនលើកច្រើនសារ យើងមិនបានអភ័យទោសអោយអ្នកដទៃឡើយ ។ បងប្អូនមានការទទួលខុសត្រូវ ក្នុងការស្ថាបនាទំនាក់ទំនងដែលបានខូចខាត កាលពីនៅអតីតកាល ។ ការស្ថាបនាទំនាក់ទំនងឡើងវិញ មិនមែនជាការស្រួលនិយាយនោះឡើយ ហើយបើធ្វើ កាន់តែយ៉ាប់ជាងនេះទៅទៀត ។ ប៉ុន្តែព្រះជាម្ចាស់អាចប្រើឱកាសដ៏អស្ចារ្យនេះ ដើម្បីបង្ហាញអោយច្បាស់ថា ព្រះអង្គបានបំផ្លាស់បំប្រែជីវិតរបស់យើង ។ ប្រសិនបើបងប្អូនបដិសេធមិនស្តាប់តាមព្រះវិញ្ញាណ ដែលបង្ហាញអំពីកំហុសរបស់បងប្អូន ដែលមិនបានស្ថាបនាទំនាក់ទំនងឡើងវិញ នោះបងប្អូនកំពុងតែបើកទ្វារសំរាប់មន្ទិលសង្ស័យហើយ ។ សូមជឿជាក់លើអំណាចរបស់ព្រះជាម្ចាស់ ក្នុងការជួយបងប្អូនប្រឆាំងនឹងមារសាតាំង ព្រោះវាធ្វើអោយបងប្អូនមានការភ័យខ្លាចក្នុងការស្ថាបនាទំនាក់ទំនងឡើងវិញ ។ សូមអាន ម៉ាថាយ ៥:២៣-២៤ ។

## បញ្ហាទី៩: ការភ័យខ្លាច

ការភ័យខ្លាច និងការសង្ស័យជាដៃគូរនឹងគ្នា ។ ការភ័យខ្លាចបានធ្វើអោយលោកពេត្រុសមានមន្ទិលសង្ស័យបន្ទាប់ពីសុំបញ្ជាពីព្រះយេស៊ូ ដើម្បីដើរលើទឹកនៅសមុទ្រកាលីឡេក្នុងខណៈមានខ្យល់បក់ខ្លាំង ។ (សូមអានព្រះគម្ពីរ ម៉ាថាយ១៤:២៨-៣១) យើងត្រូវប្រយ័ត្នមិនត្រូវអោយកាលៈទេសៈនៅជុំវិញខ្លួនយើង នាំមន្ទិលសង្ស័យ និងការភ័យខ្លាចចូលមកក្នុងយើងឡើយ ។

មានការភ័យខ្លាចមួយប្រភេទដែលល្អ ហើយយើងគួរតែមាន ។ ឧទាហរណ៍: ភ័យខ្លាចក្នុងការប៉ះពាល់ដុំដែកដែលឆេះឡើងក្រហម ឬក៏ខ្សែភ្លើងដែលមានចរន្ត ហើយឆក់បែកផ្កាភ្លើងធំៗ ។ ការភ័យខ្លាចបែបនេះមិននាំមន្ទិលសង្ស័យមកក្នុងគំនិតរបស់យើងនោះឡើយ ។

អ្នកខ្លះភ័យខ្លាចថា ព្រះជាម្ចាស់នឹងមិនដោះស្រាយបញ្ហាអោយពួកគេ (គេគិតថា ព្រះអង្គដោះស្រាយតែបញ្ហាណា ដែលព្រះអង្គគាប់ព្រះហឫទ័យប៉ុណ្ណោះ ។) គេគិតតែខ្លួនឯងថា បើព្រះជាម្ចាស់មិនគាប់ព្រះហឫទ័យ ពួកគេប្រហែលជានឹងព្យាយាមដោះស្រាយដោយខ្លួនឯង ។ ការភ័យខ្លាចបែបនេះបង្ហាញពីភាពខ្វះជំនឿលើព្រះជាម្ចាស់ ។ ព្រះគម្ពីរបានថែងថា ដ្បិតព្រះជាម្ចាស់ពុំបានប្រទានអោយយើងនូវវិញ្ញាណ ដែលនាំអោយខ្លាចទេ (២ធីម៉ូថេ ១:៧) គឺព្រះអង្គប្រទានអោយយើងទទួលវិញ្ញាណដែលផ្តល់កម្លាំង សេចក្តីស្រឡាញ់ និងចិត្តធ្ងន់ ។ សូមអាន សុភាសិត៣:៥-៦ ១យ៉ូហាន៤:១៨ និង យ៉ូហាន១៤:២៧ ។

## បញ្ហាទី១០: អំណួត

អំណួតជាសត្រូវមួយដ៏អាក្រក់ជាមួយនឹងគ្រិស្តបរិស័ទ ។ មានគ្រិស្តបរិស័ទជាច្រើន ទាំងក្មេងទាំងចាស់ បានជាប់អន្ទាក់ និងត្រូវបំផ្លាញដោយសារបញ្ហាអំណួតនេះ ។ នៅក្នុងព្រះគម្ពីរទាំងមូល បងប្អូនអាចឃើញថា ព្រះជាម្ចាស់មានបន្ទូលប្រាប់អ្នកដើរតាមព្រះអង្គអោយចេះបន្ទាបខ្លួន ហើយដកចេញនូវអំណួតទាំងឡាយ ។ បញ្ហានេះមិនមែនទើបតែកើតមានឡើងទេ ៣០០០ឆ្នាំមុនក៏អញ្ចឹងដែរ ។

មនុស្សដែលមានអំណួតមិនអាចស្តាប់ឮព្រះវិញ្ញាណមានបន្ទូលឡើយ ។ ជួនកាល ព្រះជាម្ចាស់ដាក់មន្ទិលសង្ស័យចូលក្នុងមនុស្សប្រភេទនេះ ដែលគិតថាខ្លួនឯងមានជីវិតខាងព្រលឹងវិញ្ញាណខ្ពស់ជាងគេ ប៉ុន្តែនៅក្នុង

ព្រះនេត្ររបស់ព្រះជាម្ចាស់វិញ ពួកគេមិនមែនជាអ្នកដើរតាមគ្រិស្តឡើយ ។ ព្រះអង្គនឹងដាក់មន្ទិលសង្ស័យចូលក្នុងពួកគេ ដើម្បីបង្ហាញពីកំហុសរបស់ពួកគេ ដែលដើរផ្លូវខុស ។ សូមអាន ២កូរិនថូស ៧:១៤ ។

ប្រសិនបើបងប្អូនមានមន្ទិលនៅក្នុងគំនិត មិនមែនមានន័យថាបងប្អូនមានបញ្ហា ដូចបញ្ហាទាំង១០ដែលបានរៀបរាប់ខាងលើនោះឡើយ ។ នៅមានបញ្ហាជាច្រើនទៀតដែលនាំមកនូវមន្ទិលសង្ស័យ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅពេលដែលបងប្អូនមានមន្ទិលសង្ស័យ សូមពិនិត្យមើលជីវិតរបស់បងប្អូន ។ ប្រសិនបើមានបញ្ហាស្រដៀងនេះ សូមដោះស្រាយអោយរួចរាល់ ។

## គ. តើយើងអាចរកឃើញដើមហេតុនៃមន្ទិលសង្ស័យដោយរបៀបណា?

ព្រះយេស៊ូមានព្រះហឫទ័យចង់ជួយយើងជំរះមន្ទិលសង្ស័យ ដែលមាននៅក្នុងគំនិតរបស់យើងចេញ ។ គ្មានថ្នាំណាអាចផ្តាច់មន្ទិលសង្ស័យនេះរហូតបានឡើយ ។

### ១. អធិស្ឋាន

មន្ទិលសង្ស័យជាបញ្ហាមួយដែលកើតមាននៅក្នុងគំនិតរបស់យើង ។ ការអធិស្ឋានជាការនិយាយទៅកាន់ព្រះជាម្ចាស់ ។ សូមទូលប្រាប់ព្រះអង្គអំពី រាល់ហេតុការណ៍ដែលបងប្អូនជួបប្រទះ ។ សូមអនុញ្ញាតអោយព្រះយេស៊ូដឹកនាំការគិតរបស់បងប្អូន ។ ព្រះអង្គមានអំណាចដើម្បីជួយបងប្អូន ប្រឆាំងជាមួយរាល់មន្ទិលសង្ស័យដែលចូលមកក្នុងបងប្អូន ។

### ២. សូមគិតពិចារណាបញ្ហានោះឡើងវិញ

សូមកុំធ្វេសប្រហែសជាមួយនឹងមន្ទិលសង្ស័យ ។ សូមកុំបន្ទោសតែមារសាតាំង ហើយព្យាយាមបំភ្លេចមន្ទិលសង្ស័យចោល ។ ជួនកាល បែបនេះអាចជាវិធីល្អ ប៉ុន្តែជាញឹកញាប់ វាមិនមែនជាវិធីល្អឡើយ ។ សូមព្យាយាមស្វែងរកមូលហេតុដែលបង្កជាមន្ទិលសង្ស័យ ។

មុននេះ យើងបានពិភាក្សាអំពីបញ្ហា៣ប្រភេទ ដែលជាប់ទាក់ទងជាមួយនឹងមន្ទិលសង្ស័យគឺ កង្វះខាតខាងចំណេះដឹង កង្វះខាតខាងការយល់ដឹង និងកង្វះខាតខាងឥរិយាបថ ។ តើមន្ទិលសង្ស័យរបស់បងប្អូន ស្ថិតនៅក្នុងបញ្ហាប្រភេទមួយណា? បែបនេះអាចជាជំនួយយ៉ាងសំខាន់ ចំពោះការរកដំណោះស្រាយដ៏ល្អបំផុត ដែលអាចជួយបងប្អូនបាន ។

នៅពេលដែលបងប្អូនកំពុងតែគិតពិចារណាបញ្ហានោះឡើងវិញ សូមព្យាយាមរកអោយឃើញថា នរណាជាអ្នកនាំមន្ទិលសង្ស័យបែបនេះ ចូលមកក្នុងគំនិតរបស់បងប្អូន ។មារសាតាំង មិត្តរបស់យើង អ្នកមិនជឿព្រះជាម្ចាស់ ឬមួយក៏ព្រះជាម្ចាស់? តើខ្លួនយើងជាមេហេតុ នាំមន្ទិលចូលមក?

### ៣. សិក្សាព្រះគម្ពីរ

បងប្អូនអាចរកឃើញចំលើយដ៏ល្អសំរាប់មន្ទិលសង្ស័យរបស់បងប្អូនបាន ដោយការអានព្រះគម្ពីរ ។ បើបងប្អូនកាន់តែសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ បងប្អូនកាន់តែយល់អំពីរបៀប ដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យចង់អោយយើងរស់ជីវិតនេះ ។ ប្រសិនបើបងប្អូនរកឃើញបញ្ហាដែលបង្កជាមន្ទិលសង្ស័យ សូមអានព្រះគម្ពីរ តើព្រះគម្ពីរបានចែងយ៉ាងដូចម្តេចខ្លះអំពីបញ្ហានោះ ។

### ៤. ចំណាយពេលជាមួយនឹងគ្រិស្តបរិស័ទផ្សេងទៀត

យើងចាំបាច់ត្រូវតែបង្កើតមិត្តភាពជាមួយនឹងគ្រិស្តបរិស័ទដែលចាស់ទុំខាងវិញ្ញាណ យ៉ាងហោចណាស់ក៏អោយបានម្នាក់ដែរ ។ គ្រិស្តបរិស័ទម្នាក់នោះអាចជួយយើងនៅពេលយើងមានមន្ទិលសង្ស័យបាន ។ ជួនកាលគ្រាន់តែនិយាយជាមួយនឹងគ្រិស្តបរិស័ទម្នាក់ ក៏អាចជួយកំចាត់មន្ទិលសង្ស័យចេញពីគំនិតរបស់យើងបានដែរ ។

មន្ទិលសង្ស័យរបស់យើងម្នាក់ៗ អាចខុសពីមន្ទិលសង្ស័យរបស់គ្រិស្តបរិស័ទផ្សេងទៀត ដែលគាត់បានជួបកាលពីអតីតកាល ។ សូមកុំភ្ញាក់ផ្អើល! ព្រះជាម្ចាស់ត្រៀមជាស្រេច ដើម្បីជួយយើងអោយឈ្នះលើមន្ទិលសង្ស័យទាំងអស់នោះ ។ ព្រះអង្គអាចប្រើគ្រិស្តបរិស័ទម្នាក់អោយមកជួយយើង ឬក៏ព្រះអង្គអនុញ្ញាតអោយយើងឆ្លងកាត់មន្ទិលទាំងអស់នោះ ដោយមានជំនួយពីព្រះអង្គ ។ សូមចងចាំថា ព្រះជាម្ចាស់មិនគាប់ព្រះហឫទ័យអោយមន្ទិលសង្ស័យ នៅជាប់ក្នុងជីវិតរបស់យើងរហូតឡើយ ។ នៅពេលដែលបងប្អូនរកឃើញមូលហេតុដែលបង្កជាមន្ទិលសូមសំឡឹងមើលទៅព្រះជាម្ចាស់ ដើម្បីសុំដំណោះស្រាយ និងកំចាត់បញ្ហាដែលបង្កជាមន្ទិលសង្ស័យនោះចេញ ។

## ឃ. តើត្រូវបណ្តេញមន្ទិលសង្ស័យរបស់យើងចេញដោយរបៀបណា?

មន្ទិលសង្ស័យអាចឈ្នះលើយើង ឬដោយមានជំនួយពីព្រះជាម្ចាស់ មន្ទិលសង្ស័យទាំងនោះនឹងធ្វើអោយយើងខ្លាំងជាងមុន ក្នុងការមានទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះយេស៊ូ ។ ប្រសិនបើយើងដាក់ព្រះអង្គជាអទិភាពទី១ នៅក្នុងជីវិតរបស់យើង មន្ទិលសង្ស័យមិនអាចស្ថិតនៅជាប់នឹងយើងបានយូរឡើយ ។

ខាងក្រោមនេះជាការណែនាំខ្លះៗ ដែលអាចបងប្អូនអោយឈ្នះលើមន្ទិលសង្ស័យបាន ។ យើងខ្ញុំនឹងរៀបរាប់ខ្លីៗ ចំពោះបញ្ហាមួយចំនួនដែលយើងបានពិភាក្សារួចហើយ ។

### ១. ទទួលស្គាល់ថាបងប្អូនមានមន្ទិលសង្ស័យ

សំរាប់មនុស្សខ្លះ ការទទួលស្គាល់ថាខ្លួនឯងមានមន្ទិលសង្ស័យ អាចប៉ះពាល់ដល់មុខមាត់របស់គេ ។ ពួកគេគិតថា មន្ទិលសង្ស័យនេះដូចជាជំងឺអញ្ជឹង ។ ពួកគេនិយាយថា "បើទទួលស្គាល់ថាខ្ញុំមានមន្ទិលសង្ស័យ មនុស្សដែលនៅជុំវិញខ្លួនខ្ញុំនឹងគិតថា ខ្ញុំជាគ្រិស្តបរិស័ទខ្សោយមិនខាន" ។

កាទទួលស្គាល់ថាខ្លួនឯងមានមន្ទិលសង្ស័យ ជាជំហានទី១ក្នុងការកំចាត់វាចេញ។ មន្ទិលខ្លះអាចទាញចេញពីគំនិតរបស់យើង ដោយគ្រាន់តែអធិស្ឋានទៅព្រះជាម្ចាស់ប៉ុណ្ណោះ។ ប៉ុន្តែបើវាត្រឡប់មកវិញ សូមពិនិត្យមើលវាអោយបានច្បាស់។

**២. សូមទូលថ្វាយដល់ព្រះជាម្ចាស់**

ផ្លូវឈានទៅរកសេរីភាពពីមន្ទិលសង្ស័យ គឺត្រូវចាប់ផ្តើមជាមួយនឹងព្រះជាម្ចាស់។ សូមចំណាយពេលប្រាប់ព្រះអង្គ អំពីអ្វីៗដែលកើតមាននៅក្នុងគំនិតរបស់បងប្អូន។ ព្រះអង្គនឹងមិនខ្វាល់ ឬក៏មានព្រះហឫទ័យភ្ញាក់ផ្អើលជាមួយនឹងបងប្អូនឡើយ។ សូមកុំភ្ញាក់ផ្អើល បើបងប្អូនមិនបានឮអ្វីពីព្រះអង្គ។ (បែបនេះប្រហែលជាធ្វើអោយបងប្អូនសង្ស័យថា ព្រះជាម្ចាស់ហាក់ដូចជានៅស្ងៀម ហើយនៅឆ្ងាយទៀតផង) ទោះយ៉ាងណាក៏ដោយ សូមនិយាយទៅកាន់ព្រះអង្គ។ ទូលព្រះអង្គថា ការគិតរបស់បងប្អូនជាដើមហេតុ ដែលធ្វើអោយបងប្អូនមានមន្ទិលសង្ស័យ។ ទូលសុំព្រះអង្គនូវប្រាជ្ញា ដើម្បីបំបែកមន្ទិលសង្ស័យនោះ។ សូមទូលព្រះអង្គរហូតទាល់តែបងប្អូនអាចយកឈ្នះវា។

**៣. ពិនិត្យរកមន្ទិលសង្ស័យ**

សូមចូលទៅជិត ហើយពិនិត្យមើលវា។ សូមព្យាយាមគិតរកបញ្ហាដែលបង្កអោយមានមន្ទិលសង្ស័យនេះ។ កត់សំគាល់មនុស្ស ដែលនាំយកមន្ទិលសង្ស័យមកក្នុងគំនិតរបស់យើង។ អានព្រះគម្ពីរដើម្បីស្វែងរកចំនុច ដែលបានចែងអំពីមន្ទិលសង្ស័យប្រភេទនេះ។

**៤. ទូលសួរព្រះជាម្ចាស់អំពី វិធីដែលព្រះអង្គគាប់ព្រះហឫទ័យចង់អោយយើងដកយកមន្ទិលចេញ**

ជួនកាលយើងចង់អោយព្រះជាម្ចាស់ធ្វើជីវិតយើងអោយសុខស្រួល។ "ព្រះជាម្ចាស់អើយ សូមអោយមន្ទិលសង្ស័យនេះរលាយក្នុងពេលនេះទៅ!"។ ប្រសិនបើព្រះជាម្ចាស់មិនទាន់ឆ្លើយតប យើងអាចនឹងមានមន្ទិលច្រើនជាងមុនទៅទៀត។ សូមទទួលខុសត្រូវក្នុងការដោះស្រាយ ជាមួយនឹងមន្ទិលសង្ស័យរបស់ខ្លួនឯង។

សិក្សាព្រះគម្ពីរ ហើយព្យាយាមរកមើលវិធីនៃការដោះស្រាយបញ្ហា ដែលបង្កជាមន្ទិលសង្ស័យ។ នៅពេលយើងស្គាល់បញ្ហាដែលបង្កជាមន្ទិល ទិសដៅដែលនាំទៅរកដំណោះស្រាយនឹងបង្ហាញចេញមក។

សូមកុំរំពឹងថា ព្រះជាម្ចាស់នឹងទំលាក់ដំណោះស្រាយដ៏ល្អចុះមក។ សូមសុំព្រះជាម្ចាស់អោយជួយ ក្នុងការប្រឈមមុខដោះស្រាយជាមួយនឹងបញ្ហាទាំងនោះ សូមជ្រាបថា ព្រះអង្គរំពឹងថាយើងនឹងប្រឈមមុខដោះស្រាយ។ មានបុរសម្នាក់មកសុំព្រះយេស៊ូអោយជួយ។ កូនប្រុសរបស់គាត់ត្រូវការការព្យាបាល ហើយគាត់ទូលព្រះអង្គថា "លោកម្ចាស់អើយ ខ្ញុំប្របាទជឿហើយ! សូមមេត្តាជួយអោយខ្ញុំប្របាទ ដែលជាអ្នកមិនជឿនេះផង!" គាត់ដឹងថាគាត់នៅមានមន្ទិលសង្ស័យនៅឡើយ។ បុរសនោះមិនបានអង្គុយនៅផ្ទះរង់ចាំការអស្ចារ្យកើតឡើងនោះឡើយ។ គាត់ចេញមករកព្រះយេស៊ូ ដើម្បីសុំព្រះអង្គអោយជួយ។

### ៥. ដាក់គោលដៅដែលនឹងជួយយើងកំចាត់មន្ទិលសង្ស័យចេញ តាមវិធីរបស់ព្រះជាម្ចាស់

ព្រះជាម្ចាស់អាចផ្តល់អោយយើងនូវប្រាជ្ញា ដើម្បីយកឈ្នះលើគ្រប់មន្ទិលសង្ស័យ ដែលចូលមកក្នុងគំនិតរបស់យើង ។ សូមដាក់គោលដៅក្នុងការជំរះមន្ទិលសង្ស័យ ។ សូមអធិស្ឋានជារៀងរាល់ថ្ងៃ ហើយសូមព្យាយាមចងចាំនៅក្នុងគំនិត នូវរាល់ព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ។ ហើយចាប់ផ្តើមផ្លាស់ប្រែចិត្តគំនិត ។ ការផ្លាស់ប្រែបែបនេះនឹងអាចកំចាត់រាល់បញ្ហា ដែលបង្កមន្ទិលសង្ស័យបាន ។ ប្រសិនបើយើងមានភាពជូចត់ដោយខឹងជាមួយនឹងមនុស្សម្នាក់ សូមអភ័យទោសអោយគេ ។ សូមរៀបចំគំរោង ដើម្បីស្ថាបនាទំនាក់ទនងឡើងវិញ ។ បែបនេះទើបមន្ទិលសង្ស័យមិនអាចចូលមកបាន ។

ប្រសិនបើបងប្អូនព្យាយាមកំចាត់បញ្ហាទាំងនេះ ប៉ុន្តែមិនអាចមានដំណោះស្រាយសមស្រប សូមកុំបោះបង់ចោល ។ សូមព្យាយាមជាថ្មីម្តងទៀត! សូមព្យាយាមរកដំណោះស្រាយណាដែលមានប្រសិទ្ធភាព ។ បងប្អូនអាចទៅសុំអោយគ្រិស្តបរិស័ទម្នាក់ទៀតជួយបាន ។

សូមខំប្រឹងអោយអស់ពីលទ្ធភាព ដើម្បីដកមន្ទិលសង្ស័យចេញ ។ សំខាន់ជាងគេនោះ សូមចាំថា យើងត្រូវការជំនួយពីព្រះជាម្ចាស់ ដើម្បីរស់ជាគ្រិស្តបរិស័ទ ។ ព្រះជាម្ចាស់អាចនឹងអនុញ្ញាតិអោយមន្ទិលសង្ស័យចូលមកក្នុងយើង ដើម្បីសាកល្បងយើង និងផ្តល់ឱកាសអោយយើងរីកចំរើនខ្លាំងជាងមុន ។ ទោះជាមន្ទិលសង្ស័យនៅ ឬមិននៅក្នុងខ្លួនរបស់យើងក៏ដោយ យើងអាចឈរយ៉ាងរឹងមាំនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយនិយាយថា "ខ្ញុំដឹងខ្លួនឯងច្បាស់ថា ខ្ញុំជាគ្រិស្តបរិស័ទ" ។